សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បទល្មើសពាក់ព័ន្ធ នឹងការជួញដូរមូលបត្រ

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ពេជ្រ កក្កដា**
**ក. ស៊ឹម សៀកឡេង**

សាស្ត្រាចារ្យណែនាំ
លោក **ឃឹម ឧត្តម**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បទល្មើសពាក់ព័ន្ធ នឹងការជួញដូរមូលបត្រ

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ក. **ពេជ្រ ភក្កដា**
ក. **ស៊ឹម សៀកឡេង**

សាស្ត្រាចារ្យណែនាំ
លោក **ឃឹម ឧត្តម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ពេជ្រ កក្កដា** និង **ស៊ឹម សៀកឡេង** ជាកូន និងជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី១៩ ក្នុងឆ្នាំសិក្សា ២០១៥ ដល់២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកអ្នកមានគុណទាំងពីរះ

- លោកឪពុកឈ្មោះ **ម៉ុក ពេជ្រ** និងអ្នកម្តាយឈ្មោះ **គង់ រិន**
- លោកឪពុកឈ្មោះ **អ៊ុន គីម** និងអ្នកម្តាយឈ្មោះ **ចាន់ ស្រីទូច**

យើងខ្ញុំជាកូនសូមលំឱនកាយក្រាបថ្វាយបង្គំដោយកិច្ចប្រណិប័តន៍ សម្តែងនូវកតញ្ញូ យ៉ាងជ្រាលជ្រៅបំផុត ជូនលោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងជួយជ្រោមជ្រែង ផ្តល់សព្វបែបយ៉ាងទាំងស្មារតី សម្ភារៈ និងថវិកា មកលើរូបកូនឱ្យមានលទ្ធភាពចូលសិក្សារៀនសូត្រតាំងពីថ្នាក់មត្តេយ្យរហូតដល់បានបញ្ចប់ថ្នាក់ឧត្តមសិក្សា។

- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យ**ទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងណែនាំព្រមទាំង ធ្វើការចង្អុលបង្ហាញស្ថានភាពសង្គមជាក់ស្តែងទៀតផង។ លើសពីនេះទៀត ពួកគាត់បានផ្តល់នូវជំបូន្មានដ៏ល្អៗនិងជួយណែនាំបង្ហាញផ្លូវរបស់ពួកយើងខ្ញុំដើម្បីជាទុនដល់ការស្រាវជ្រាវ និងគំនិតក្នុងការតាក់តែងនូវស្នាដៃនេះឡើង។
- ជាពិសេសដោយក្តីគោរព និងការថ្លែងអំណរគុណយ៉ាងធំធេង ជូនចំពោះលោកសាស្ត្រាចារ្យ **ឃឹម ឧត្តម** ជាសាស្ត្រាចារ្យដែលបានណែនាំនិងពន្យល់ឱ្យយើងខ្ញុំយល់ពីប្រធានមួយនេះ។ លោកសាស្ត្រាចារ្យ **ឃឹម ឧត្តម** ជាសាស្ត្រាចារ្យ ដែលទទួលបន្ទុកដឹកនាំសារណារបស់យើងខ្ញុំដែលលោកបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងពេលវេលាដ៏មានតម្លៃ និងមមាញឹករបស់លោក មកលើការត្រួតពិនិត្យ និងជួយផ្តល់អនុសាសន៍ដ៏មានតម្លៃ ក្នុងការជួយត្រួតពិនិត្យ និងការកែតម្រូវលើការសរសេរសារណារបស់យើងខ្ញុំអាចលេចចេញជារូបរាងនៅពេលនេះ។ លោកសាស្ត្រាចារ្យមានទឹកចិត្តទូលាយចេះអធ្យាស្រ័យខ្ពស់ និងគុណស្រ័យនេះយើងខ្ញុំសូមគោរពដឹងគុណនិងចងចាំជារៀងរហូត។

ជាកិច្ចបញ្ចប់ យើងខ្ញុំសូមលើកម្រាមដៃដប់ប្រណមបួងសួងទៅដល់ វត្ថុស័ក្តសិទ្ធិក្នុងលោកដែលមានរិទ្ធិបារមីទាំងអស់ក្នុងលោក សូមជួយឃុំគ្រងរក្សា អ្នកមានគុណទាំងអស់ដែលរួមមានះលោកអ្នកមានគុណទាំងពីរ ថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យដែលបានរៀបរាប់ខាងលើ សូមអោយជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អបរិបូរណ៍ អាយុយឺនយូរ និងសំណាងល្អតរៀងទៅ គ្រប់ពេលវេលា កុំបីអាក់ខានឡើយ ។

## អារម្ភកថា

កិច្ចការស្រាវជ្រាវមួយនេះ ថ្វីត្បិតតែមានការតាក់តែងឡើង ពីបណ្តាឯកសារពាក់ព័ន្ធជាច្រើន ដែលជួយសម្រួលដល់ការសិក្សាទាំងអស់អោយយល់ដឹងពី បទល្មើសព្រហ្មទណ្ឌក្នុងវិស័យមូលបត្រ ដែលកើតមានឡើងក្នុងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក។ មុខវិជ្ជានេះជាមូលដ្ឋានសម្រាប់អ្នក ដែលចាប់អារម្មណ៍ក្នុងវិស័យមូលបត្រ ឬការជួញដូរមូលបត្រជាដើម។ នៅក្នុងកិច្ចការស្រាវជ្រាវលើ ប្រធានបទនេះផងដែរយើងខ្ញុំបានសង្កេតឃើញថា មានការផ្តោតសំខាន់លើវិស័យច្បាប់ដែលពាក់ព័ន្ធ នៅក្នុងបទល្មើសនៃវិស័យមូលបត្រ ដែលបទល្មើសទាំងនោះមានក្នុងបណ្តាប្រទេសកម្ពុជាក៏ដូចជា ប្រទេសអាមេរិក។ បើទោះបីជាកិច្ចការស្រាវជ្រាវមួយនេះ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ តែវាជា ចង្កៀងដ៏តូចមួយសម្រាប់បំភ្លឺផ្លូវដល់អ្នកសិក្សា អោយបានយល់ដឹងពីបញ្ហានៅក្នុងវិស័យមូលបត្រ បានមួយផ្នែកផងដែរ។ ដោយឡែកបើយើងក្រឡេកមកមើលពីជីវភាពរស់នៅប្រចាំថ្ងៃនោះវិញ មនុស្ស តែងតែជៀសមិនផុតនោះទេ ពីការប៉ះទង្គិចគ្នានៅក្នុងសង្គម និងការធ្វើជំនួញរកស៊ី ដើម្បីទទួលបាន ប្រាក់ចំណេញនោះ។ ដូច្នេះយើងឃើញថារាជរដ្ឋាភិបាលប្រទេសកម្ពុជា ក៏ដូចជាសហរដ្ឋអាមេរិក គឺ បានយកចិត្តទុកដាក់ជាខ្លាំងលើករណីនៃការជួញដូរមូលបត្រ ហើយថ្នាក់ដឹកនាំនៃប្រទេសទាំងនេះ បានបង្កើតពីច្បាប់ និងបទប្បញ្ញត្តិមួយចំនួន ដែលពាក់ព័ន្ធ នៅក្នុងបទល្មើសមូលបត្រនេះ ឯកសារ នេះគឺអាចជួយសម្រួលក្នុងការរៀបចំប្រទេសឱ្យមានសន្តិសុខល្អ និងមានការអភិវឌ្ឍប្រទេសឈាន ទៅរកភាពរីកចម្រើនយ៉ាងល្អ និងការអន្តរាគមន៍ពីសន្តិសុខសណ្តាប់ធ្នាប់ឱ្យបានទាន់ពេលវេលានៅ ពេលដែលមានបញ្ហានៃវិវាទបានកើតមានឡើង។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា កិច្ចការស្រាវជ្រាវមួយនេះនឹងមានប្រយោជន៍ សម្រាប់អ្នក សិក្សាស្រាវជ្រាវគ្រប់រូប ដែលចង់ស្វែងយល់អំពីវិស័យមូលបត្រនេះអោយទទួលបាននូវជោគជ័យ។ យើងខ្ញុំក៏សូមអភ័យទោសនូវរាល់កំហុសខុសឆ្គង ដែលបានកើតមានឡើងជាអចេតនា ក្នុងកិច្ចការ ស្រាវជ្រាវមួយនេះផងដែរ។ យើងខ្ញុំរីករាយនឹងទទួលរាល់មតិរិះគន់ទាំងឡាយដើម្បីក្នុងន័យស្ថាបនា។

សូមអរគុណ!

# មាតិកា

**បញ្ជីពាក្យអក្សរកាត់** ---------- v

**បញ្ជីពាក្យបច្ចេកទេស** ---------- vi

**សេចក្តីផ្តើម** ---------- ១

## ជំពូកទី១

## សញ្ញាណនៃទីផ្សារមូលបត្រ

**កថាខណ្ឌទី១៖ ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ** ---------- ៣

**ក. សារតានៃទីផ្សារមូលបត្រសកល** ---------- ៣

១. ការទទួលប្រាក់ចំណេញពីការជួញដូរភាគហ៊ុន និងទទួលភាគលាភ ---------- ៥

២. ការទិញភាគហ៊ុនជម្រើសសម្រាប់ការសន្សំ ---------- ៥

៣. ការធ្វើពិពិធកម្មដោយវិនិយោគភាគហ៊ុនអាចជួយកាត់បន្ថយហានិភ័យពីការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ---------- ៦

៤. ភាគហ៊ុនមានសន្ទនីយភាពខ្ពស់ជាង ឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត ---------- ៦

៥. ទីផ្សារភាគហ៊ុនជាឧបករណ៍វាស់ស្ទង់សេដ្ឋកិច្ច ---------- ៧

៦. រួមចំណែកទទួលបានភាពជាម្ចាស់កម្មសិទ្ធិក្នុងក្រុមហ៊ុនជោគជ័យ ---------- ៧

៧. ការវិនិយោគភាគហ៊ុនជាការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច ---------- ៧

**ខ. សារតានៃទីផ្សារមូលបត្រកម្ពុជា** ---------- ៨

១. ប្រវត្តិទីផ្សារមូលបត្រកម្ពុជា ---------- ៨

២. បច្ចុប្បន្នភាពនៃទីផ្សារមូលបត្រ ---------- ៩

២.១. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ ---------- ៩

២.២. ក្រុមហ៊ុនមូលបត្របំណុល ---------- ១១

២.៣. ការបង្កើតទីផ្សារឧបករណ៍និស្សន្ទ ---------- ១២

២.៤. គម្រោងវិនិយោគរួម ---------- ១៣

**កថាខណ្ឌទី២៖ អំពីការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា** ---------- ១៣

**ក. ការបោះផ្សាយលក់មូលបត្រជាសាធារណៈ** ---------- ១៣

**ខ. លក្ខខណ្ឌតម្រូវនៃពាក្យស្នើសុំការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ** ---------- ១៤

ខ.១. ទីផ្សារដំបូង ---------- ១៤

១. អ្វីទៅជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ?----------------------------១៦
២. លក្ខខណ្ឌតម្រូវដើម្បីបោះផ្សាយលក់មូលបត្រ-------------------------------------------- ១៧
៣. នីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ------------------------------------- ២០
៣.១ ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ --- ២០
៣.២ ការតែងតាំងក្រុមហ៊ុនធានាទិញ---------------------------------------------------- ២១
៣.៣ ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ------------------------------------------------------------------------------- ២២
៣.៤ ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ --------------------------------------- ២២
៣.៥ ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាព អាចចុះបញ្ជីលក់មូលបត្រ ----------------- ២២
៣.៦ ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនិងការទទួលបានការអនុញ្ញាត ជាគោលការណ៍លើសំណើសុំបោះផ្សាយ លក់មូលបត្រជាសា-ធារណៈពី **គ.ម.ក**----------------------------------------------------------------២៣
៣.៧ ការកំណត់ថ្លៃលក់មូលបត្រ តាមរយៈប៊ុកបៀលឌីង Book Building-------------២៣
៣.៨ ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា -------- ២៥
៣.៩ ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់និងការទទួលបានការអនុញ្ញាតនិងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក**------------------------------------- ២៥
៣.១០ ការធ្វើបរិវិសកម្មមូលបត្រ---------------------------------------------------------- ២៥
៣.១១ ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្ម ------------------------------------២៧
៣.១២ ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ----------២៧
៤. កាតព្វកិច្ចផ្សេងៗដែលកើតចេញពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ----- ២៨
៤.១ កាតព្វកិច្ចដែលធ្លាក់មកលើក្រុមហ៊ុន------------------------------------------------ ២៨
៤.២ កាតព្វកិច្ចដែលធ្លាក់មកលើភាគហ៊ុនិក ----------------------------------------------- ៣០
៤.៣ អាកប្បកិរិយាដែលត្រូវបានហាមឃាត់ទាក់ទិនទៅនឹងមូលបត្រ -----------------៣២
ខ.២. ទីផ្សារបន្ទាប់-----------------------------------------------------------------------------៣២
១. ដំណើរការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់-------------------------------------------៣២
២.ការជ្រើសរើសក្រុមហ៊ុនមូលបត្រ ----------------------------------------------------------- ៣៣
៣. ការបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រ --------------------------------------- ៣៣
៤. ការដាក់បញ្ជាទិញ-លក់របស់វិនិយោគិនមូលបត្រ-----------------------------------------៣៥

៥. ការអនុវត្តបញ្ជាទិញ-លក់របស់វិនិយោគិនមូលបត្រ ---------------------------------- ៣៥
៦. ការផាត់ទាត់និងការទូទាត់ការជួញដូរមូលបត្រ ---------------------------------------- ៣៥
៧. ការរក្សាទុកមូលបត្រ ---------------------------------------------------------------------- ៣៦
**កថាខណ្ឌទី៣៖ ព័ត៌មានសាជីវកម្ម** ---------------------------------------------------------- ៣៦

# ជំពូកទី២

# បទល្មើសពាក់ព័ន្ធ នឹងការជួញដូរមូលបត្រ

**កថាខណ្ឌទី១៖ ការជួញដូរផ្ទៃក្នុង** ( Insider Trading )------------------------------------------ ៣៧
**ក. ការជួញដូរផ្ទៃក្នុងតាមច្បាប់កម្ពុជា** ------------------------------------------------------- ៣៧
១. លក្ខខណ្ឌ (បុគ្គលផ្ទៃក្នុង និងព័ត៌មានផ្ទៃក្នុង) ------------------------------------------ ៣៨
២. ទណ្ឌកម្មនៃបទល្មើសជួញដូរផ្ទៃក្នុង ------------------------------------------------------ ៤០
**ខ. ការជួញដូរផ្ទៃក្នុងតាមច្បាប់បរទេស (ករណីសហរដ្ឋអាមេរិក)**------------------------------ ៤០
១. លក្ខខណ្ឌនៃការជួញដូរផ្ទៃក្នុង (Insider Trading)------------------------------------------ ៤០
២. ទណ្ឌកម្ម ------------------------------------------------------------------------------------ ៤១
**កថាខណ្ឌទី២៖ ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ**---------------- ៤៣
**ក. ការជួញដូរក្លែងក្លាយនិងការប្រើឧបាយកលក្នុងទីផ្សារតាមច្បាប់កម្ពុជា**---------------- ៤៣
១. លក្ខខណ្ឌនៃបទល្មើស ------------------------------------------------------------------- ៤៣
២. ទណ្ឌកម្ម ------------------------------------------------------------------------------------ ៤៤
**ខ. ការរៀបចំឧបាយកលក្នុងទីផ្សារតាមច្បាប់បរទេស (Market Manipulation) (ករណីសហរដ្ឋ-អាមេរិក)**------------------------------------------------------------------------------------ ៤៤
១. លក្ខខណ្ឌនៃបទល្មើស ------------------------------------------------------------------- ៤៤
២. ទណ្ឌកម្ម ------------------------------------------------------------------------------------ ៤៥
**កថាខណ្ឌទី៣៖ សេចក្តីថ្លែងឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស** --៤៦
**ក. សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុសតាមច្បាប់កម្ពុជា (False and Misleading Statement)**----------------------------------------------------------- ៤៦
១. លក្ខខណ្ឌនៃបទល្មើស ------------------------------------------------------------------- ៤៦
២. ទណ្ឌកម្ម ------------------------------------------------------------------------------------ ៤៧
**ខ.សេក្តីថ្លែងការណ៍ក្លែងបន្លំនិងនាំអោយយល់ខុស (False and Misleading Statement) (ករណីសហរដ្ឋអាមេរិក)**------------------------------------------------------------------ ៤៧

១. លក្ខខណ្ឌនៃបទល្មើស ---------------------------------------------------------------------------- ៤៧

២.ទណ្ឌកម្ម -------------------------------------------------------------------------------------------៤៨

**សេចក្ដីសន្និដ្ឋាន**-------------------------------------------------------------------------------------------៥១

**អនុសាសន៍**---------------------------------------------------------------------------------------------------- ៥២

**ឯកសារយោង** ------------------------------------------------------------------------------------------------ ៥៣

**ឧបសម្ព័ន្ធ**---------------------------------------------------------------------------------------------------------៥៥

# បញ្ជីពាក្យអក្សរកាត់

គ.ម.ក : គណៈកម្មការមូលបត្រកម្ពុជា

ផ.ម.ក : ក្រុមហ៊ុនផ្សារមូលបត្រ

CSA : (Cash Settlement Agent) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធ នឹងមូលបត្រ

SF : (Securities Firm) ក្រុមហ៊ុនមូលបត្រ

CSO : (Cash Settlement Operator) ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ

CSX : (Cambodia Securities Exchange) ក្រុមហ៊ុនផ្សារមូលបត្រ

SECC : (Security Exchange Committee in Cambodia) គណៈកម្មការមូលបត្រ

NBC : (National Bank of Cambodia) ធនាគារជាតិនៃកម្ពុជា

CSD : (Cash Settlement Depository) ប្រតិបត្តិកររក្សារទុកមូលបត្រ

CMA : (Client Money Account) គណនីទូទាត់សាច់ប្រាក់អតិថិជន

OTC : (Over the Counter Market)

SEC : U.S. Securities and Exchange Commission

# បញ្ជីពាក្យបច្ចេកទេស

**មូលបត្រ** ( សន្ទានុក្រមរដ្ឋប្បវេណី ) គឺជាបណ្ណដែលតំណាងឱ្យសិទ្ធិលើកម្មសិទ្ធិរបស់ម្ចាស់បណ្ណទៅលើក្រុមហ៊ុន (បណ្ណហ៊ុន) តំណាងឱ្យសិទ្ធិទំនាក់ទំនងផ្នែកឥណទេយ្យរវាងម្ចាស់បណ្ណនោះ និងក្រុមហ៊ុន ឬរដ្ឋាភិបាល (ឧ. បណ្ណរតនាគារ) ឬតំណាងឱ្យសិទ្ធិផ្សេងៗទៀតទៅម្ចាស់បណ្ណនោះ។ ចំណែកឯ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន មូលបត្រ គឺសំដៅដល់មូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអនុលោមតាមច្បាប់។

**ទីផ្សារមូលបត្រ** (Securities Market) សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើ លក់ ផ្ទេរ ឬស្នើការទិញ លក់មូលបត្រ។

**នីតិបុគ្គលប្រតិស្រុត**(Permitted Entity) សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់បោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិផ្សេងទៀត។ នីតិបុគ្គលនេះ មិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ហិរញ្ញប្បទាន** (Financing) សំដៅដល់ការផ្តល់ប្រាក់កម្ចី។

**ប្រតិបត្តិការរក្សាទុកមូលបត្រ** (Securities Depository) បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថា ផ្តល់សេវាកម្មដូចខាងក្រោមនេះ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ ៖

ក. កាន់កាប់ចុះបញ្ជី សិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀត ដែលអតិថិជនតែងតាំង។

ខ. ទទួលរក្សាទុកនូវមូលបត្រ ឬឧបរណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀត ដែលអតិថិជនតែងតាំង។

គ. ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងៗទៀត ដែលអតិថិជនទិញនិងការផ្តល់សេវាកម្មដូចមានចែងក្នុងកថាខណ្ឌ (ក) និង (ខ)។

**ប្រតិបត្តិករជាត់ទាត់ និងទូទាត់មូលបត្រ** (Securities Clearance and Settlement Facility) គឺសំដៅដល់បុគ្គល ដែលផ្តល់នូវប្រព័ន្ធលទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រកាតព្វកិច្ច

ខ្លួនទៅវិញទៅមក ដោយការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។

**ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ** (Derivative Instrument) គឺជាកិច្ចសន្យាដែលផ្ដល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឱ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញ លក់ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថា បុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើសិទ្ធិនេះក៏ដោយ។

**ពាណិជ្ជករមូលបត្រអញ្ញត្រកម្ម** (Exempt Securities Dealer) បុគ្គលដែលធ្វើអាជីវកម្មមូលបត្រដោយមិនចាំបាច់បំពេញលក្ខខណ្ឌតាមលក្ខខណ្ឌនៃច្បាប់នេះ។ ពាណិជ្ជករមូលបត្រអញ្ញត្រកម្មនេះនឹងមានចែងដោយអនុក្រឹត្យ ឬប្រកាស។

**ប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម**(Exempt Securities Transaction) សំដៅដល់ប្រតិបត្តិការមូលបត្រដែលធ្វើដោយបុគ្គលជាក់លាក់ណាមួយ ឬដោយបុគ្គលផ្សេងទៀត ដើម្បីចុះឈ្មោះសុំទិញ ទិញបោះផ្សាយលក់ ឬផ្ទេរមូលបត្រដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់។

**អ្នកធ្វើបរិវិសកម្ម** (Subscriber) អ្នកចុះឈ្មោះសុំទិញមូលបត្រនៅពេញក្រុមហ៊ុនធ្វើសំណើលក់មូលបត្រជាសាធារណៈ។

**សញ្ច័យ** (Saving) ការសន្សំ។

**សន្ទនីយភាព** សំដៅដល់សមត្ថភាពក្នុងការផ្ដល់ទុនដើម្បីបង្កើនទ្រព្យសកម្មបំពេញកាតព្វកិច្ចទូទាត់បំណុលដែលបាន ឬមិនបានរំពឹងទុក និងលទ្ធភាពទូទាត់ ឬកាត់កងប៉ូស៊ីសិន (Position) ដោយមិនបង្កឱ្យមានការខាតបង់ធ្ងន់ធ្ងរ។ សន្ទនីយភាពអាចរងផលប៉ះពាល់ពីឧបករណ៍ហិរញ្ញវត្ថុទាំងក្នុង និងក្រៅតារាងតុល្យការ។

**ពិពិធកម្មវិនិយោគ** (Eng. Investment Diversification) សំដៅដល់ការវិនិយោគដែលមិនពឹងផ្អែកទៅលើតែឧបករណ៍ហិរញ្ញវត្ថុមួយប្រភេទ។

**សូចនករសេដ្ឋកិច្ច** គឺជាស្ថិតិសំខាន់ដែលបង្ហាញពីទិសដៅនៃសេដ្ឋកិច្ចសំខាន់ៗ ជំរុញឱ្យមានចលនាតម្លៃរូបិយប័ណ្ណបរទេស ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យមានភាពល្អប្រសើរនៃព្រឹត្តិការណ៍សេដ្ឋកិច្ចសកលដើម្បីអនុវត្តការវិភាគជាមូលដ្ឋានដែលអាចឱ្យឈ្មួញជួញដូរ Forex ធ្វើការសម្រេចចិត្ត។

# សេចក្តីផ្តើម

ជាការពិត វិស័យហិរញ្ញវត្ថុជាធាតុមួយយ៉ាងសំខាន់នៅក្នុងខឿនសេដ្ឋកិច្ចរបស់ប្រទេសមួយ។ ភាពរឹងមាំ និងរស់រវើកនៃវិស័យនេះ ជួយជម្រុញការអភិវឌ្ឍវិស័យឯកជន ព្រមទាំងធានាឱ្យមានកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាព។ ជាមួយនេះដែរទីផ្សារមូលបត្រជាប៉ូលមួយក្នុងចំណោមប៉ូលសំខាន់ៗនានានៃវិស័យហិរញ្ញវត្ថុ។ ទីផ្សារមូលបត្រមានវិធានស្មុកស្មាញប្រកបដោយជំនាញខ្ពស់ព្រមទាំងប្រទាក់ក្រឡាគ្នាជាមួយវិស័យពាក់ព័ន្ធជាច្រើននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសកល។ ដោយសារភាពសាំញ៉ាំនេះហើយដែលតម្រូវឱ្យមានការយល់ដឹង និងការចូលរួមឱ្យបានទូលំទូលាយពីគ្រប់ផ្នែកដែលពាក់ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេសគឺការយល់ដឹងលើបទប្បញ្ញត្តិ និងប្រតិបត្តិការនានាដែលនិយ័តករវិស័យហិរញ្ញវត្ថុបានដាក់ចេញ សម្រាប់ការគ្រប់គ្រងដំណើរការទីផ្សារមូលបត្រឱ្យមានភាពរឹងមាំ សុក្រឹត្យភាព តម្លាភាពនិងសង្គមភាពព្រមទាំងការត្រួតពិនិត្យនិងគ្រប់គ្រងប្រតិបត្តិការទីផ្សារមូលបត្រទាំងមូល។

ទន្ទឹមនឹងការរីកចម្រើននៅក្នុងវិស័យមូលបត្រ ថ្នាក់ដឹកនាំប្រទេសក៏បានរៀបចំ និងធ្វើការចងក្រងនូវបទប្បញ្ញត្តិនិងវិធានផ្សេងៗ ដើម្បីជាការកំណត់ព្រំដែននៃសិទ្ធិរបស់វិនិយោគិនដើម្បីជៀសវាងនូវបទល្មើសផ្សេងៗ ដែលនឹងកើតមានឡើងដោយសារតែអំពើមិនគប្បី អសីលធម៌ ការគេងចំណេញ ការបន្លំ ការបោកប្រាស់ជាដើម ដែលនាំឱ្យមានគុណវិបត្តិជាច្រើនដែលប៉ះពាល់ដល់ដំណើការនៃវិស័យមូលបត្រ មិនតែប៉ុណ្ណោះបទប្បញ្ញត្តិទាំងនោះក៏បានចែងពីទណ្ឌកម្ម និងធ្វើការផ្តន្ទាទោសទៅលើជនល្មើស ដើម្បីទប់ស្កាត់នូវអំពើល្មើសក្នុងគោលបំណងការពារផលប្រយោជន៍របស់សាធារណៈជនក៏ដូចជាការពារជនរងគ្រោះ និងការពារសង្គមពីបញ្ហាផ្សេងៗ ឬអាកប្បកិរិយាដែលផ្ទុយពីច្បាប់ដែលរួមមានដូចជាការប្រើប្រាស់ឧបាយកលក្នុងទីផ្សារការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ដែលនាំឱ្យយល់ខុស។

ជាការពិតច្បាប់ និងបទប្បញ្ញត្តិទាំងអស់គឺមិនត្រឹមតែយកទៅអនុវត្តចំពោះការប្រើប្រាស់ឧបាយកលក្នុងទីផ្សារដែលធ្វើឱ្យតម្លៃមូលបត្រ ឬភាគហ៊ុនប្រែប្រួលប៉ុណ្ណោះទេ ប៉ុន្តែត្រូវទប់ស្កាត់ផងដែរនូវការជួញដូរមូលបត្រ ឬភាគហ៊ុនទាំងឡាយណាដែលប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដែលមិនទាន់បានផ្សព្វផ្សាយជាសាធារណៈ ឬធ្វើសេចក្តីថ្លែង មិនត្រឹមត្រូវនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬក៏ស្ថាប័នពាក់ព័ន្ធដ៏ទៃទៀតក្នុងការបំភ័នសាធារណជន ឬអ្នកវិនិយោគិនក្នុងវិស័យមូលបត្រឱ្យមានការយល់ខុស។ ជាមួយគ្នានេះដែរ ច្បាប់និងបទប្បញ្ញត្តិស្តីពីមូលបត្រត្រូវចែងលម្អិតអំពីប្រភេទនានានៃទណ្ឌកម្មរបស់និយ័តករមូលបត្រនៃប្រទេសមួយ ប្រឆាំង

នឹងជនទាំងឡាយណាដែលរំលោភបំពាននឹងការហាមឃាត់នានាដែលច្បាប់បានដាក់ចេញ ព្រមទាំងចែងអំពីសំណងរដ្ឋប្បវេណីចំពោះជនទាំងឡាយណា ដែលទទួលរងប៉ះពាល់ដោយសកម្មភាពរំលោភបំពានច្បាប់នានានោះ។ លើសពីនេះតុលាការអាចបង្កើតចំនួននៃសំណងរដ្ឋប្បវេណី ដែលមានចែងដោយច្បាប់ និងបទប្បញ្ញត្តិនៅក្នុងខណៈពេលដែលជនល្មើសបានប្រព្រឹត្តបទល្មើសមិនរាងចាល។

ដូច្នេះ វាមានសារៈសំខាន់ណាស់ ដែលយើងត្រូវយល់ដឹងពីបញ្ហាមូលបត្រថា តើវិស័យមូលបត្រមានសាវតានៃការកកើតយ៉ាងដូចម្តេច? ហើយតើការជួញដូរមូលបត្រ និងប្រព្រឹត្តិទៅយ៉ាងដូចម្តេច? តើបទល្មើសពាក់ព័ន្ធ និងការជួញដូរមូលបត្រមានអ្វីខ្លះ? នឹងការប្រព្រឹត្តិទៅយ៉ាងដូចម្តេច? ហើយតើបុគ្គល ដែលបានប្រព្រឹត្តនូវបទល្មើសត្រូវទទួលរងទណ្ឌកម្មយ៉ាងណានោះក្នុងបរិបទនៃច្បាប់របស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក?

ប្រធានបទស្តីពី «បទល្មើសពាក់ព័ន្ធ នឹងការជួញដូរមូលបត្រ ដោយតាមក្នុងបរិបទនៃច្បាប់កម្ពុជា និងសហរដ្ឋអាមេរិក» គឺមានគោលបំណងសំខាន់ក្នុងការរួមចំណែកផ្តល់នូវចំណេះដឹង ដល់ប្រជាជនកម្ពុជាក៏ដូចជាសិស្សានុសិស្ស ឬនិស្សិត ដើម្បីជ្រួលជ្រាបអោយកាន់តែទូលំទូលាយដល់និសិត្សក៏ដូចជាប្រជាជនទូទៅ នឹងបុគ្គលដែលពាក់ព័ន្ធផងដែរ ហើយការចូលរួមក្នុងវិស័យមូលបត្រជាប្រយោជន៍ក្នុងការសិក្សា និងស្វែងយល់នូវចំណេះដឹងអំពីសាវតា នៃប្រភេទបទល្មើសជួញដូរ ក៏ដូចជាទណ្ឌកម្មចំពោះបុគ្គលដែលបានប្រព្រឹត្តល្មើសក្នុងវិស័យនេះ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមានរបស់កម្ពុជា និងសហរដ្ឋអាមេរិក។

ដោយសារតែទំហំ នៃកិច្ចការមានដែនកំណត់ ដូចនេះកិច្ចការស្រាវជ្រាវនេះនឹងផ្តោតសំខាន់លើសាវតានៃការកកើតទីផ្សារមូលបត្រសកល និងប្រវត្តិនៃការកកើតនៅក្នុងប្រទេសកម្ពុជា និងបទល្មើសពាក់ព័ន្ធ នឹងការជួញដូរមូលបត្រនៅក្នុងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិច។ ហេតុដូច្នេះ តាំងពីដើមដល់ចប់ ការស្រាវជ្រាវ និងការតាក់តែងខ្លឹមសារប្រធានបទ គឺពឹងផ្អែកជាចម្បងទៅលើការប្រមូលឯកសារ ទិន្នន័យជាស្នូល ដែលទាក់ទងភាសាខ្មែរ និងភាសាបរទេស ពីប្រភពសំខាន់ៗ ដូចជាការទាញយកពីគេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា គេហទំព័ររបស់គណៈកម្មការមូលបត្រសហរដ្ឋអាមេរិក និងឯកសារដែលទទួលបានពីសាស្ត្រាចារ្យណែនាំផ្ទាល់។

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអាន និងការសិក្សាស្វែងយល់អំពីប្រធាបទ កិច្ចការស្រាវជ្រាវត្រូវបានបែងចែកជាពីជំពូកធំៗៈ ដែលនៅក្នុងជំពូកទី១ គឺរៀបរាប់អំពី សាវតា និងការជួញដូរមូលបត្រនៅប្រទេសកម្ពុជា និងជំពូកទី២ បកស្រាយអំពី បទល្មើស និងទណ្ឌកម្មចំពោះការប្រព្រឹត្តបទល្មើសក្នុងវិស័យមូលបត្រ។

# ជំពូកទី១
# សញ្ញាណនៃទីផ្សារមូលបត្រ

ទីផ្សារ ជាសញ្ញាណផ្ទាល់របស់អ្នកសេដ្ឋកិច្ចទោះបីជាសញ្ញាណនេះត្រូវបានប្រើជាញឹកញាប់ដោយអ្នកច្បាប់ក៏ដោយ។ តាមន័យសេដ្ឋកិច្ច ទីផ្សារគឺជាកន្លែងជួបគ្នារវាងតម្រូវការ និងការផ្គត់ផ្គង់។ កម្មវត្ថុនៃតម្រូវការ និងការផ្គត់ផ្គង់អាចជាទំនិញ ឬសេវាកម្ម។ ដូចគ្នាដែរ សម្រាប់ទីផ្សារមូលបត្រយើងអាចផ្តល់និយមន័យបានយ៉ាងសាមញ្ញថា ជាកន្លែងជួបគ្នារវាងតម្រូវការនិងការផ្គត់ផ្គង់មូលបត្រ។ កម្មវត្ថុនៃតម្រូវការ និងការផ្គត់ផ្គង់នៅលើទីផ្សារមូលបត្រគឺមូលបត្រ។ ច្បាប់ប្រទេសខ្លះមិនបានកំណត់អំពីនិយមន័យទីផ្សារមូលបត្រអោយបានច្បាស់លាស់នោះទេ ដោយសារតែការវិវឌ្ឍន៍យ៉ាងលឿននៃវិស័យមូលបត្រនេះ។ នៅក្នុងច្បាប់ខ្មែរ និយមន័យនេះ ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីមូលបត្រមហាជននិងនៅក្នុងសហរដ្ឋអាមេរិចត្រូវបានកំណត់នៅក្នុងSecurities Exchange Act1934។

ការបង្កើតឱ្យមានទីផ្សារមូលបត្រ គឺអាស្រ័យទៅលើគោលនយោបាយ និងការដឹកនាំពោលគឺចក្ខុវិស័យសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ។ វិស័យមូលបត្របានចាប់បដិសន្ធិឡើងទើបតែប៉ុន្មានទសវត្សចុងក្រោយនេះ គឺជាវិស័យមួយដែលផ្តល់នូវសេវាកម្មហិរញ្ញវត្ថុ ទាំងការពង្រីកមធ្យោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងការធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុរបស់គ្រប់ បណ្តាប្រទេសនៅលើពិភពលោកមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្តល់នូវជម្រើសថ្មីមួយទៀតក្នុងការធ្វើហិរញ្ញប្បទានដោយផ្ទាល់ដល់គម្រោងវិនិយោគនានា ដែលជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច។ ខាងក្រោមនេះ យើងនឹងធ្វើការបកស្រាយ អំពីប្រវត្តិនៃការកកើតទីផ្សារមូលបត្រ ទាំងទីផ្សារមូលបត្រសកល និងទីផ្សារមូលបត្រកម្ពុជា (ផ្នែកទី១) បន្ទាប់មក យើងនឹងធ្វើការស្វែងយល់កាន់តែស៊ីជម្រៅអំពីការជួញដូរមូលបត្រក្នុងទីផ្សារមូលបត្រកម្ពុជា (ផ្នែកទី២)។

## កថាខណ្ឌទី១៖ ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ

ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ យើងនឹងសិក្សាទៅលើសាវតានៃទីផ្សារមូលបត្រសកល យើងនិយាយជារួម និងសាវតានៃទីផ្សារមូលបត្រកម្ពុជាយើងនិយាយដោយឡែក។

### ក. សាវតានៃទីផ្សារមូលបត្រសកល

ទស្សនៈសម័យទំនើប នៃការបង្កើតទីផ្សារមូលបត្រ (Securities Exchange) ឬដែលហៅម៉្យាងទៀតថា ទីផ្សារភាគហ៊ុន (Stock Exchange) បានចាប់ផ្តើមតាំងពីចុងសតវត្សទី១៦។ ទីផ្សារភាគហ៊ុនត្រូវបានបង្កើតឡើងនៅបណ្តាលប្រទេសក្នុងទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដ៏ទៃទៀតដែលមានដូចជា ហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ ខណៈ

ពេលដែលឈ្មួញធំៗ នៅទ្វីបអឺរ៉ុបមានបំណងចាប់ផ្តើមអាជីវកម្មទំហំធំ ដែលទាមទារឱ្យមានចំនួនទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់ មានប្រាក់ច្រើនសន្ធឹកសន្ធាប់សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំបានតែម្នាក់ឯងនោះទេ។ ជាលទ្ធផល វិនិយោគិនបានយកប្រាក់សន្សំរបស់ពួកគេទៅធ្វើការដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងជាសហាកម្មសិទ្ធិជាមួយនឹ ងចំណែកភាគហ៊ុនរបស់ខ្លួននៅក្នុងអាជីវកម្ម ឬទម្រង់រួមទុន។ ក្រុមហ៊ុនរួមទុន ដែលមានកំណត់នៅប្រទេសហូឡង់ បានក្លាយទៅជាគំរូអាជីវកម្មមួយ សម្រាប់អាជីវកម្មដទៃទៀត ដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។

ទីផ្សារភាគហ៊ុនកើតឡើងដំបូងប្រហែលនៅជានៅពេលដែលភាគហ៊ុនរបស់ ក្រុមហ៊ុន ឌឺ ឌាចហ៍ អ៊ីសឥណ្ឌា The Dutch East India Co. បានបង្កើតនៅក្នុងឆ្នាំ ១៦០២ ហើយក្រុមហ៊ុនដំបូងគេដែលបានបោះផ្សាយក្រដាសតំណាងភាគហ៊ុនជាលើកដំបូង។ ភាគលាភនៃផលចំណេញរបស់ក្រុមហ៊ុនត្រូវបានផ្តល់ជូនដល់អ្នកទិញដោយអាស្រ័យទៅនឹងភាគហ៊ុនដែលមាន។ ភាគហ៊ុននេះត្រូវបានគេជួញដូរជាបន្តបន្ទាប់ រហូតលេចចេញការជួញដូរនៅលើ ក្រុមហ៊ុនផ្សារអាំស្ទែដាំ (Amsterdam Exchange)។ ហើយក្រោយមក ឧបករណ៍ហិរញ្ញសំបូរបែបផ្សេងៗត្រូវបានធ្វើការទិញ-លក់នៅលើទីផ្សារអាំស្ទែដាំ (Amsterdam Market)នេះ។

ក្រុមហ៊ុនផ្សារភាគហ៊ុន (Stock Exchange) នៅក្នុងទីក្រុងញូយ៉កត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៧៩២ នៅពេលដែលឈ្មួញជើងសា Brokers ចំនួន ២៤នាក់បានសម្រេចចិត្តយកកំរៃជើងសានៅពេលដែលពួកគេដើរតួជាភ្នាក់ងារ សម្រាប់មនុស្សផ្សេងៗទៀតក្នុងការធ្វើជំនួញ។ ពួកគេបានធ្វើការជួញដូរជាច្រើននៅក្រោមដើមឈើមួយនៅវ៉លស្ទ្រីត Wall Street ជាប្រចាំទើបបង្កើតឱ្យមានទីផ្សារមួយឈ្មោះថា វ៉លស្ទ្រីតមកដល់ពេលបច្ចុប្បន្ននេះនៅសហរដ្ឋអាមេរិក។ ក្រោយមកគេក៏បានបង្កើតឧបករណ៍ដែលអាចធ្វើការជួញដូរមូលបត្របាន ត្រូវមានការអនុញ្ញាតឱ្យអ្នកភាគហ៊ុនិកមានភាពងាយស្រួលក្នុងការទិញ-លក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួនជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និងវិនិយោគិនដទៃទៀត។ គំនិតនេះបានទទួលជោគជ័យដោយការលក់ភាគហ៊ុនបានរីករាលដាលដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀតដូចជា ប្រទេសព័រទុយហ្គាល អេស្ប៉ាញនិងបារាំង។ នៅទីបំផុតការអនុវត្តគំនិតនេះក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។ ឧស្សាហកម្មដ៏ទៃទៀត ក្នុងអំឡុងពេលបដិវត្តន៍ឧស្សាហកម្ម បានចាប់ផ្តើមប្រើការលក់ភាគហ៊ុនជាវិធីប្រមូលមូលធនសម្រាប់ធ្វើអាជីវកម្ម។ ការហូរចូលនៃតម្លៃមូលធននេះបានបន្តឱ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់ នៃឧស្សាហកម្មសម័យទំនើប។ ការធ្វើអោយមានការកើនឡើងនៃចំនួនបរិមាណ នៃការជួញដូរភាគហ៊ុនបានជំរុញឱ្យមានការបង្កើតជាទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។

ជាលទ្ធផលពាណិជ្ជករភាគហ៊ុនបានសម្រេចចិត្តទៅជួបគ្នា នៅក្នុងហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមកហាងកាហ្វេនោះត្រូវបានពាណិជ្ជករ ភាគហ៊ុនទិញយក ហើយបានប្រែឈ្មោះក្លាយជាទីផ្សារភាគហ៊ុនដែលបានការរៀបចំនិងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ១៧៧៣។ ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេនៅលើពិភព-លោក។ គំនិតនៃការរៀបចំបែបនេះក៏បានហូរចូលទៅក្នុងសហរដ្ឋអាមេរិក ហើយចាប់ផ្ដើមនៅទីក្រុង Philadelphia ក្នុងឆ្នាំ១៧៩០។

ទីផ្សារមូលធនសកលបានផ្ដល់អត្ថប្រយោជន៍ជាច្រើនរួមមាន[1]៖

### ១. ការទទួលប្រាក់ចំណេញពីការជួញដូរភាគហ៊ុន និងទទួលភាគលាភ

ប្រយោជន៍ចម្បងពីការវិនិយោគក្នុង ទីផ្សារភាគហ៊ុន គឺជាឱកាសទទួលបានប្រាក់ចំណេញ។ ទីផ្សារភាគហ៊ុនមានទំនោរកើនឡើងនូវតម្លៃ បើទោះបីជាភាគហ៊ុននីមួយៗកើន ឬធ្លាក់ថ្លៃជារៀងរាល់ថ្ងៃក៏ដោយ។ ការវិនិយោគជាមួយក្រុមហ៊ុនដែលមានស្ថេរភាព និងមានសក្ដានុពល វាអាចនឹងធ្វើឱ្យអ្នកវិនិយោគិនទទួលបានប្រាក់ចំណេញដោយទិញនៅពេលថ្លៃទាប ហើយលក់ទៅវិញនៅពេលភាគហ៊ុនឡើងថ្លៃ។ មួយវិញទៀត ការវិនិយោគភាគហ៊ុនច្រើនផ្សេងៗគ្នា នឹងជួយបង្កើនទ្រព្យសម្បត្តិរបស់លោកអ្នក និងកាន់តែកាត់បន្ថយហានិភ័យវិនិយោគ តាមរយៈឥទ្ធិពលកំណើនវិស័យផ្សេងៗក្នុងសេដ្ឋកិច្ច បើទោះបីជាថ្លៃភាគហ៊ុនខ្លះដែលលោកអ្នកបានវិនិយោគធ្លាក់ថ្លៃក៏ដោយ។ ភាគហ៊ុនជាច្រើនបានផ្ដល់ឱ្យលោកអ្នកនូវប្រាក់ចំណូលក្នុងទម្រង់ជាភាគលាភ ដែលជាចំណែកនៃប្រាក់ចំណេញដែលក្រុមហ៊ុនរកបាន ហើយបង់ចំណែកនោះជូនវិនិយោគិនប្រចាំឆ្នាំ។ វិនិយោគិនអាចប្រើប្រាស់ភាគលាភ សម្រាប់ទុកចាយវាយនៅពេលចូលនិវត្ត ឬយកទៅធ្វើការវិនិយោគបន្ត។

### ២. ការទិញភាគហ៊ុនជម្រើសសម្រាប់ការសន្សំ

នៅក្នុងប្រទេសដែលបានបង្កើតទីផ្សារភាគហ៊ុនច្រើនឆ្នាំ វិនិយោគិនជាច្រើនជ្រើសរើសយកភាគហ៊ុនជំនួសឱ្យការវិនិយោគជម្រើសផ្សេងទៀតដូចជា សញ្ញាបណ្ណ(មូលបត្របំណុល) ឬក៏អចលនទ្រព្យ ។ល។ ដោយសារតែភាគហ៊ុន ជាជម្រើសសម្រាប់ការវិនិយោគដ៏ល្អមួយ ដែលអាចបង្កើនប្រាក់ក្នុងអត្រាចំណូលខ្ពស់ជាងជម្រើសវិនិយោគផ្សេងៗទៀតក្នុងរយៈពេលវែង។ យ៉ាងណាមិញវិនិយោគិនក្នុងទីផ្សារភាគហ៊ុន ក៏ត្រូវប្រឈមនឹងហានិភ័យខ្លះផងដែរ ក៏ប៉ុន្តែវិនិយោគិននៅមានពេលវេលា និងឱកាសល្អៗច្រើនទៀត ដើម្បីវិនិយោគក្នុងទីផ្សារភាគហ៊ុន។ បើយើងក្រឡេកមើល

[1] ព្រឹត្តបត្រមូលបត្ររបស់គណៈកម្មការមូលបត្រកម្ពុជាផ្សាយចេញលេខ២ ខែមករា ឆ្នាំ២០១៧ ស្ដីពីអត្ថប្រយោជន៍សម្រាប់ក្រុមហ៊ុនវិនិយោគិនភាគហ៊ុន

ករណីសហរដ្ឋអាមេរិក តម្លៃភាគហ៊ុនបានកើនឡើងប្រហែល ១០ ភាគរយ ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលមួយសតវត្សចុងក្រោយនេះ។ វិនិយោគិនភាគហ៊ុននៅសហរដ្ឋអាមេរិកអាចរកចំណូលបានកាន់តែច្រើនជាងវិនិយោគិនមូលបត្របំណុល ឬអចលនទ្រព្យក្នុងរយៈពេលវែង បើទោះបីជាទីផ្សារភាគហ៊ុនមានការប្រែប្រួលថ្លៃជារៀងរាល់ថ្ងៃក៏ដោយ។ ការវិនិយោគភាគហ៊ុនមានសារៈសំខាន់ណាស់ការសន្សំនិងវិនិយោគ សម្រាប់អនាគតហើយអ្នកជំនាញផ្នែកវិនិយោគភាគច្រើនក្នុងពិភពលោកសុទ្ធតែយល់ស្របថា ការវិនិយោគភាគហ៊ុនជាជម្រើសល្អបំផុតសម្រាប់ការសន្សំ និងវិនិយោគសម្រាប់ការចូលនិវត្ត។ ជាទូទៅ ថ្លៃភាគហ៊ុនប្រែប្រួលជារៀងរាល់ថ្ងៃ។ ការប្រែប្រួលនេះអាចនិយាយបានយ៉ាងសាមញ្ញថា ដោយសារកម្លាំងនៃផ្គត់ផ្គង់និងតម្រូវការនៅលើទីផ្សារ។ បានសេចក្តីថា ប្រសិនបើមានការផ្គត់ផ្គង់(ការលក់) ច្រើនជាងតម្រូវការ (ការទិញ) នោះថ្លៃមានទំនោរធ្លាក់ចុះ។

## ៣. ការធ្វើពិពិធកម្មដោយវិនិយោគភាគហ៊ុនអាចជួយកាត់បន្ថយហានិភ័យពីការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត

ការធ្វើពិពិធកម្ម (Diversification) គឺជាបច្ចេកទេសមួយដែលអាចជួយកាត់បន្ថយហានិភ័យក្នុងការវិនិយោគ ដោយការបែងចែកទឹកប្រាក់វិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗគ្នា ដោយមិនប្រើប្រាស់ទឹកប្រាក់ទាំងអស់ វិនិយោគលើឧបករណ៍តែមួយនោះទេ។ គោលបំណងនៃការធ្វើបែបនេះគឺដើម្បីបង្កើនឱកាសទទួលបានប្រាក់ចំណេញពីការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុច្រើនផ្សេងគ្នា និងអាចចៀសផុតពីការក្ស័យធនផងដែរ។

សម្រាប់វិនិយោគិន ដែលបានដាក់ប្រាក់ចូលទៅក្នុងការវិនិយោគឧបករណ៍ហិរញ្ញវត្ថុផ្សេងៗគ្នាភាគហ៊ុនមានតួនាទីផ្តល់នូវឥទ្ធិពលដល់ការធ្វើពិពិធកម្ម។ ជាទូទៅការវិនិយោគមួយដែលអាចផ្តល់ផលចំណេញច្រើន គឺតែងតែមានហានិភ័យខ្ពស់។ ភាគហ៊ុនអាចជួយបង្កើនប្រាក់ចំណូល ប៉ុន្តែវាក៏អាចនាំមកនូវហានិភ័យផងដែរ។នៅពេលរៀបចំគម្រោងវិនិយោគ វិនិយោគិនតែងជ្រើសរើសវិនិយោគទ្រព្យសកម្មផ្សេងៗគ្នាដើម្បីកាត់បន្ថយហានិភ័យ។ ការធ្វើពិពិធកម្មដោយវិនិយោគភាគហ៊ុនអាចជួយកាត់បន្ថយការខាតបង់ និងចៀសវាងការវិនិយោគដែលមានភាពអភិរក្សពេក។

## ៤. ភាគហ៊ុនដែលមានសន្ទនីយភាពខ្ពស់ជាងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត

ភាគហ៊ុន ត្រូវបានជួញដូរនៅក្នុងទីផ្សារភាគហ៊ុន ដែលបានអនុញ្ញាតឱ្យវិនិយោគិន ទិញ-លក់ភាគហ៊ុនបានយ៉ាងរហ័យតាមតម្លៃទីផ្សារ។ វិនិយោគិន និយមជួញដូរភាគហ៊ុននៅជុំវិញពិភពលោក ដោយសារទីផ្សារភាគហ៊ុនផ្តល់នូវសន្ទនីយភាពខ្ពស់ និងការធានាទៅកាន់វិនិយោគិនថា ការវិនិយោគ

ភាគហ៊ុនរបស់ពួកគេអាចត្រូវបានប្តូរជាសាច់ប្រាក់វិញ បានយ៉ាងឆាប់រហ័សតាមតម្លៃទីផ្សារគ្រប់ពេលដែលគេត្រូវការ ដោយមានផលប៉ះពាល់តិចតួចបំផុតលើតម្លៃដែលទទួលបាន។

### ៥. ទីផ្សារភាគហ៊ុនជាឧបករណ៍វាស់ស្ទង់សេដ្ឋកិច្ច

ទីផ្សារភាគហ៊ុន ជាឧបករណ៍ដែលអាចជឿទុកចិត្តបាន ក្នុងការវាស់ស្ទង់ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសជាច្រើនទូទាំងពិភពលោកមានដូចជាសហរដ្ឋអាមេរិក អង់គ្លេស ចិន ជប៉ុន កូរ៉េ សិង្ហបុរី ថៃ ជាដើម។ រាល់ព័ត៌មានរំជើបរំជួល និងការផ្លាស់ប្តូរធំៗនៅក្នុងប្រទេសនឹងត្រូវបានឆ្លុះបញ្ចាំងតាមរយៈតម្លៃភាគហ៊ុន និងបង្ហាញពីការរីកចម្រើនឬធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសមួយ។ ទីផ្សារភាគហ៊ុន គឺត្រូវបានគេចាត់ទុកជាជីពចរនៃសេដ្ឋកិច្ច ឬជាកញ្ចក់ដែលឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ត្បិតតែទីផ្សារភាគហ៊ុនជាសូចនករសេដ្ឋកិច្ចដ៏សំខាន់ ដែលជាជំនួយសម្រាប់វិនិយោគិនក្នុងការរៀបចំ និងសម្រេចចិត្តវិនិយោគឱ្យបានត្រឹមត្រូវហើយទីផ្សារភាគហ៊ុនក៏អាចជួយពង្រីកចំណេះដឹងរបស់ប្រជាជនអំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសផងដែរ។

### ៦. រួមចំណែកទទួលបានភាពជាម្ចាស់កម្មសិទ្ធិក្នុងក្រុមហ៊ុនជោគជ័យ

ជាទូទៅ វិនិយោគិនភាគហ៊ុននិយមវិនិយោគជាមួយក្រុមហ៊ុនដែលជោគជ័យនិងរកបានចំណូលច្រើន។ ការទិញភាគហ៊ុន គឺមានន័យថា លោកអ្នកទទួលបានចំណែកភាពជាម្ចាស់កម្មសិទ្ធិពីក្រុមហ៊ុនដែលបានលក់ភាគហ៊ុនហើយលោកអ្នកក៏មានសិទ្ធិទទួលនូវចំណែកនៃប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបានផងដែរ។ ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោតនឹងមានចំណែកចូលរួមសម្រេចចិត្តក្នុងអាជីវកម្មរបស់ក្រុមហ៊ុន តាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនបានកាន់កាប់។

### ៧. ការវិនិយោគភាគហ៊ុនជាការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច

នៅក្នុងទីផ្សារភាគហ៊ុន មានភាគហ៊ុនរបស់ក្រុមហ៊ុនជាច្រើនដែលត្រូវបានជួញដូរ។ ដំណើរការនៃការទិញ-លក់ទាំងនេះអាចជួយក្នុងការវិនិយោគលើគម្រោងវិនិយោគ ដែលមានផលិតភាពខ្ពស់ដែលអាចឈានទៅដល់ការបង្កើនមូលធននិងនាំឱ្យមានកំណើនសេដ្ឋកិច្ច។ ការវិនិយោគភាគហ៊ុនរបស់វិនិយោគិនមិនគ្រាន់តែជាការវិនិយោគដើម្បីប្រាក់ចំណេញប៉ុណ្ណោះទេ ក៏ប៉ុន្តែទឹកប្រាក់ទាំងនោះ អាចជួយក្រុមហ៊ុនដែលបោះផ្សាយលក់ភាគហ៊ុន ឱ្យទទួលបានដើមទុនបន្ថែមសម្រាប់ពង្រីងអាជីវកម្ម និងមានសមត្ថភាពជួលបុគ្គលិកធ្វើការបន្ថែម។ ក្នុងន័យនេះ ការវិនិយោគភាគហ៊ុនគឺជាការចូលរួមចំណែកជួយបង្កើតការងារនិងជួយដល់កំណើនសេដ្ឋកិច្ចជាតិ។ ជាការពិតណាស់ ដោយសារទីផ្សារភាគហ៊ុន ដែលជាផ្នែកដ៏សំខាន់មួយនៃទីផ្សារហិរញ្ញវត្ថុ មានអត្ថប្រយោជន៍ទីដល់

ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រោះវិស័យនានាក៏មានការរីកចម្រើន ដោយសារភាគហ៊ុនិកដើមអាចលក់ភាគហ៊ុនរបស់ខ្លួនក្នុងថ្លៃខ្ពស់ នឹងយកទៅវិនិយោគក្នុងវិស័យថ្មី។

## ខ. សាខតានៃទីផ្សារមូលបត្រកម្ពុជា

### ១. ប្រវត្តិទីផ្សារមូលបត្រកម្ពុជា

ការបង្កើតទីផ្សារមូលបត្រនៅកម្ពុជា [2] ត្រូវបានរៀបចំឡើងទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០០៦ ដល់ ២០១៥ របស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខដឹកនាំ។ តាមពិត គំនិតផ្តួចផ្តើមនៃការបង្កើតទីផ្សារមូលបត្រនៅកម្ពុជា តាំងពីឆ្នាំ១៩៩៥មកម្លេះ ប៉ុន្តែដោយសារតែប្រព័ន្ធធនាគារមិនទាន់មានភាពរឹងមាំ រដ្ឋាភិបាលបានសម្រេចពន្យាពេលបង្កើតទីផ្សារនេះ ប៉ុន្តែនៅតែចាត់ទុកថាជាបញ្ហាអាទិភាព។ នៅឆ្នាំ១៩៩៨ កម្ពុជាចាប់ផ្តើមធ្វើកំណែទម្រង់ប្រព័ន្ធធនាគារដោយបានធ្វើឱ្យប្រព័ន្ធធនាគារនៅកម្ពុជាមានភាពរឹងមាំរីកចម្រើន និងអភិវឌ្ឍន៍ជាលំដាប់។ ក្រោយមកនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ គម្រោងទីផ្សារមូលបត្រនៅកម្ពុជាបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មការមូលត្រកម្ពុជាហៅកាត់ថា **គ.ម.ក** ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន បានអនុម័តរួច។ **គ.ម.ក** មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមជាតិ តាមរយៈធ្វើការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រដើម្បីឆ្លើយតបទៅនឹងតម្រូវការហរិញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។ **គ.ម.ក** បានបង្កើតបទប្បញ្ញត្តិជាច្រើន ដើម្បីគ្រប់គ្រង រៀបចំ និងដំណើរការទីផ្សារមូលបត្រនៅកម្ពុជា។

ផ្សារមូលបត្រកម្ពុជា ត្រូវគ្រប់គ្រងដោយស្ថាប័នមួយដែលមានឈ្មោះថា គណៈកម្មការមូលបត្រកម្ពុជា ក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

ដើម្បីអាចគ្រប់គ្រងវិស័យមូលបត្រកម្ពុជាឱ្យមានប្រសិទ្ធិភាពគណៈកម្មការមូលបត្រកម្ពុជាមានបេសកកម្មសំខាន់ៗ ដែលត្រូវបំពេញដូចខាងក្រោម៖

- បង្កើតនិងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការការពារសិទ្ធិស្របច្បាប់ របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។

[2] http://insokun.wordpress.com

- ➢ លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធិភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ។
- ➢ ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ➢ ជំរុញឱ្យមានការធ្វើការវិនិយោគទុនពីបរទេស និងមានការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ➢ ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្ម និងសហគ្រាសសាធារណៈផ្សេងៗទៀតដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ➢ ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ជារឿងសំខាន់ណាស់សម្រាប់ម្ចាស់អាជីវកម្មត្រូវត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីដឹងពីការចំណាយ និងចំណូលរបស់អាជីវកម្មរបស់អ្នក។ បើទោះអាជីវកម្មរបស់អ្នកមានប្រព័ន្ធគ្រប់គ្រងចំណូលដោយ ក៏អ្នកមិនអាចប្រហែលបានដែរ។

## ២. បច្ចុប្បន្នភាពនៃទីផ្សារមូលបត្រ[3]

### ២.១ ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ[4]

ផលិតផលទ្រព្យកម្មសិទ្ធិ គឺជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈដើម្បីគៀងគរមូលនិធិពីសាធារណៈជន។ វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឱ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិកគឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួលបាននូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនចុះបញ្ជី ជាធម្មតាអាចវាយតម្លៃបាន តាមរយៈភាគលាភដែលភាគហ៊ុនិកបានទទួលនិងតាមរយៈថ្លៃភាគហ៊ុនដែលបានដាក់ថ្លៃនៅលើទីផ្សារ។ មានមូលបត្រ២ប្រភេទ ដែលអាចដាក់ជួញដូរ នៅលើផ្សារមូលបត្រកម្ពុជា (**ផ.ម.ក.**)៖

១.ភាគហ៊ុនធម្មតា

ភាគហ៊ុនធម្មតា គឺជាឧបករណ៍កម្មសិទ្ធិ អ្នកដែលទិញវានឹងក្លាយជាម្ចាស់មួយផ្នែក ឬក្លាយជាភាគហ៊ុនិកនៃក្រុមហ៊ុនបោះផ្សាយមូលបត្រ។ មូលបត្រកម្មសិទ្ធិនេះត្រូវបាន ហៅថា ភាគហ៊ុនធម្មតា ព្រោះដើម្បីផ្តាច់លក្ខណៈដាច់ដោយឡែក ដែលមានភាពខុសគ្នា ជាមួយនឹងភាគហ៊ុនបុរិមា។ ភាគ

[3] www.secc.gov.kh
[4] www.secc.gov.kh

ហ៊ុននេះ ដែលមានការលើកទឹកចិត្តដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈ ភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។ ភាគហ៊ុនធម្មតា មានសិទ្ធិបោះឆ្នោតសម្រេចរាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន។

២.ភាគហ៊ុនបុរិមា

ភាគហ៊ុនបុរិមា ជាមូលបត្រកម្មសិទ្ធិពិសេសមួយ ដែលមានលក្ខណៈទាំងពីរ គឺលក្ខណៈជាឧបករណ៍កម្មសិទ្ធិផង និងឧបករណ៍បំណុលផង។ ជាទូទៅវាត្រូវបានគេហៅថា ឧបករណ៍កូនកាត់។ មូលបត្រកម្មសិទ្ធិនេះមានឈ្មោះថា ភាគហ៊ុនបុរិមា ព្រោះម្ចាស់ភាគហ៊ុននេះនឹងទទួលបានការទូទាត់ភាគលាភមុនម្ចាស់ ភាគហ៊ុនធម្មតា ប៉ុន្តែជាទូទៅម្ចាស់ភាគហ៊ុននេះពុំមានសិទ្ធិក្នុងការបោះឆ្នោតឡើយ។

បច្ចុប្បន្ននៅប្រទេសកម្ពុជាមានក្រុមហ៊ុនមូលបត្រកម្មសិទ្ធិ ៥ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រ មានដូចជា[5]៖

❖ ក្រុមហ៊ុនកំពង់ផែស្វ័យក្រុងព្រះសីហនុ ហៅកាត់ **ក.ស.ស** បង្កើតតាំងពីឆ្នាំ១៩៥៦ បានចុះបញ្ជីថ្ងៃទី០៨ មិថុនា ឆ្នាំ២០១៧ និងមានចំនួនភាគហ៊ុនចុះបញ្ជី ៨៥.៧៧១.៩៦៧។ ជាក្រុមហ៊ុនរដ្ឋដែលបានបង្កើតឡើងធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើការងារកណ្ដធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភារដល់នាវា លើកដាក់ ផ្ទេរ ផ្ទុកទំនិញនៅឃ្លាំង និងទីលាន ព្រមទាំងដឹកជញ្ជូនទំនិញ។ ការនាំចេញចូលជាទីផ្សារមួយដែលមានអោយសេដ្ឋកិច្ចរបស់កម្ពុជាមានភាពរីកចម្រើន។

❖ ក្រុមហ៊ុនភ្នំពេញអុីហ្សិត ភីអិលស៊ី ដែលមាននិមិត្តសញ្ញា ភីភីអេសភី បានបង្កើតនៅឆ្នាំ២០០៦ ហើយបានចុះបញ្ជីនៅថ្ងៃទី១៩ តុលា ឆ្នាំ២០១៨ ដែលមានភាគចុះបញ្ជីសរុប ៧១.៨៧៥.០០០។ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត និងសម្រាប់ផ្គត់ផ្គង់នឹងចែកចាយទឹកស្អាត សេវាជូល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាលប្រព្រឹត្តិកម្មទឹកស្អុយ និងសេវាកម្មដ៏ទៃទៀត។

❖ ក្រុមហ៊ុនកំពង់ផែស្វាយយ័ត ដែលមាននិមិត្តសញ្ញា **ក.ស.ភ** បង្កើតនៅឆ្នាំ១៩០៤ ហើយបានចុះបញ្ជីនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ដែលមានភាគហ៊ុនចុះបញ្ជី ២០.៦៨៨.៣៦៥។

❖ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អុីធើណេសសិនណល (ខេមបូឌា) ភីអិលស៊ី ដែលមាននិមិត្តសញ្ញា **ហាធអ** បង្កើតនៅឆ្នាំ២០១៧ បានចុះបញ្ជីនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ និងមានភាគហ៊ុនចុះបញ្ជីចំនួន

[5] www.secc.gov.kh

៥០.០០០.០០០។ គឺជារោងចក្រមៅការបន្ត និងជារោងចក្រ ផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។

❖ ក្រុមហ៊ុន រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មាននិមិត្តសញ្ញា PWSA(រទសភ) បង្កើតតាំងពីឆ្នាំ ១៨៩៥ បានចុះបញ្ជីនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ដែលមានភាគហ៊ុនចុះបញ្ជីចំនួន ៨៦.៩៧៣.១៦២។ គ្រឹះស្ថានបានបង្កើតជាគ្រិះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលមានតួនាទីផ្គត់ផ្គង់ទឹកស្អាត។

ហើយថ្មីនេះក៏មានក្រុមហ៊ុនក្នុងស្រុកចំនួនទៀតកំពុងរៀបចំនីតិវិធីស្នើសុំ និងពិចារណាស្នើសុំចុះបញ្ជីផងដែរ ដូចជា អេ អេស អេ ភីអិលសុី (ធនាគារអេសុីលីដា)និង ក្រុមហ៊ុន វេសឡាញអេឌ្យូខេសិន គ្រុប (WEG) ជាដើម។

## ២.២ ក្រុមហ៊ុនមូលបត្របំណុល[6]

សញ្ញាបណ្ណ គឺជាប្រភេទមូលបត្របំណុល ដែលមានការតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល(រួមមានសាជីវកម្មសហគ្រាសរដ្ឋឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។ តាមរយៈកិច្ចសន្យានេះបុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឱ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា "ឥណប្រទិទាន"។ ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារក្រុមហ៊ុនឬអង្គភាពមួយអាចបោះផ្សាយសញ្ញាបណ្ណទៅឱ្យវិនិយោគិនដោយផ្ទាល់ នៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗបន្តប្រតិបត្តិការក្រុមហ៊ុនឬដើម្បីទូទាត់បំណុល។ លក្ខណៈខុសគ្នាចម្បងមួយរវាងភាគហ៊ុននិងសញ្ញាបណ្ណ គឺថាសញ្ញាបណ្ណតំណាងឱ្យភាពជាម្ចាស់បំណុល រីឯភាគហ៊ុនតំណាងឱ្យភាពជាម្ចាស់កម្មសិទ្ធិនៃក្រុមហ៊ុនមួយ។ ថ្លៃភាគហ៊ុនអាចកើនឡើងយ៉ាងឆាប់រហ័ស ប្រសិនបើក្រុមហ៊ុននោះមានការរីកចម្រើន និងមានប្រាក់ចំណេញច្រើន។ ផ្ទុយទៅវិញ សញ្ញាបណ្ណធ្វើការទូទាត់តែការប្រាក់ដែលបានកំណត់ជាមុនហើយថ្លៃរបស់វាប្រែប្រួលនៅក្នុងដែនដែលកំណត់ដោយអត្រាការប្រាក់ ពោលគឺមិនមែនកំណត់ដោយប្រាក់ចំណេញរបស់ក្រុមហ៊ុននោះឡើយ។ បច្ចុប្បន្ន មានតែប្រភេទសញ្ញាបណ្ណសាជីវកម្មមួយប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីនៅ **ផ.ម.ក.** ដោយសារតែមិនទាន់មាន សញ្ញាបណ្ណរដ្ឋ។ សញ្ញាបណ្ណសាជីវកម្ម ជាប្រភេទ

[6] www.secc.gov.kh

មួយនៃមូលបត្របំណុលដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈចេញដោយ **គ.ម.ក.** សញ្ញាបណ្ណសាជីវកម្មអាចចែកចេញជា៖

- **សញ្ញាបណ្ណធម្មតា ( Plain Vanilla Bond)** សំដៅដល់សញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ មានកំណត់តណប្រតិទានជាមុននៅ កាលបរិច្ឆេទបោះផ្សាយ មិនមានការលើកកម្ពស់ (Enhancement) និង/ឬលក្ខណៈបន្ថែមដូចជាសិទ្ធិទិញត្រលប់ (Call Option) ឬ សិទ្ធិលក់ (Put Option) និងមិនមានការធានា។
- **សញ្ញាបណ្ណមានបុគ្គលធានា (Guaranteed Bond)** សំដៅដល់សញ្ញាបណ្ណដែលផ្តល់ការធានាថាការប្រាក់ និងប្រាក់ដើមនឹងត្រូវបានទូទាត់សងដោយភាគីទីបី ដែលជានីតិបុគ្គល ករណីដែលបុគ្គលបោះផ្សាយមិនមានលទ្ធភាពសងបំណុល (Default) ដោយមូលហេតុដូចជាអសាធនភាព ឬក្ស័យធន។
- **សញ្ញាបណ្ណមានវត្ថុធានា (Secured Bond)** សំដៅដល់សញ្ញាបណ្ណដែលមានដាក់ទ្រព្យសកម្មជាវត្ថុធានា លើកលែងតែ មូលបត្របំណុលដែលមានទ្រព្យធានា (Asset Backed Securities) ដែលត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

ក្រុមហ៊ុនបោះមូលបត្របំណុលនៅមិនទាន់មានឡើយទេ ប៉ុន្តែបើដូចការគ្រោងទុកនៅដើមខែធ្នូ ២០១៨ខាងមុខនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ (HKLOនឹងក្លាយជាក្រុមហ៊ុនទី៦ ដែលចុះបញ្ជីបោះផ្សាយមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងជាក្រុមហ៊ុនដំបូងគេដែលបានបោះផ្សាយមូលបត្របំណុលនៅកម្ពុជា។

### ២.៣ ការបង្កើតទីផ្សារឧបករណ៍និស្សន្ទ[7]

ឧបករណ៍និស្សន្ទ គឺសំដៅដល់កិច្ចសន្យាលើគម្លាតថ្លៃ នៃឧបករណ៍ហិរញ្ញវត្ថុ ដើមដែលចេញពីមូលបត្រកម្មសិទ្ធ មូលបត្របំណុល សន្ទស្សន៍លោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្មន័ធម្មជាតិ កសិផល រូបិយវត្ថុ រួមទាំងគម្រោងការពារថ្លៃដើម ជាដើមនិងដែលត្រូវបានជួញដូរក្នុងទីផ្សារ។ ឧបករណ៍នស្សន្ទទាំងនេះ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។ ឧបករណ៍និស្សន្ទបានបង្កើតឡើងនៅថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០១៥។

បច្ចុប្បន្នគណៈកម្មការមូលបត្រកម្ពុជា គឺបានធ្វើការផ្តល់អាជ្ញាបណ្ណាដល់ក្រុមហ៊ុនជាសមភាគីកណ្តាលចំនួន៨ធ្វើជាដៃគូរផ្ទាល់ចំពោះរាល់កិច្ចសន្យាជួញដូរលើឧបរកណ៍និស្សន្ទក្នុងនោះមាន៖

[7] www.secc.gov.kh

- ក្រុមហ៊ុនខេមបូឌា ដេរីវេទីវ អិចឆេង ឯ.ក
- ក្រុមហ៊ុន ភ្នំពេញដេរីវេទីវ អិចឆេង ភីអិលស៊ី
- ក្រុមហ៊ុនរ៉ូយ៉ាល់ ហ្វាយនែនសល ខនភើរេសិន
- ក្រុមហ៊ុន ហ្គោល ហ្វាយនែនសល ភ្លូប៊ិលអិនវេសម៉ិន

### ២.៤ គម្រោងវិនិយោគរួម

បច្ចុប្បន្នទើបតែមានប្រកាសស្តីពីការគ្រប់គ្រង និងការផ្តល់អាជ្ញាប័ណ្ណគម្រោងវិនិយោគរួម ប៉ុន្តែមិនទាន់ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនណាមួយអោយមានគម្រោងវិនិយោគរួមទេ។ ដោយឡែក Collective Investment Schemes នេះជាការវិយោគរបស់សាធារណៈជនលើអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជាក្នុងការគ្រប់គ្រងមូលនិធិ ហើយមូលនិធិនេះត្រូវបានយកទៅវិនិយោគ បែងចែកយ៉ាងមានប្រសិទ្ធិភាព តម្លាភាព រួមទាំងសុវត្ថិភាពថែមទៀតផង ដោយសារមានអ្នកជំនាញជួញប្រឹក្សាយោបល់ក្នុងការវិនិយោគជាងការវិនិយោគផ្ទាល់។ ក្នុងពេលនេះអ្វីៗទាំងអស់ស្ថិតក្នុងដំណាក់កាលនៃការបង្កើតតួអង្គ កាលណាមានតួអង្គហើយទើបតួអង្គនោះដើរតួនាទីជាអ្នកបង្កើតផលិតផល ចំណែកគណៈកម្មការមូលបត្រកម្ពុជាជាអាជ្ញាធរបង្កើតហេដ្ឋារចនាសម្ព័ន្ធ ដែលជាអ្នករៀបចំឱ្យមានទីផ្សារកើតឡើង។ ការបង្កើតឱ្យមានក្រុមហ៊ុនគ្រប់គ្រងមូលនិធិនេះមានផលប្រយោជន៍ ដល់វិស័យមូលបត្រក្នុងការជំរុញឱ្យមានអ្នកលក់និងអ្នកទិញ។

## កថាខណ្ឌទី២៖ អំពីការជួញដូរមូលបត្រនីក្នុងទីផ្សារមូលបត្រកម្ពុជា

### ក. ការបោះផ្សាយលក់មូលបត្រជាសាធារណៈ

មូលបត្រមហាជន សំដៅដល់មូលបត្រ ដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានការអនុញ្ញាតឱ្យមានការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មូលបត្រទាំងនោះមាន៖

- មូលបត្រកម្មសិទ្ធិដែលរាប់បញ្ចូលទាំងភាគហ៊ុន
- មូលបត្របំណុល រាប់បញ្ចូលទាំងសញ្ញាប័ណ្ណ
- ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម
- ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវដែលទាក់ទង

មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ឬនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនិង គ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងក្រុមហ៊ុនបុរិមា។

គ្មានបុគ្គលណាមួយបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពី **គ.ម.ក** ដោយអនុលោមតាមច្បាប់ និងលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក**។ ទីផ្សារមូលបត្រកម្ពុជាកំពុងបោះជំហានទៅរកការបើកទ្វារលក់ដូរដោយក្រុមហ៊ុនរដ្ឋមួយ គឺរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ កំពុងរៀបចំបោះផ្សាយលក់មូលបត្ររបស់ជាសាធារណៈ ជាលើកដំបូង (ហៅកាត់តាមភាសាអង់គ្លេសថា (IPO)។

## ខ. លក្ខខណ្ឌតម្រូវនៃពាក្យស្នើសុំការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ខ.១. ទីផ្សារដំបូង៖ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

មូលបត្រមហាជន [8] សំដៅដល់មូលបត្រ ដែលបោះផ្សាយដោយក្រុមហ៊ុនមូលបត្រមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់នេះ។

មូលបត្រទាំងនោះមាន៖

ក. មូលបត្រកម្មសិទ្ធិរាប់បញ្ចូលទាំងភាគហ៊ុន

ខ. មូលបត្របំណុលរាប់បញ្ចូលទាំងសញ្ញាបណ្ណ

គ. ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម

ឃ. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវដែលទាក់ទងនឹងមូលបត្រមួយគឺយោងទៅលើចំណុច ក ខ ឬគ ខាងលើ។

ង. ឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលកំណត់ថាជាមូលបត្រ

សំណើលក់មូលបត្រមាន២ ប្រភេទគឺ សំណើលក់មូលបត្រជាសាធារណៈ និងសំណើលក់មូលបត្រជាឯកជន។ សំណើលក់មូលបត្រជាសាធារណៈ (Public Offer) សំដៅដល់ការអញ្ជើញសាធារណជន ឱ្យមកដាក់ពាក្យស្នើសុំទិញ ឬទិញមូលបត្រ។ នាពេលបច្ចុប្បន្ននេះ មូលបត្រភាគច្រើនមិនមែនជាប្រភេទក្រដាសដូចកាលពីមុនឡើយ។

សំណើលក់នេះរួមមាន៖

[8] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

(១) សំណើដាក់លក់មូលបត្រ ឬទិញមូលបត្រ ដែលធ្វើឡើងចំពោះមជ្ឈដ្ឋានសាធារណជនជាក់លាក់ណាមួយ ដែលត្រូវបានជ្រើសរើសឡើងតាមរបៀបណាក៏ដោយ។

(២) សំណើដាក់លក់ ឬទិញមូលបត្រដែលធ្វើឡើងតាមរបៀបចៃដន្យចំពោះសមាជិកនៃមជ្ឈដ្ឋានសាធារណៈ ដែលបានជ្រើសរើស។

(៣) សំណើដាក់លក់ ឬទិញមូលបត្រ ដែលធ្វើឡើងចំពោះបុគ្គលដែលស្គាល់ពីមុន តាមរយៈការផ្សាយពាណិជ្ជកម្មសំណើដាក់លក់ឬទិញឬតាមរយៈការអញ្ជើញបុគ្គលនោះឱ្យមកសាកសួរព័ត៌មាន ឬសុំការពិគ្រោះយោបល់អំពីការធ្វើការវិនិយោគ។

(៤) ការចែកអត្ថបទផ្សាយពាណិជ្ជកម្ម ឯកសារព័ត៌មាន ឬពាក្យស្នើសុំ ដែលទាក់ទងនឹងការដាក់ពាក្យសុំទិញ ការទិញ ឬការលក់មូលបត្រ។

ប៉ុន្តែសំណើលក់ជាសាធារណៈមិនរាប់បញ្ចូលនូវ៖

- សំណើលក់ជាឯកជន ដែលធ្វើឡើងចំពោះបុគ្គល ដែលមានទំនាក់ទំនងជាមួយនឹងបុគ្គលធ្វើសំណើលក់ ឬសហការី
- សំណើលក់ជាឯកជន ដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០រូប
- ការអញ្ជើញបុគ្គលណាមួយឱ្យមកធ្វើកិច្ចព្រមព្រៀងធានាទិញ ឬកិច្ចព្រមព្រៀងធានាបន្តដែលទាក់ទិននឹងការបោះផ្សាយមូលបត្រ

សំណើលក់មូលបត្រជាឯកជន(Private or Personal Offer) សំដៅដល់សំណើលក់ដែល៖

(១) ត្រូវបានធ្វើស្នីការដោយបុគ្គលដែលជាអ្នកទទួលសំណើ

(២) ត្រូវបានធ្វើឡើងចំពោះបុគ្គល ដែលមានការចាប់អារម្មណ៍ចំពោះសំណើលក់ដោយពិចារណាលើ៖

- ទំនាក់ទំនងពីមុនរវាងបុគ្គលដែលធ្វើសំណើនិង អ្នកដែលទទួលស្គាល់សំណើនោះ
- ទំនាក់ទំនងវិជ្ជាជីវៈ ឬទំនាក់ទំនងដទៃទៀតរវាងបុគ្គលដែលធ្វើសំណើ និងអ្នកទទួលសំណើនោះ
- សេចក្តីប្រកាស ឬអំពើរបស់បុគ្គលណាមួយ ដែលបង្ហាញថាខ្លួនចាប់អារម្មណ៍នឹងសំណើនោះ។

ដោយហេតុថា នៅកម្ពុជាទើបតែមានការបោះផ្សាយ លក់មូលបត្រកម្មសិទ្ធិតែប៉ុណ្ណោះ ចំណែកការបោះផ្សាយលក់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតគឺមិនទាន់មានយន្តការនិងការកំណត់ច្បាស់លាស់ដោយច្បាប់នៅឡើយ ដូចនេះកម្មវត្ថុនៃការសិក្សា៖

- សិក្សាអំពីអ្វីទៅដែលហៅថា ការបោះផ្សាយលក់មូលបត្រជាសាធារណៈ (មូលបត្រកម្មសិទ្ធិ)
- សិក្សាផ្តោតសំខាន់ទៅលើកាធ្វើការរបោះផ្សាយ លក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ១. អ្វីទៅជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ?

### សំណើលក់មូលបត្រមូលបត្រកម្មសិទ្ធិសាធារណៈ

សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិមាន ២គឺ[9]៖

**<u>សំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ</u>**

សំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ មាន២[10]គឺ៖

(១) សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការលក់មូលបត្រកម្មសិទ្ធិ ដែលមិនធ្លាប់បានធ្វើការបោះផ្សាយ លក់មូលបត្រជាសាធារណៈពីមុនមកដោយក្រុមហ៊ុនមហាជនខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

(២) សំណើបោះផ្សាយលក់មូលបត្របន្ថែមជាសាធារណៈ សំដៅទៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ដែលត្រូវបានធ្វើឡើងដោយក្រុមហ៊ុនដែលធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

មូលបត្រ បែងចែកចេញជា៖

- មូលបត្រថ្មី (New Securities) សំដៅទៅដល់មូលបត្រ ដែលមិនធ្លាប់បោះផ្សាយ ឬធ្វើសំណើលក់ជាសាធារណៈពីមុនមកដោយក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមានចែងក្នុងច្បាប់។
- មូលបត្របន្ថែមត្រូវបានបោះផ្សាយបន្ថែមដោយក្រុមហ៊ុនដែលធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

**<u>សំណើលក់មូលបត្រកម្មសិទ្ធិជាឯកជន</u>**

សំណើលក់មូលបត្រកម្មសិទ្ធិ ជាឯកជនសំដៅទៅដល់ការបោះផ្សាយ ដែលធ្វើឡើងនៅក្នុងលក្ខខណ្ឌខាងក្រោម[11]៖

- សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០រូប
- សំណើលក់មូលបត្រ មិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយរួមទាំងការធ្វើការផ្សព្វផ្សាយក្នុងគោលបំណងឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើការវិនិយោគលើមូលបត្រ។

[9] ប្រការ ៣ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

[10] ប្រការ ២ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

[11] ប្រការ ២ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

សំណើលក់មូលបត្រជាឯកជន បន្ទាប់ពីបញ្ចប់បុគ្គលធ្វើសំណើនេះត្រូវរាយការណ៍អំពីលទ្ធផលជូន **គ.ម.ក។**

ក្រុមហ៊ុនមួយ គឺអាចធ្វើសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនិងការធ្វើសំណើលក់មូលបត្រជាឯកជនបានប៉ុន្តែត្រូវមានកាតព្វកិច្ចរាយការណ៍ជូន**គ.ម.ក** អំពីលទ្ធផលនៃសំណើលក់មូលបត្រឯកជនភ្លាមបន្ទាប់ពីបានបញ្ចប់ជាស្ថាពរ[12]។

## ២. លក្ខខណ្ឌតម្រូវដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

<u>បុគ្គលដែលអាចបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ មាន២ប្រភេទ៖</u>

(១) ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

(២) នីតិបុគ្គលប្រតិស្រុត

លក្ខខណ្ឌតម្រូវ ចំពោះបុគ្គលដែលអាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបាន មានពីរប្រភេទគឺ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត។ បុគ្គលបោះផ្សាយលក់មូលបត្រ ដែលទទួលបានការអនុញ្ញាតឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវគោរពតាមលក្ខខណ្ឌចាំបាច់មួយចំនួនទៀត ដូចខាងក្រោម៖

❋ អភិបាលកិច្ចសាជីវកម្ម៖ ក្រុមហ៊ុនបោះផ្សាយត្រូវធានាឱ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អ តាមរយៈការបង្កើតយន្តការដើម្បីការពារសិទ្ធិរបស់ភាគហ៊ុនិក ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនការកំណត់សិទ្ធិអំណាច និងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាលការបង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ[13]។

❋ អភិបាលកិច្ចសាជីវកម្ម គឺជាប្រព័ន្ធដែលសហគ្រាស ឬក្រុមហ៊ុនត្រូវការដឹកនាំ គ្រប់គ្រង និងត្រួតពិនិត្យ។

គោលការណ៍នៃអភិបាលកិច្ចសាជីវកម្ម រួមមាន៖

❋ សិទ្ធិនិងប្រព្រឹត្តិកម្មស្មើភាពនៃភាគហ៊ុនិក

❋ តួនាទីនិងទំនួសខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

❋ ភាពស្មោះត្រង់និងក្រមសីលធម៌វិជ្ជាជីវៈ

❋ បង្ហាញនិងធ្វើឱ្យមានតម្លាភាព។

[12] ប្រការ ៣ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

[13] ប្រការ ៣ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

ក្រុមហ៊ុនបោះផ្សាយត្រូវធានាឱ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អ តាមរយៈការបង្កើតយន្តការដើម្បីការពារសិទ្ធិរបស់ភាគហ៊ុនិក ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន ការកំណត់សិទ្ធិអំណាចនិងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ការបង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពនិងការពារសិទ្ធិសិទ្ធិរបស់ភាគីពាក់ព័ន្ធ[14]។

ឯកសារផ្តល់ព័ត៌មាន (Disclosure Document)[15]៖ សំដៅដល់លិខិតជូនដំណឹង ឬសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយពីប្រវត្តិក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុ ឬជាការអញ្ជើញឱ្យទិញ ឬសំណើឱ្យគេដាក់ពាក្យសុំទិញឬទិញមូលបត្រឬប្រកាសអំពីការដាក់លក់ ឬការដាក់លក់មូលបត្រនិងរាប់បញ្ចូលទាំងឯកសារផ្តល់ព័ត៌មានជាប្រចាំ ឬឯកសារផ្តល់ព័ត៌មានជំនួសផងដែរ។

មាតិកានៃឯកសារផ្តល់ព័ត៌មាន ត្រូវមានដូចជា[16]៖

- ព័ត៌មានទូទៅអំពីក្រុមហ៊ុនបោះផ្សាយ (ចែងលម្អិតក្នុងប្រការ ៩នៃប្រកាស)
- ព័ត៌មានស្តីពីកត្តាហានិភ័យ(ចែងលម្អិតក្នុងប្រការ ១០នៃប្រកាស)
- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណ
- (ចែងលម្អិតក្នុងប្រការ ១១នៃប្រកាស)
- ផែនការវិនិយោគ
- ការពិពណ៌នាអំពីធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ(ចែងលម្អិតក្នុងប្រការ ១២នៃប្រកាស)
- ការពិពណ៌នាអំពីអចលកម្មបីរបស់ក្រុមហ៊ុនបោះផ្សាយ(ចែងលម្អិតក្នុងប្រការ ១៣នៃប្រកាស)
- ផែនការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ(ចែងលម្អិតក្នុងប្រការ ១៤នៃប្រកាស)
- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ(ចែងលម្អិតក្នុងប្រការ ១៥នៃប្រកាស)
- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល និងបុគ្គលិកជាន់ខ្ពស់(ចែងលម្អិតក្នុងប្រការ ១៦នៃប្រកាស)
- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់
- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ
- ប្រាក់បំណាច់ឬលាភការ សម្រាប់អភិបាលនិងបុគ្គលិកជាន់ខ្ពស់(ចែងលម្អិតក្នុងប្រការ១៩នៃប្រកាស)

[14] ប្រការ ៣ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

[15] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[16] ប្រការ ៧ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ចែងលម្អិតក្នុងប្រការ ២០នៃប្រកាស)
- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក
- ទ្រព្យសកម្មសុទ្ធ និងប្រាក់បំណាច់ក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ
- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ
- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់(ចែងលម្អិតក្នុងប្រការ ២៤នៃប្រកាស)
- ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់(ចែងលម្អិតក្នុងប្រការ ២៥នៃប្រកាស)
- ព័ត៌មានហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ
- ព័ត៌មានហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុរួម។

រៀងរាល់ឯកសារផ្តល់ព័ត៌មានទាំងអស់មុនពេលធ្វើការផ្សព្វផ្សាយជាសាធារណៈ ត្រូវទទួលបានការអនុញ្ញាត និងចុះបញ្ជីពី **គ.ម.ក**[17]។

<u>ការបដិសេធលើឯកសារផ្តល់ព័ត៌មាន[18]៖</u>

- ឯកសារបដិសេធផ្តល់ព័ត៌មានធ្វើមិនត្រឹមត្រូវតាមលក្ខខណ្ឌ និងការកំណត់របស់ច្បាប់
- នីតិវិធីបដិសេធ
  - ជូនដំណឹងដោយបញ្ជាក់អំពីមូលហេតុ
  - ផ្តល់ឱកាសឱ្យពន្យល់
  - ផ្តល់ឱកាសកែប្រែ

ឯកសារផ្តល់ព័ត៌មានបន្ថែម ឬជំនួស[19]៖ អគ្គនាយកអាចស្នើឱ្យកែប្រែ ផ្លាស់ប្តូរព័ត៌មាន ឬឱ្យរៀបចំតាមលក្ខខណ្ឌតម្រូវថ្មីក្នុងករណីមានកែប្រែច្បាប់ឬបទប្បញ្ញត្តិពាក់ព័ន្ធណាមួយឬករណីឯកសារផ្តល់ព័ត៌មានមានព័ត៌មានសំខាន់មិនច្បាស់លាស់ ក្លែងបន្លំ ឬដែលអាចនាំឱ្យយល់ខុស ឬខកខានមិនបានបង្ហាញនូវព័ត៌មានសំខាន់ណាមួយ[20]។

មិនអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានជំនួស ឬឯកសារផ្តល់ព័ត៌មានបន្ថែម មុនពេលឯកសារផ្តល់ព័ត៌មាននេះទទួលបានការអនុញ្ញាត និងចុះបញ្ជីនៅ **គ.ម.ក** បានឡើយ។

[17] មាត្រា ១៨ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[18] មាត្រា ១៩ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[19] មាត្រា ២០ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[20] មាត្រា ២១ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ការព្យួរ ឬការលុបចោលឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចៈ ករណីមានលក្ខណៈក្លែងបន្លំ នាំឱ្យយល់ខុស ឬខកខានមិនបានបង្ហាញនូវព័ត៌មានសំខាន់ណាមួយ។

ផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬជំនួសដោយគ្មានការអនុញ្ញាត និងចុះបញ្ជីនៅ **គ.ម.ក** ត្រូវមានទោស[21]៖

- ពន្ធនាគារ ១-៥ឆ្នាំ
- ពិន័យជាប្រាក់ ២ លានរៀល - ១០លានរៀល

<u>លក្ខខណ្ឌនៃសំណើលក់មូលបត្រជាសាធារណៈ:</u>

លក្ខខណ្ឌផ្សេងៗ[22]៖ ក្រុមហ៊ុនបោះផ្សាយត្រូវមានមូលធនភាគហ៊ុនិក ៥.០០០ លានរៀល និងមានទំហំនៃការបោះផ្សាយរួមមាន៖

- បោះផ្សាយយ៉ាងតិច ២០ ភាគរយ ករណីមូលធនតិចជាង ២០.០០០ លានរៀល
- បោះផ្សាយយ៉ាងតិច ១៥ ភាគរយ ករណីមានមូលធនចាប់ពី ២០.០០០ លានរៀល ឡើងទៅ
- ប្រាក់ចំណេញសុទ្ធ ៥០០ លានរៀល និងមានផលចំណេញសម្រាប់រយៈពេល៣ ឆ្នាំ គិតមកដល់ថ្ងៃដាក់ពាក្យ សរុបចំនួន ១.០០០ លានរៀល។

## ៣. នីតិវិធី នៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ

អនុលោមតាមគោលការណ៍ណែនាំ ស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង៖ យន្តការបោះផ្សាយលក់មូលបត្រមាន ១២ ចំណុច[23]៖

### ៣.១ ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក**គ.ម.ក**។ ក្នុងលិខិតសម្តែងឆន្ទៈនេះត្រូវមានខ្លឹមសារ ០៣ ចំណុច៖

- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- គម្រោងពេលវេលាំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

[21] មាត្រា ៩៥ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[22] ប្រកាស ៤ នៃច្បាប់ស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

[23] គោលការណ៍ស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលរំពឹងទុក និងដែលរួមមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

## ៣.២. ការតែងតាំងក្រុមហ៊ុនធានាទិញ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយ នៅក្នុងគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក**.។

លើសពីនេះ តាមបទពិសោធន៍នៃបណ្តាទីផ្សារមូលបត្រធំៗ អ្នកចុះកិច្ចសន្យាធានាទិញ ភាគច្រើនជាសម្ព័ន្ធក្រុមហ៊ុនមូលបត្រដែលក្រុមហ៊ុនមូលបត្រមួយ ដើរតួនាទីជាអ្នកធានាទិញចម្បង ( Lead underwriter or book manager ) ហើយក្រុមហ៊ុនមួយផ្សេងទៀតដែលចូលរួមសហអ្នកធានាទិញ។ ក្រុមហ៊ុនធានាទិញជាអន្តរការីជាអ្នកធ្វើការផ្សព្វផ្សាយ ដើម្បីស្វែងរកអ្នកវិនិយោគសាធារណៈអោយចុះឈ្មោះទិញមូលបត្ររបស់ក្រុមហ៊ុន និងដាក់លក់មូលបត្រដែលបោះផ្សាយអោយទៅអតិថិជនរបស់ក្រុមហ៊ុនធានាទិញនោះ។ នៅក្នុងការអនុវត្តនៅក្នុងបណ្តាប្រទេសធំៗ ដូចជា ប្រទេសបារាំង អាល្លឺម៉ង់ អង់គ្លេស និងសហរដ្ឋអាមេរិក ធនាគារដាក់លក់ប្រមាណ ៧០ ភាគរយ នៃមូលបត្រដែលបោះចេញអោយទៅអ្នកវិនិយោគសាធារណៈដែលជានីតិបុគ្គលធនាគារមេជាអ្នកធ្វើការដាក់លក់នូវមូលបត្រក្នុងទ្រង់ទ្រាយធំ។ ចំណែកដែលនៅសល់ត្រូវដាក់លក់ដោយធនាគារផ្សេងទៀតដែលចូលរួម។

ការសិក្សាស្រាវជ្រាវបានបង្ហាញថា ការជ្រើសរើសអ្នកចុះកិច្ចសន្យាធានាទិញនេះ គឺជាធាតុសារវន្តដែលកំណត់ពីភាពជោគជ័យនៃការធ្វើសំណើរលក់មូលបត្រនៅលើទីផ្សារមូលបត្រ។ អ្នកចុះកិច្ចសន្យាធានាទិញដែលល្អត្រូវជាបុគ្គលដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ។

ការជ្រើសរើសនេះគឺកាត់បន្ថយនូវហានិភ័យនៃការបន្ថោកតម្លៃក្រុមហ៊ុន ហើយអ្នកវិនិយោគសាធារណៈ អាចមានការជឿជាក់ទៅលើកិត្តិនាមរបស់អ្នកចុះកិច្ចសន្យាធានាទិញ។ ក៏ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវចំណាយខ្ពស់លើសេវាកម្ម ដែលផ្តល់អោយចុះកិច្ចសន្យាធានាទិញដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញនោះ។[24]

[24] . Patrick SENTIS, Introduction en Bourse: une approche internationale, 2004, p.69

## ៣.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ក្រៅពីក្រុមហ៊ុនធានាទិញ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ សមាសភាពក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង IPO Team ឬក្រុមហ៊ុនធានាទិញមូលបត្រអាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយមូលបត្រ លើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវីឬក្រុមហ៊ុនមេធាវីនិងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រៅពីក្រុមការងារបោះផ្សាយនេះ លោកអ្នកក៏អាចទំនាក់ទំនងមកកាន់ក្រុមការជំរុញការចុះបញ្ជីរបស់ **ផ.ម.ក** ដើម្បីទទួលបានការប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការត្រៀមរៀបចំខ្លួនសម្រាប់ការចុះបញ្ជីផងដែរ។

## ៣.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។ នៅក្នុងដំណាក់កាលនេះ ឯកសារផ្តល់ព័ត៌មាននឹងត្រូវបានរៀបចំឡើង។

## ៣.៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ អនុលោមតាមវិធាននៃការចុះបញ្ជីនេះក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានឹងធ្វើការបញ្ជាក់ថា តើក្រុមហ៊ុនបោះផ្សាយមូលបត្រអាចបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងៗ សម្រាប់ការចុះបញ្ជីលក់មូលបត្រដែរឬទេ។

### ៣.៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាត ជាគោលការណ៍លើសំណើរសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក**គ.ម.ក** តាមទម្រង់ដែលកំណត់ដោយ **គ.ម.ក**។ ក្រុមហ៊ុនបោះផ្សាយត្រូវដាក់ឯកសារផ្តល់ព័ត៌មាន និងឯកសារភ្ជាប់នានា។ ក្រោយពេលទទួលបានសំណើរនេះ **គ.ម.ក** ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មានមុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើរបោះផ្សាយលក់មូលបត្រ ជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។ អគ្គនាយកនៃ **គ.ម.ក** ត្រូវពិនិត្យ និងសម្រេចលើពាក្យស្នើសុំក្នុងរយៈពេលយ៉ាងយូរ ០៣ខែគិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ។

### ៣.៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង Book Building

ក្រោយពីទទួលបានការអនុញ្ញាត ជាគោលការណ៍លើសំណើស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី**គ.ម.ក** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រ។ ការកំណត់ថ្លៃនេះ ត្រូវធ្វើឡើងតាមរយៈវិធីសាស្ត្រប៊ុកបៀលឌីង។ ការធ្វើប៊ុកបៀលឌីងនេះ ការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយនឹងអ្នកវិនិយោគសក្តានុពលមុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

កិច្ចដំណើរការធ្វើប៊ុកបៀលឌីងត្រូវបានធ្វើមុនពេលនៃការចាប់ផ្តើមធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈដើម្បីអញ្ជើញអ្នកវិនិយោគិនឱ្យមកចូលរួមដោយត្រូវបានបញ្ជាក់ឱ្យបានច្បាស់ពីកាលបរិច្ឆេទកំណត់នៃការធ្វើប៊ុកបៀលឌីងនេះ។ វិនិយោគិន ដែលអាចចូលរួមធ្វើប៊ុកបៀលឌីងនេះបានត្រូវមានអត្តសញ្ញាណវិនិយោគិនដែលចេញដោយ**គ.ម.ក**។ វិនិយោគិនដែលចូលរួមក្នុងដំណើរការប៊ុកបៀលឌីងត្រូវបំពេញពាក្យស្នើសុំដែលកំណត់ដោយ**គ.ម.ក** និងត្រូវតម្កល់ប្រាក់ស្មើនឹង១០% នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលបានបំពេញក្នុងពាក្យសុំចូលរួមប៊ុកបៀលឌីង។ ទម្រង់ពាក្យស្នើសុំនេះត្រូវបានកំណត់ផ្សេងគ្នាសម្រាប់វិនិយោគជារូបវន្តបុគ្គល និងវិនិយោគិនជានីតិសបុគ្គល។ ក្នុងការស្ទាបស្ទង់តម្លៃនេះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ នឹងធ្វើការកំណត់ចន្លោះថ្លៃនៃថ្លៃ

មូលបត្រ (ឧ. ពី ៣$ ទៅ ៥$)ហើយអ្នកវិនិយោគដែលចូលរួមធ្វើប៊ុកបៀលឌីងនេះ ត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃនោះនិងត្រូវបញ្ជាក់ពីចំនួនមូលបត្រដែលខ្លួនមានបំណងចង់ធ្វើបរិវិសកម្ម។

ការគណនាថ្លៃមូលបត្រដែលត្រូវធ្វើសំណើលក់ ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញ ត្រូវកំណត់ថ្លៃមូលបត្រដែលត្រូវធ្វើសំណើលក់ជាសាធារណៈ ដើម្បីស្នើសុំការសម្រេចពី **គ.ម.ក**។ ការគណនាថ្លៃមូលបត្រនេះត្រូវធ្វើឡើង ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគលើមូលដ្ឋានថ្លៃនិងចំនួនមូលបត្រដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។ ថ្លៃដែលបានកំណត់រួចតាមរយៈបច្ចេកទេសនេះ អាចត្រូវបានធ្វើការកែតម្រូវដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពទីផ្សារដោយមានការសម្រេចពី គ.ម.ក។ បន្ទាប់ពីបញ្ចប់ការកំណត់ថ្លៃ ថ្លៃដែលបានកំណត់ត្រូវដាក់ជូនស្នើសុំការសម្រេចពី **គ.ម.ក** ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងនិងវិនិយោគិនដែលមិនទទួលបានជោគជ័យ។ វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងសំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើថ្លៃមូលបត្រដែលត្រូវបានកំណត់សម្រាប់ធ្វើសំណើលក់។ បន្ទាប់ពីទទួលបានការអនុញ្ញាតពី **គ.ម.ក** ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើសេចក្តីជូនដំណឹងដល់វិនិយោគិនពីលទ្ធផលនៃការធ្វើប៊ុកបៀលឌីងនេះ។

សារៈសំខាន់នៃវិធីសាស្ត្រប៊ុកបៀលឌីង ត្រូវបានធ្វើការកំណត់ថ្លៃដោយប្រើប្រាស់វិធីសាស្ត្រប៊ុកបៀលឌីងនេះ នឹងអាចឱ្យថ្លៃដែលកំណត់ឆ្លុះបញ្ចាំងពីតម្រូវការរបស់ទីផ្សារ។ តម្លៃមូលបត្រពិតប្រាកដនឹងត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានថ្លៃ ដែលអ្នកវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំធ្វើប៊ុកបៀលឌីង។ លើសពីនេះ វិធីសាស្ត្រនេះក៏អាចធានាបានពីភាពជោគជ័យនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈផងដែរ ដោយសារវាជាការស្ទាបស្ទង់មើលថា តើការធ្វើ បរិវិសកម្មអាចនឹងមានទំហំប៉ុន្មាន។ អ្នកដែលចូលរួមធ្វើប៊ុកបៀលឌីង ហើយទទួលបានជោគជ័យមានន័យថា ដូចបានកក់មូលបត្រទុកជាមុន។ គាត់ទទួលបានសិទ្ធិអាទិភាពក្នុងការចុះឈ្មោះសុំទិញមូលបត្រនៅពេលដែលក្រុមហ៊ុនដាក់លក់មូលបត្រនោះ។ ហេតុដូចនេះដើម្បីអោយវិនិយោគិនចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាបានថាមូលបត្រកម្មសិទ្ធិបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ ដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីងមានចំនួនដល់ទៅ៧០% នៃមូលបត្រសរុបដែលនៅសល់បន្ទាប់ពីបានធ្វើការលៃបំរុងទុក សម្រាប់លក់ជូនបុគ្គលិកក្នុងករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្ត តាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ មានន័យថា អ្នកដែលទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង ទទួលបានសិទ្ធិអាទិភាពទិញមូលបត្រចំនួន៧០%នេះ។ ចំណែកដែលនៅសល់ ៣០%ទៀត គឺត្រូវបានលៃបំរុងទុកសម្រាប់វិនិយោគិនដែលមិនបានចូលរួមឬ

មិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង។ ចំណែក៣០%នេះអាចនឹងត្រូវកាត់បន្ថយ ២០%បន្ថែមទៀត ប្រសិនបើអ្នកទទួលបានជោគជ័យមានចំនួនច្រើនលើសលប់ហើយបានដាក់ពាក្យសុំធ្វើបរិវិសកម្មច្រើនលើសលប់ផងដែរ។ លក្ខខណ្ឌលម្អិតសម្រាប់ការធ្វើបរិវិសកម្មជាកម្មវត្ថុនៃចំនុចបន្ទាប់។

### ៣.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រ តាមរយៈប៊ុកបៀលឌីងរួចហើយក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រដែលបានកំណត់អាចដាក់លក់នៅលើផ្សារមូលបត្របានដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលទាំងវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

### ៣.៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជារួចដាក់ជជូន **គ.ម.ក** ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

### ៣.១០. ការធ្វើបរិវិសកម្មមូលបត្រ

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក** ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ពោលគឺការអនុញ្ញាតឱ្យ អ្នកវិនិយោគសាធារណៈចុះឈ្មោះសុំទិញមូលបត្រ ដែលក្រុមហ៊ុនធ្វើសំណើលក់ជាសាធារណៈ។ ការធ្វើបរិវិសកម្មមូលបត្រនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព ពោលគឺក្នុងរយៈពេលមិនលើសពី ០៦ខែគិតចាប់ពីថ្ងៃដែលឯកសារផ្តល់ព័ត៌មានបានចុះបញ្ជីនៅ **គ.ម.ក**។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈ ២០% នៃសំណើលក់ជាសាធារណៈត្រូវបានបំរុងទុកសម្រាប់ធ្វើបរិវិសកម្ម ដោយអ្នកវិនិយោគសញ្ជាតិខ្មែរ និង ៨០%ទៀត ត្រូវបានបើកចំហ

ចំពោះអ្នកវិនិយោគទាំងអស់។ ប៉ុន្តែក្នុងករណីដែលការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការបែងចែកនេះ អគ្គនាយកនៃ **គ.ម.ក** អាចធ្វើការកំណត់ការបែងចែកនេះឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**គ.ម.ក** បានចេញគោលការណ៍ណែនាំពាក់ព័ន្ធនឹងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ។ យោងតាមគោលការណ៍ណែនាំនេះ អ្នកវិនិយោគសាធារណៈទាំងអស់ទោះបីទទួលបានជោគជ័យ ឬមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង ឬមិនចូលរួមធ្វើប៊ុកបៀលឌីងក៏ដោយចាំបាច់ត្រូវតែដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម តាមទម្រង់ដែលត្រូវបានកំណត់ដោយ **គ.ម.ក** ។ គ្រាន់តែដើម្បីលើកទឹកចិត្តឱ្យវិនិយោគិនចូលរួមធ្វើប៊ុកបៀលឌីងឱ្យបានច្រើន វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងមានសិទ្ធិអាទិភាពក្នុងការធ្វើបរិវិសកម្មមូលបត្រក្នុងចំនួន ដែលត្រូវបានលៃបំរុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង។ លើសនេះ ក្នុងករណីមានអ្នកវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីងមានចំនួនច្រើនលើសលុប ហើយបានដាក់ពាក្យធ្វើបរិវិសកម្មក្នុងចំនួនច្រើនលើសលុបលើសពីចំនួន មូលបត្រដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង (៧០%) នោះ **គ.ម.ក** អាចពិនិត្យធ្វើការបែងចែកក្នុងចំនួនមិនលើសពី២/៣ នៃមូលបត្រដែលត្រូវបានលៃបម្រុងទុកសម្រាប់អ្នកមិនបានចូលរួម ឬមិនបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង (ស្មើនឹង ២០% បន្ថែមទៀត)។ តើចំនួន ច្រើនលើសលុបនេះត្រូវកំណត់យ៉ាងដូចម្តេច? ប៉ុន្តែ វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ក៏មានកាតព្វកិច្ចធ្វើបរិវិសកម្មមូលបត្រស្មើនឹងទឹកប្រាក់១០% ដែលបានដាក់តម្កល់ពេលធ្វើប៊ុកបៀលឌីង ប្រសិនបើមូលបត្រដែលបានលៃបម្រុងទុកមិនត្រូវបានធ្វើបរិវិសកម្មអស់នោះទេ។ ដោយឡែក ប្រសិនបើមានអ្នកវិនិយោគិន ដែលបានទទួលបានការជោគជ័យក្នុងប៊ុកបៀលឌីងបានធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុក វិនិយោគិនដែលមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មអាចមិនធ្វើបរិវិសកម្ម និងអាចដកប្រាក់តម្កល់១០%នេះវិញបាន។[25]

ដើម្បីអាចចូលរួមធ្វើបរិវិសកម្មបាន វិនិយោគិនទាំងអស់ត្រូវតម្កល់ប្រាក់យ៉ាងតិច ១០០% នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។ ការធ្វើបរិវិសកម្មមួយត្រូវចាត់ទុកថាបានបញ្ចប់នៅពេលអ្នកធ្វើបរិវិសកម្មបានបំពេញត្រឹមត្រូវ តាមទម្រង់នៃពាក្យស្នើសុំបានបង់ប្រាក់គ្រប់ចំនួននិងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ ជាគោលការណ៍អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែក្នុងករណីដែលឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក**និងក្នុងករណីមានឯកសារផ្តល់ព័ត៌មាន

[25] . មាត្រា ៧ លេខ៤-ខ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់មូលបត្រមហាជន។

បន្ថែម។ ក្នុងករណីដែលឯកសារផ្តល់ព័ត៌មានត្រូវបានព្យួរ ក្រុមហ៊ុនត្រូវបញ្ឈប់ការទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម។ ការបន្តការធ្វើបរិវិសកម្មមូលបត្រឡើងវិញ អាចធ្វើទៅបាន លុះត្រាតែមានបញ្ហាដែលបណ្តាលឱ្យមានការព្យួរឯកសារផ្តល់ព័ត៌មានត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក**។

ប្រសិនបើការធ្វើបរិវិសកម្មមានចំនួនច្រើនលើសពីមូលបត្រ ដែលបានលៃបម្រុងទុកសម្រាប់គោលដៅនីមួយៗ ឬលើសពីចំនួនមូលបត្រនៃសំណើលក់ជាសាធារណៈការបែងចែកមូលបត្រជូនវិនិយោគិនត្រូវធ្វើឡើងតាមវិធានប្រូរ៉ាតា (ProRata)។ បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រតាមការដាក់ពាក្យស្នើសុំនោះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការផ្ទេរសាច់ប្រាក់ដែលនៅសល់ពីការធ្វើបរិវិសកម្មជូនអ្នកធ្វើបរិវិសកម្មនោះវិញ។ ផ្ទុយទៅវិញ ប្រសិនបើផុតកាលបរិច្ឆេទធ្វើបរិវិសកម្មមូលបត្រមិនត្រូវបានធ្វើបរិវិសកម្មអស់នោះទេក្រុមហ៊ុនធានាទិញត្រូវធ្វើបរិវិសកម្មមូលបត្រដែលនៅសល់ទាំងអស់ហើយការទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬជាឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងរយៈពេល ៣០ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យសុំធ្វើបរិវិសកម្ម។

### ៣.១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្ម

ក្រោយពីបានបញ្ចប់ ការធ្វើបរិវិសកម្មមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ តាមទម្រង់ដែលកំណត់ដោយ **គ.ម.ក** ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន**គ.ម.ក** ដោយភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជអំពីចំនួនទឹកប្រាក់ដែលមាននៅក្នុងគណនី ដោយឡែកត្រូវបានបង្កើតឡើងដោយមានគោលបំណងក្នុងការបោះផ្សាយលក់មូលបត្រ។

### ៣.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ស្របតាមបទប្បញ្ញត្តិនៃប្រការ៤៣ នៃប្រកាសស្តីអំពី ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបាន

ជោយជ័យ។ ខណៈពេលដែលសេដ្ឋកិច្ចនៃប្រទេសកម្ពុជាបន្តការរីកលូតលាស់និងពង្រីកនោះ ផ្សារហ៊ុនកម្ពុជាក៏អាចត្រូវបានរំពឹងថានឹងរីកលូតលាស់ដូចគ្នាដែរ។

ក្នុងន័យនេះ ការចុះបញ្ជីផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុតជាកាតព្វកិច្ច។

❋ កម្រៃសេវាក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈ

❋ ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សានិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅពេលដាក់ពាក្យស្នើសុំ។

- ១២.០០០.០០០រៀល សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ
- ៨.០០០.០០០រៀល សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម

❋ ថ្លៃពាក្យស្នើសុំពិនិត្យ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម

- ១២.០០០.០០០រៀល សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ
- ៨.០០០.០០០រៀល សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម

សោហ៊ុយស្នើសុំពិនិត្យសំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈដែលអស់សុពលភាព

- ១២.០០០.០០០រៀល សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ
- ៨.០០០.០០០រៀល សំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម

## ៤. កាតព្វកិច្ចផ្សេងៗទៀត ដែលកើតចេញពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ

ដើម្បីបង្កើតនិងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគសាធារណៈ តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគសាធារណៈ និងដើម្បីធានាឱ្យមានការបោះផ្សាយនិងការជួញដូរមូលបត្រប្រកប ដោយសណ្តាប់ធ្នាប់និងត្រឹមត្រូវច្បាប់បានបង្កើតនូវកាតព្វកិច្ចមួយចំនួនដែលកាតព្វកិច្ចទាំងនោះខ្លះជាបន្ទុករបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ(១)និងខ្លះទៀត ជាបន្ទុកផ្ទាល់របស់ភាគហ៊ុនិក(២)នៃក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ក្រៅពីកាតព្វកិច្ចទាំងនេះច្បាប់ក៏បានកំណត់ពីអាកប្បកិរិយាមួយចំនួន(៣)ដែលបុគ្គលគ្រប់រូបរួមទាំងក្រុមហ៊ុនបោះផ្សាយមូលបត្រនិងភាគហ៊ុនិកមិនត្រូវប្រព្រឹត្តផងដែរ ហើយអាកប្បកិរិយាទាំងនោះត្រូវបានច្បាប់កំណត់ថា ជាបទល្មើស។

### ៤.១. កាតព្វកិច្ចដែលធ្លាក់មកលើក្រុមហ៊ុន

បន្ទាប់ពីបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវផ្សព្វផ្សាយជាសាធារណៈនូវរាល់ព័ត៌មានទាំងឡាយ ដែលមានឥទ្ធិពលទៅលើតម្លៃមូលបត្រ។ ក្រៅពីកាតព្វកិច្ចក្នុងការផ្តល់នូវព័ត៌មានសមាជិក និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំក្រុមហ៊ុនបោះផ្សាយមូលបត្រ

មានកាតព្វកិច្ចផ្សព្វផ្សាយនូវឯកសារផ្តល់ព័ត៌មានជាប្រចាំ។ **របាយការណ៍សមាជិក**សម្តៅដល់របាយការណ៍ដែលបានរៀបចំសម្រាប់រយៈពេល នៃការរាយការណ៍ជាក់លាក់ណាមួយរួមមានរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។ របាយការណ៍សមាជិកនេះ អាចត្រូវបានទាមទារដោយអគ្គនាយកនៃ **គ.ម.ក** ឬដោយធ្វើប្រតិបត្តិករទីផ្សារមូលបត្រ។ ប្រតិបត្តិករទីផ្សារមូលបត្រអាចរៀបចំវិធានប្រតិបត្តិការដើម្បីតម្រូវឱ្យបុគ្គលចុះបញ្ជី នៅក្នុងទីផ្សារមូលបត្រផ្តល់នូវរបាយការណ៍សមាជិកដោយរួមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលប្រតិបត្តិករ យល់ឃើញថាជាការចាំបាច់ក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវដល់ទីផ្សារមូលបត្រ[26] កាតព្វកិច្ចផ្តល់ព័ត៌មានសមាជិកគឺធានាឱ្យបាននូវតម្លាភាពក្នុងការគ្រប់គ្រង និងតម្លាភាពនៃព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ របាយការណ៍សមាជិកដ៏សំខាន់មួយដែលមិនអាចខ្វះបាន សម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងអស់គឺរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។ របាយការណ៍ហិរញ្ញវត្ថុនេះរួមមានតារាងតុល្យការ និងរបាយការណ៍ចំណេញខាតរបស់ក្រុមហ៊ុន[27]។ របាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើសវនកម្មដោយមានភ្នាក់ងារឯករាជ្យដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក** ដើម្បីផ្តល់សេវាសវនកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រនេះ។

**កាតព្វកិច្ចផ្តល់ព័ត៌មានជាប្រចាំ**[28] ក្រៅពីកាតព្វកិច្ចផ្តល់របាយការណ៍សមាជិក តាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក** និងវិធានប្រតិបត្តិការរបស់ទីផ្សារ ក្រុមហ៊ុនបោះផ្សាយមូលបត្រក៏មានកាតព្វកិច្ចផ្តល់ឯកសារ ឬព័ត៌មានពាក់ព័ន្ធជាប្រចាំផងដែរដល់ **គ.ម.ក** និងប្រតិបត្តករទីផ្សារមូលបត្រដើម្បីផ្សព្វផ្សាយជាសាធារណៈផងដែរ ប្រសិនបើក្រុមហ៊ុនបោះផ្សាយមូលបត្របានដឹងថាព័ត៌មាននោះមិនទាន់បានផ្សព្វផ្សាយជាសាធារណៈ ឬព័ត៌មាននោះបានផ្សព្វផ្សាយជាសាធារណៈនឹងធ្វើឱ្យប៉ះពាល់ដល់ថ្លៃមូលបត្រដែលបានបោះផ្សាយលក់ ឬព័ត៌មាននោះដែលមិនទាន់បានបញ្ចូលទៅក្នុងឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស។ ការផ្តល់ព័ត៌មានជាប្រចាំនេះ អាចធ្វើឡើងក្រោមទម្រង់ជាឯកសារផ្តល់ព័ត៌មានប្រចាំដែលសំដៅដល់ឯកសារផ្តល់ព័ត៌មានដែលពិពណ៌នាអំពីព្រឹត្តការណ៍ដែលកើតឡើងនៅពេលណាមួយដែលមានក្នុងអាយុកាលរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រចាំបាច់ត្រូវតែធ្វើការផ្សព្វផ្សាយព័ត៌មានទាំងឡាយណាដែលអាចមានឥទ្ធិពលដល់ការឡើងចុះតម្លៃរបស់មូលបត្រ។ ព័ត៌មានមួយអាចប៉ះពាល់ដល់ថ្លៃនៃមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ប្រសិនបើព័ត៌មាននោះអាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គលក្នុងការជួញដូរមូលបត្រ។ កិច្ចព្រមព្រៀងរក្សាការសម្ងាត់មិនត្រូវនិងមិនអាច

[26] មាត្រា ៣៥ កថាខណ្ឌទី២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់មូលបត្រមហាជន។

[27] បៀន សាំង, "មូលបត្រកម្មសិទ្ធិ និងតម្លៃ", បោះពុម្ពលើកទី១, ឆ្នាំ ២០១១, ទំព័រ ៧២-៨៥

[28] បៀន សាំង, "មូលបត្រកម្មសិទ្ធិ និងតម្លៃ", បោះពុម្ពលើកទី១, ឆ្នាំ ២០១១, ទំព័រ ៧២-៨៥

ធ្វើការហាមឃាត់ចំពោះក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមិនឱ្យអនុវត្តកាតព្វកិច្ចផ្តល់ឯកសារផ្តល់ព័ត៌មានជាប្រចាំនេះបានឡើយ។ កាតព្វកិច្ចផ្តល់ព័ត៌មានជាប្រចាំនេះ គឺជាកាតព្វកិច្ចដែលកើតឡើងដោយឯកឯង និងគ្មានកាលកំណត់ច្បាស់លាស់នោះទេ។ ដើម្បីធានានូវការការពារចំពោះអ្នកវិនិយោគសាធារណៈ ការផ្សព្វផ្សាយនៅរាល់ឯកសារផ្តល់ព័ត៌មានដែលជាប្រចាំនេះត្រូវទទួលបានការអនុញ្ញាតពី **គ.ម.ក** ។ ការខកខានមិនបានផ្សព្វផ្សាយនូវព័ត៌មានដែលក្រុមហ៊ុនដឹងថា អាចប៉ះពាល់ដល់ថ្លៃមូលបត្រនេះ នឹងត្រូវផ្តន្ទាទោសដោយមាត្រា៥៩ នៃច្បាប់មូលបត្រមហាជន។ លើសពីនេះការប្រើប្រាស់ព័ត៌មានដែលអាចមានឥទ្ធិពលលើការឡើងចុះថ្លៃមូលបត្រ បើទោះបីដោយផ្ទាល់ឬដោយប្រយោលក្តី អាចនឹងត្រូវប្រឈមមុខនឹងការចោទប្រកាន់ពី បទល្មើសជួញដូរផ្ទៃក្នុងស្របតាមបទប្បញ្ញត្តិនៃមាត្រា៤០ និងមាត្រា៥៤ នៃច្បាប់មូលបត្រមហាជន។ បទល្មើសទាំងនេះនឹងត្រូវបកស្រាយលម្អិតនៅក្នុងចំនុចខាងមុខ។

**ការផ្សព្វផ្សាយនូវព័ត៌មានផ្សេងទៀត** ប្រសិនបើ **គ.ម.ក** ឬប្រតិបត្តិករទីផ្សារមូលបត្រយល់ឃើញថាមានការជួញដូរក្លែងក្លាយនៃមូលបត្រ ឬមានហានិភ័យខ្ពស់ក្នុងការកកើតឡើងនូវការជួញដូរក្លែងក្លាយនៃមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ អគ្គនាយកនៃ **គ.ម.ក** ឬប្រតិបត្តិករទីផ្សារមូលបត្រអាចស្នើឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រផ្តល់ព័ត៌មានដើម្បីកែតម្រូវ ឬទប់ស្កាត់ការជួញដូរក្លែងក្លាយ។ ប្រសិនបើអគ្គនាយកនៃ**គ.ម.ក** ឬប្រតិបត្តិករទីផ្សារមូលបត្រតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រផ្តល់ព័ត៌មាន អគ្គនាយកនៃ **គ.ម.ក** ឬប្រតិបត្តិករទីផ្សារមូលបត្រ អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយមូលធ្វើការផ្សព្វផ្សាយព័ត៌មាននោះមួយផ្នែក ឬទាំងអស់នៅក្នុងសារព័ត៌មានសរសេរប្រចាំថ្ងៃដែលចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផ្សព្វផ្សាយតាមមធ្យោបាយផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក** ។ ការចំណាយលើការផ្សព្វផ្សាយនេះជាបន្ទុករបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ។

## ៤.២. កាតព្វកិច្ចដែលធ្លាក់មកលើភាគហ៊ុនិក

ភាគហ៊ុនិកនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈមានកាតព្វកិច្ចធ្វើ អនុប្បទានភាគហ៊ុនរបស់ខ្លួនតាមរយៈអន្តរការីប្រតិស្រុត និងមានកាតព្វកិច្ចផ្សព្វផ្សាយនូវព័ត៌មានទាំងឡាយដែលកំណត់ដោយច្បាប់។ ព័ត៌មានទាំងនោះទាក់ទងជាពិសេសទៅនឹងការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ចំនួនច្រើននិងចំនួនច្រើនលើសលប់ការកើនឡើងនៃចំនួនភាគហ៊ុនដែលភាគហ៊ុនិកម្នាក់ៗ មាននៅក្នុងក្រុមហ៊ុន និងប្រតិបត្តិការមួយចំនួនទៀត។ ព័ត៌មានដែលទាក់ទងនឹងការកាន់កាប់ក្រុមហ៊ុនមានសារៈសំខាន់ណាស់សម្រាប់អ្នកវិនិយោគសាធារណៈ ដែលមានបំណងចង់វិភាគ

លើមូលបត្រភាគហ៊ុនដែលបោះផ្សាយលក់ជាសាធារណៈដោយក្រុមហ៊ុន។ អ្នកវិនិយោគត្រូវការដឹងអំពីនរណាជាអ្នកកាន់កាប់ ក្រុមហ៊ុន ឬមានបំណងចង់កាន់កាប់ក្រុមហ៊ុន។ ការកើនឡើងនៃចំនួនភាគហ៊ុនរបស់ភាគហ៊ុនិកម្នាក់អាចបង្ហាញពីឆន្ទៈក្នុងការទិញសិទ្ធិកាន់កាប់ក្រុមហ៊ុន។ ប្រតិបត្តិការនេះអាចមានផលប៉ះពាល់ដល់ការឡើងចុះថ្លៃមូលបត្រ។ ហេតុដូចនេះ ទើបច្បាប់តម្រូវអោយសមាជិកភាគហ៊ុនត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រតិបត្តិការនេះ។

**ព័ត៌មានទាក់ទងនឹងសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន**[29] សិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើនសំដៅដល់សិទ្ធិ ឬសមាជោគនៃសិទ្ធិស្របច្បាប់ របស់សមាការី ឬបុគ្គលដែលពាក់ព័ន្ធក្នុងការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលផ្តល់ដល់បុគ្គលនោះនូវលទ្ធភាពកាន់កាប់សំឡេងឆ្នោតសរុបចាប់ពី០៥% ឡើងទៅ ហើយដែលសំឡេងឆ្នោតនោះត្រូវបានភ្ជាប់ទៅនឹងភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រ។បុគ្គលដែលចាប់ផ្តើមមាន ឬលែងមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើននៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវផ្តល់ព័ត៌មានទៅ **គ.ម.ក** ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងប្រតិបត្តិករទីផ្សារមូលបត្រ បើក្រុមហ៊ុននោះជាបុគ្គលចុះបញ្ជីលក់មូលបត្រក្នុង រយៈពេល ០៣ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានដឹងព័ត៌មាននេះ[30]។ ដូចគ្នាផងដែរនៅពេលដែលសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើននោះមានការប្រែប្រួលឡើងឬចុះយ៉ាងតិច ០១%។

**ព័ត៌មានទាក់ទងនឹងសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់** បុគ្គលណាម្នាក់ ដែលមានបំណងចង់ទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវតែសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក** ។ លើសពីនេះ ភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ នៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវផ្តល់ព័ត៌មានជូន **គ.ម.ក** ប្រសិនបើសិទ្ធិកាន់កាប់នោះមានការប្រែប្រួល ឡើង ឬ ចុះយ៉ាងតិច០១%។ សិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់សំដៅដល់សិទ្ធិរបស់បុគ្គលម្នាក់ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី៣០%ឡើងទៅនៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមិនត្រូវបានគិតថាសិទ្ធិរបស់បុគ្គលនោះមានលក្ខណៈប្រយោល ឬកើតឡើងដោយរបៀបណាក៏ដោយ។ ដូចគ្នាផងដែរបុគ្គលដែលមានបំណងចង់លក់សិទ្ធិកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានពេញលេញ និងត្រឹមត្រូវអំពីសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិ

[29] មាត្រា ៣៦ វាក្យខណ្ឌទី ៤ និង ៥ នៃអនុក្រឹត្យស្តីការអនុវត្តច្បាប់មូលបត្រមហាជន។

[30] មាត្រ ៨៧ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់មូលបត្រមហាជន។

បោះឆ្នោតចំនួនច្រើនលើសលប់នោះ។ គោលបំណងរបស់ច្បាប់គឺអនុញ្ញាតឱ្យអ្នកវិនិយោគសាធារណៈទាំងអស់ដឹងច្បាស់អំពីចលនាដើមទុនហើយអាចសម្រេចចិត្តក្នុងការរក្សាទុកឬទិញឬក៏លក់មូលបត្រដែលជាប់ពាក់ព័ន្ធប្រសិនបើភាគហ៊ុនិកដែលជាប់ពាក់ព័ន្ធមិនបានធ្វើការផ្សព្វផ្សាយនោះទេ គេនឹងត្រូវទទួលរងនូវទណ្ឌកម្មដែលកំណត់ដោយច្បាប់។ប៉ុន្តែច្បាប់ជាធរមានមិនទាន់បានកំណត់អំពីទណ្ឌកម្មនេះនៅឡើយទេ។

### ៤.៣. អាកប្បកិរិយាដែលត្រូវបានហាមឃាត់ទាក់ទិននៅនឹងមូលបត្រ

ទាំងចំពោះក្រុមហ៊ុនបោះផ្សាយមូលបត្រភាគហ៊ុនិករបស់ក្រុមហ៊ុន និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធ មិនត្រូវប្រព្រឹត្តនៅអាកប្បកិរិយាណាមួយដែលមាត្រា៤០ដល់មាត្រា៤២ នៃច្បាប់មូលបត្រមហាជនបានហាមឃាត់នោះទេ [31] ។ទង្វើទាំងអស់នេះត្រូវបានច្បាប់ចាត់ទុកថា បទល្មើសព្រហ្មទណ្ឌស្របតាមមាត្រា៥៤ នៃច្បាប់មូលបត្រមហាជន។ យោងតាមមាត្រា៥៤នេះ បទល្មើសទាំងនោះរួមមាន បទល្មើសជួញដូរផ្ទៃក្នុងបទល្មើសជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ និងបទល្មើសដែលទាក់ទងនឹងការធ្វើសេចក្ដីថ្លែងឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំឬនាំឱ្យយល់ខុស។ បទល្មើសទាំងនេះ ជាប្រភេទបទល្មើសឧក្រិដ្ឋដូចគ្នា ហើយត្រូវផ្ដន្ទាទោសដូចគ្នាផងដែរ។

### ខ.២. ទីផ្សារបន្ទាប់

ការជួញដូរមូលបត្រ សំដៅទៅដល់ការទិញលក់មូលបត្ររវាងអ្នកវិនិយោគនិងអ្នកវិនិយោគ។ ការជួញដូរនេះ ត្រូវធ្វើឡើងនៅក្នុងទីផ្សារប្រតិស្រុត (ទីផ្សារបន្ទាប់)។ ប្រទេសកម្ពុជា មិនទាន់មានការអនុញ្ញាតឱ្យធ្វើការជួញដូរតាមរយៈទីផ្សាររំលងបញ្ជរ (Over The Counter-OTC) នៅឡើយ។

### ១. ដំណើរការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់

តើធ្វើយ៉ាងណា ដើម្បីជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជាបាន? ការជួញដូរមូលបត្រគឺជាប្រតិបត្តិការមួយដែលមានភាពស្មុគស្មាញ និងសាំញ៉ាំសម្រាប់សាធារណៈជនក៏ដូចជាវិនិយោគិនកម្ពុជាមួយចំនួន ដែលមានបំណងទិញ-លក់មូលបត្រខណៈពេលដែលទីផ្សារមួយនេះទើបត្រូវបានដាក់ឱ្យដំណើរការជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា នាពេលថ្មីៗនេះ។

ការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រ មានភាពខុសគ្នាពីការជួញដូរទំនិញនៅក្នុងទីផ្សារធម្មតា។ ការជួញដូរទំនិញនៅក្នុងទីផ្សារធម្មតា អាចត្រូវបានធ្វើឡើងដោយផ្ទាល់រវាងអ្នកទិញនិង

[31] មាត្រា ៦៥ និង និង ៦៦ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់មូលបត្រមហាជន។

អ្នកលក់នៅក្នុងទីផ្សារ។ ដោយឡែកការជួញដូរមូលបត្រដែលមាននៅក្នុងទីផ្សារមូលបត្រ មិនអាចត្រូវធ្វើឡើងដោយផ្ទាល់រវាងវិនិយោគិននៅក្នុងទីផ្សារមូលបត្រមូលបត្របាននោះទេ។ រាល់ការជួញដូរមូលបត្រ ត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលមានតួនាទីអនុវត្តការជួញដូរមូលបត្រជំនួស និងក្នុងនាមវិនិយោគិនមូលបត្រដែលជាអតិថិជនរបស់ខ្លួន ជាថ្នូរនឹងកម្រៃជើងសារដែលក្រុមហ៊ុនត្រូវទទួលបាន។ ដើម្បីយល់ច្បាស់ពីបញ្ហានេះ ក្រុមការងារព្រឹត្តិបត្រនៃគណៈកម្មការមូលបត្រកម្ពុជានឹងធ្វើការបកស្រាយដោយសង្ខេបពីរបៀបនៃការជួញដូរមូលបត្រ ដែលត្រូវអនុវត្តទៅតាមដំណាក់កាលមួយចំនួនដូចខាងក្រោមៈ

## ២. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ

ដោយការជួញដូរមូលបត្រ ត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រ ដូច្នេះ វិនិយោគិនដែលមានបំណងជួញដូរមូលបត្រ ត្រូវជ្រើសរើសជាដំបូងក្រុមហ៊ុនមូលបត្រណាមួយក្នុងចំណោមក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក** ដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា។ វិនិយោគិនមូលបត្រអាចសម្រេចជ្រើសរើសក្រុមហ៊ុនមូលបត្រណាមួយ ដោយផ្អែកទៅលើគោលការណ៍នៃច្បាប់អាជីវកម្មរបស់ក្រុមហ៊ុនឬគុណភាពនៃសេវាកម្មដែលក្រុមហ៊ុនផ្តល់ឱ្យដោយធៀបនឹងតម្លៃនៃកម្រៃជើងសាររបស់ក្រុមហ៊ុននោះ។ វិនិយោគិនដែលមានបំណងជួញដូរមូលបត្រអាចស្វែងរកបញ្ជីឈ្មោះដែលមានក្នុងក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី**គ.ម.ក** និងអាស័យដ្ឋានទំនាក់ទំនងក្រុមហ៊ុនមូលបត្រនៅក្នុងគេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (www.secc.gov.kh) ឬគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (www.csx.com.kh) ។

## ៣. ការបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រ

គណនីមូលបត្រ គឺជាប្រភេទគណនីក្រុមហ៊ុនរបស់ធនាគារលីដា ដែលបានអនុញ្ញាតឱ្យក្រុមមូលបត្រ ឬភ្នាក់ងារពាក់ព័ន្ធដែលបានទទួលអាជ្ញាបណ្ណពី គណៈកម្មការមូលបត្រកម្ពុជា អាចបើកគណនីសម្រាប់ទូទាត់សាច់ប្រាក់ជួញដូរមូលបត្របាន។ បន្ទាប់ពីបានធ្វើការជ្រើសរើសក្រុមហ៊ុនមូលបត្រវិនិយោគិនមូលបត្រ ត្រូវបើកគណនីជួញដូរមួយជាមួយក្រុមហ៊ុនមូលបត្រដែលខ្លួនបានជ្រើសរើសមុននឹងចាប់ផ្តើមប្រតិបត្តិការនៃការដាក់បញ្ជាទិញ-លក់មូលបត្រ។ វិនិយោគិនម្នាក់អាចបើកគណនីជួញដូរបានតែមួយប៉ុណ្ណោះនៅក្នុងក្រុមហ៊ុនមូលបត្រមួយ[32]។ ដើម្បីអាចបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រ វិនិយោគិនត្រូវទៅបំពេញពាក្យស្នើសុំបើកគណនី និងចុះកិច្ចព្រម

[32] ប្រការ ៧ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈនៃក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

ព្រៀងអតិថិជនជាមួយក្រុមហ៊ុនមូលបត្រដែលខ្លួនបានជ្រើសរើស[33] ដោយត្រូវមានឯកសារភ្ជាប់មួយចំនួនដូចជា (១) ចំពោះវិនិយោគិនជារូបវន្តបុគ្គលៈ ត្រូវមានភ្ជាប់អត្តសញ្ញាណថតចម្លង (ចំពោះជនជាតិខ្មែរ) ឬលិខិតឆ្លងដែនថតចម្លង (ចំពោះជនបរទេស) លេខគណនីធនាគារ លេខសំគាល់អត្តសញ្ញាណវិនិយោគិន (វិនិយោគិនអាចស្នើសុំលេខសំគាល់អត្តសញ្ញាណវិនិយោគិនដោយផ្ទាល់នៅ **គ.ម.ក** ឬតាមរយៈក្រុមហ៊ុនមូលបត្រ) ប្រវត្តិរូបសង្ខេបរបស់វិនិយោគិន និងរូបថត ៤×៦ (បួនគុណនឹងប្រាំមួយ) ចំនួនមួយសន្លឹក[34] (២) ចំពោះវិនិយោគិនជានីតិបុគ្គលៈ ត្រូវមានភ្ជាប់អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់អ្នកគ្រប់គ្រងក្រុមហ៊ុន អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់អ្នកតំណាងនីតិបុគ្គល ត្រារបស់នីតិបុគ្គល លក្ខន្តិកៈថតចម្លង វិញ្ញាបនបត្រចុះបញ្ជីថតចម្លង បណ្ណប៉ាតង់ថតចម្លង អាជ្ញាបណ្ណថតចម្លង លេខគណនីធនាគារ និងលេខសំគាល់អត្តសញ្ញាណវិនិយោគិនរបស់នីតិបុគ្គល[35]។ បន្ទាប់ពីបានបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រ ហើយក្រុមហ៊ុនមូលបត្រ នឹងបន្តការបើកគណនីសាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រក្នុងនាមខ្លួនផ្ទាល់ និងគណនីមូលបត្រមួយផ្សេងទៀតនៅប្រតិបត្តិកររក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់ និងកាតព្វកិច្ចទូទាត់មូលបត្របន្ទាប់ពីបញ្ចប់ការជួញដូរ។

### ៤. ការដាក់បញ្ជាទិញ-លក់របស់វិនិយោគិនមូលបត្រ[36]

មួយថ្ងៃក្រោយពីការបើកគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រ វិនិយោគិនមូលបត្រអាចចាប់ផ្តើម ដាក់បញ្ជាទិញលក់មូលបត្ររបស់ខ្លួនតាមរយៈក្រុមហ៊ុនមូលបត្រ។ការដាក់បញ្ជាទិញ-លក់មូលបត្ររបស់វិនិយោគិនមូលបត្រ អាចធ្វើឡើងតាមរយៈការទៅជួបផ្ទាល់ជាមួយនឹងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រនៅក្រុមហ៊ុនមូលបត្រ ឬតាមរយៈការហៅទូរស័ព្ទ សារទូរស័ព្ទ អ៊ីម៉ែល ឬមធ្យោបាយអេឡិចត្រូនិចផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក**។ នៅក្នុងបញ្ជាទិញ-លក់មូលបត្រ

[33] ប្រការ៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយមូលបត្រនិងការជួញដូរមូលបត្រមហាជន និងប្រការ៦នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈនៃក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

[34] ទម្រង់ពាក្យស្នើសុំបើកគណនីដែលជាឧបសម្ព័ន្ធ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈនៃក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

[35] ទម្រង់ពាក្យស្នើសុំបើកគណនីដែលជាឧបសម្ព័ន្ធ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈនៃក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

[36] ប្រការ ៥ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈនៃក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

ដែលត្រូវផ្ញើទៅក្រុមហ៊ុនមូលបត្រ ត្រូវមានបញ្ជាក់យ៉ាងហោចណាស់ព័ត៌មានសំខាន់ៗដូចជាៈ ប្រភេទនៃបញ្ជាជួញដូរ (ជាបញ្ជាទិញមូលបត្រ ឬជាបញ្ជាលក់មូលបត្រ) ថ្លៃជួញដូរក្នុងមួយមូលបត្រ ចំនួនមូលបត្រដែលត្រូវជួញដូរ និងឈ្មោះមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយដែលវិនិយោគិនមានបំណងធ្វើការជួញដូរ។ ម្យ៉ាងវិញទៀត នៅពេលដាក់បញ្ជាជួញដូរមូលបត្រ វិនិយោគិនត្រូវដាក់តម្កល់នៅក្នុងគណនីជួញដូររបស់ខ្លួនដែលបានបើកជាមួយក្រុមហ៊ុនមូលបត្រ នូវសាច់ប្រាក់យ៉ាងហោចណាស់ ១០០% សម្រាប់បញ្ជាទិញមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោចណាស់ ១០០% សម្រាប់បញ្ជាលក់មូលបត្រ។ នៅមុនពេលអនុវត្តបញ្ជារបស់វិនិយោគិនដែលជាអតិថិជនរបស់ខ្លួន ក្រុមហ៊ុនមូលបត្រត្រូវបង្កកទុកសាច់ប្រាក់ និងមូលបត្រដែលបានតម្កល់ទុកទាំងនោះនៅក្នុងគណនីជួញដូរ ដើម្បីធានាការទូទាត់នៅពេលដែលបញ្ជាត្រូវអនុវត្តបានដោយជោគជ័យ។ ទោះជាយ៉ាងណាក៏ដោយមុននឹងសម្រេចចិត្តដាក់បញ្ជាទិញ-លក់មូលបត្រ វិនិយោគិនមូលបត្រអាចធ្វើការប្រឹក្សាជាមុនជាមួយនឹងក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនដែលបានផ្តល់ប្រឹក្សាវិនិយោគដែលមានការទទួលបានអាជ្ញាបណ្ណពី **គ.ម.ក** ពីវិធីសាស្ត្រនៃការជួញដូរ របៀបនៃការជួញដូរ កត្តាហានិភ័យផ្សេងៗដែលអាចកើតមានឡើងនៅពេលធ្វើការជួញដូរ និងសិក្សាឱ្យបានច្បាស់លាស់លើឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយ។

### ៥. ការអនុវត្តបញ្ជាទិញ-លក់របស់វិនិយោគិនមូលបត្រ

បន្ទាប់ ពីបានទទួលការបញ្ជាទិញ-លក់របស់វិនិយោគិនមូលបត្រដែលជាអតិថិជនរបស់ខ្លួន ក្រុមហ៊ុនមូលបត្រត្រូវតែបញ្ជូនបញ្ជានោះ ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សាររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាភ្លាម។ នៅរៀងរាល់ម៉ោងជួញដូរ ពោលគឺនៅម៉ោង ៩ព្រឹក និងម៉ោង ១១:៣០នាទីព្រឹក ប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារ ចាប់ផ្តើមធ្វើការផ្គូរផ្គង និងអនុវត្តបញ្ជានានាដែលត្រូវបានបញ្ជូនមកដោយយោងទៅតាមគោលការណ៍ដេញថ្លៃ ដែលកំណត់ទុកជាមុន។ បន្ទាប់ពីការផ្គូរផ្គងលទ្ធផលនឹងបង្ហាញចេញនូវបញ្ជាទិញ-លក់ដែលបានសម្រេច និងបញ្ជាទិញ-លក់ដែលមិនបានសម្រេច។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានឹងបញ្ជូនលទ្ធផលជួញដូរនេះ ទៅកាន់ក្រុមហ៊ុនមូលបត្រដែលជាសមាជិកពាក់ព័ន្ធ ហើយក្រុមហ៊ុនមូលបត្រត្រូវបញ្ជូនដំណឹងបន្តទៅកាន់វិនិយោគិនមូលបត្រដែលជាអតិថិជនរបស់ខ្លួន។

### ៦. ការផាត់ទាត់និងការទូទាត់ការជួញដូរមូលបត្រ

ការផាត់ទាត់ និងការទូទាត់ត្រូវបានធ្វើឡើងដោយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់របស់ក្រុមហ៊ុនផ្សារមូលបត្រ។ ប្រតិបត្តិការនេះនឹងត្រូវបានធ្វើឡើងចំពោះបញ្ជាទិញ-លក់ទាំងឡាយណា

ដែលទទួលជោគជ័យក្នុងការផ្គូរផ្គងប៉ុណ្ណោះ។ ការទូទាត់ គឺជាដំណាក់កាលមួយនៃការបញ្ចប់ការធ្វើប្រតិបត្តិការជួញដូរដែលអ្នកលក់ត្រូវផ្ទេរមូលបត្រ ហើយអ្នកទិញត្រូវផ្ទេរសាច់ប្រាក់ទៅឱ្យអ្នកលក់។ ការទូទាត់ នឹងត្រូវធ្វើឡើងក្នុងរយៈពេលពីរថ្ងៃ នៃថ្ងៃជួញដូរបន្ទាប់ពីថ្ងៃដែលមូលបត្រនោះត្រូវបានជួញដូរ(T+2) [37] ។ តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ដែលបានបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ [38] ហើយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះទៅឱ្យក្រុមហ៊ុនមូលបត្រ ដែលតាងនាមឱ្យវិនិយោគិនដែលជាអ្នកលក់។ ដូចគ្នាដែរ ការទូទាត់មូលបត្រត្រូវធ្វើឡើងតាមរយៈការផ្ទេរក្នុងបញ្ជី (Book-Entry Transfer)ពីគណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រ ដែលតាងនាមឱ្យវិនិយោគិនដែលអ្នកលក់ទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រដែលបានបើកជាមួយនឹងប្រតិបត្តិកររក្សាទុកមូលបត្រ ហើយអ្នកប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះទៅក្រុមហ៊ុនមូលបត្រដែលតាងនាមឱ្យវិនិយោគិនដែលជាអ្នកទិញ[39]។

### ៧. ការរក្សាទុកមូលបត្រ

នៅពេលប្រតិបត្តិការផាត់ទាត់និងទូទាត់ត្រូវបានបញ្ចប់រាល់មូលបត្រទាំងអស់ត្រូវរក្សាទុកនៅប្រតិបត្តិកររក្សាទុកមូលបត្រ ព្រោះប្រតិបត្តិការទូទាត់មូលបត្រត្រូវធ្វើឡើងតាមរយៈការផ្ទេររវាងគណនី (Book Entry) ដោយគ្មានការផ្ទេរមូលបត្ររូបវន្តនោះទេ។ ការរក្សាទុកមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ គឺដើម្បីទទួលបានការកត់ត្រាកម្មសិទ្ធិលើមូលបត្រ និងធានាហានិភ័យចំពោះការបាត់បង់និងការលួចមូលបត្រទាំងឡាយដែលអាចកើតមាន។

## កថាខណ្ឌទី៣៖ ព័ត៌មានសាជីវកម្ម

ព័ត៌មានសាជីវកម្ម គឺជាព័ត៌មានដែលសំខាន់បំផុតសម្រាប់អ្នកវិនិយោគដែលមានក្នុងការទិញលក់មូលបត្រហើយព័ត៌មាននេះ ក៏ជាកត្តាសំខាន់ដែលនាំឱ្យមានការប្រែប្រួល ឬប៉ះពាល់ធ្ងន់ធ្ងរទៅដល់តម្លៃមូលបត្រផងដែរ។ អាស្រ័យហេតុនេះ **គ.ម.ក** បានរៀបចំនូវប្រកាសស្តីពីព័ត៌មានសាជីវកម្ម ដើម្បីកំណត់អំពីប្រភេទនៃព័ត៌មាន និងនីតិវិធីសមស្របសម្រាប់ក្រុមហ៊ុនបោះផ្សាយ ក្នុងការផ្សព្វផ្សាយព័ត៌មានសាជីវកម្មរបស់ខ្លួន។

[37] ប្រការ ៥ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ

[38] ប្រការ ៧ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ

[39] ប្រការ ៨ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាតមូលបត្រ

# ជំពូកទី២

# បទល្មើសពាក់ព័ន្ធ នឹងការជួញដូរមូលបត្រ

ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនបានបែងចែក បទល្មើសពាក់ព័ន្ធ នឹងការជួញដូរជាបីប្រភេទធំៗ រួមមាន[40]៖

- ការជួញដូរផ្ទៃក្នុង (កថាខណ្ឌ១)
- ការជួញក្លែងក្លាយ និងប្រើឧបាយកលក្នុងទីផ្សារ កថាខណ្ឌទី២)
- សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស(កថាខណ្ឌទី៣)

## កថាខណ្ឌទី១៖ ការជួញដូរផ្ទៃក្នុង ( Insider Trading )

### ក. ការជួញដូរផ្ទៃក្នុងតាមច្បាប់កម្ពុជា

ដើម្បីធានានូវសមភាព និងសមធម៌រវាងអ្នកវិនិយោគសាធារណៈទាំងអស់នៅក្នុងការជួញដូរមូលបត្រ ដែលជាផ្នែកមួយចាំបាច់សម្រាប់រក្សាឱ្យបាននូវទំនុកចិត្តរបស់អ្នកវិនិយោគសាធារណៈ និងដើម្បីរក្សានូវកេរ្តិ៍ឈ្មោះរបស់ទីផ្សារមូលបត្រកម្ពុជាការជួញដូរផ្ទៃក្នុងត្រូវបានហាមឃាត់។ យោងតាមមាត្រា៤០ កថាខណ្ឌទី៣ នៃច្បាប់មូលបត្រមហាជន ការជួញដូរផ្ទៃក្នុងអាចកើតឡើងក្រោមរូបភាពពីរយ៉ាងដែលអាចជា ការឆ្លៀតប្រើប្រាស់ព័ត៌មានផ្ទៃក្នុង ឬជាការផ្តល់ព័ត៌មានផ្ទៃក្នុងឱ្យបុគ្គលដទៃ ដើម្បីធ្វើការជួញដូរមូលបត្រក្នុងគោលបំណងកេងយកចំណេញឬបញ្ចៀសការខាតបង់នឹងកំណត់ថាជាការជួញដូរផ្ទៃក្នុង។ ការជួញដូរមូលបត្រទាំងឡាយណាដែលធ្វើដោយអ្នកផ្ទៃក្នុងនិងដោយឆ្លៀតប្រើប្រាស់នូវព័ត៌មានផ្ទៃក្នុងទោះដោយផ្ទាល់ ឬដោយមិនផ្ទាល់ក្នុងគោលបំណងរកចំណេញ ឬបញ្ចៀសការខាតបង់ផ្ទាល់ខ្លួន នឹងត្រូវបានច្បាប់កំណត់ថា ជាការជួញដូរផ្ទៃក្នុងផងដែរ ការផ្តល់ព័ត៌មានផ្ទៃក្នុងទាំងឡាយដែលធ្វើដោយអ្នកផ្ទៃក្នុងដល់បុគ្គលណាមួយឬនីតិបុគ្គលប្រតិស្រុតណាមួយ ក្នុងគោលបំណងធ្វើឱ្យបុគ្គលនោះ ឬនីតិបុគ្គលប្រតិស្រុតនោះរកចំណេញឬបញ្ចៀសការខាតបង់។ ការផ្តល់ព័ត៌មាននេះ ត្រូវផ្តន្ទាទោសដោយមិនគិតអំពីលទ្ធផលនៃការផ្តល់ព័ត៌មាននេះនោះទេ។ មានន័យថា បើទោះបីជាអ្នកទទួលបានព័ត៌មានមិនបានប្រើប្រាស់នូវព័ត៌មាននោះក៏ដោយ អ្នកផ្ទៃក្នុងដែលផ្តល់ព័ត៌មាននោះនឹងត្រូវផ្តន្ទាទោសតាមការកំណត់របស់ច្បាប់។ ទង្វើនៃការផ្តល់ព័ត៌មានផ្ទៃក្នុងនេះទៅឱ្យបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសដូចគ្នាទៅនឹងការប្រើប្រាស់ព័ត៌មាន

[40] មាត្រា ៥៤ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ផ្ទៃក្នុងដើម្បីជួញដូរដោយផ្ទាល់ ឬដោយប្រយោលលើមូលបត្រដែលពាក់ព័ន្ធ។ ជាទូទៅបទល្មើសនៃការជួញដូរផ្ទៃក្នុង ត្រូវបានផ្សំឡើងដូចជា៖

**ធាតុផ្សំនៃបទល្មើសជួញដូរផ្ទៃក្នុង** [41] ដើម្បីចាត់ទុកថាជាការជួញដូរផ្ទៃក្នុង លុះត្រាតែជាការជួញដូរដែលធ្វើឡើងដោយអ្នកផ្ទៃក្នុង និងដោយប្រើប្រាស់ ឬដោយផ្តល់ឱ្យបុគ្គលណាម្នាក់នូវព័ត៌មានផ្ទៃក្នុង។ តើនរណាខ្លះត្រូវបានច្បាប់ចាត់ទុកថាជាអ្នកផ្ទៃក្នុង? ហើយអ្វីទៅជាព័ត៌មានផ្ទៃក្នុងនោះ? អ្នកផ្ទៃក្នុង និងព័ត៌មានផ្ទៃក្នុងត្រូវបានកំណត់ក្នុងមាត្រា ៤០ នៃច្បាប់មូលបត្រមហាជន។

**អ្នកផ្ទៃក្នុង**[42] ត្រូវបានកំណត់ដូចខាងក្រោម៖

### ១. លក្ខខណ្ឌ (បុគ្គលផ្ទៃក្នុង និងព័ត៌មានផ្ទៃក្នុង)

ការជួញដូរផ្ទៃក្នុង សំដៅដល់សកម្មភាពអ្នកផ្ទៃក្នុង ហើយអ្នកផ្ទៃក្នុងមិនត្រូវធ្វើដូចជា៖

- ឆ្លៀតប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដោយផ្ទាល់ឬ មិនផ្ទាល់ដើម្បីជួញដូរមូលបត្ររបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឬនីតិបុគ្គលប្រតិស្រុតិក្នុងគោលបំណងរកចំណេញ ឬបញ្ចៀសការខាតបង់ផ្ទាល់ខ្លួន។
- ផ្តល់ព័ត៌មានផ្ទៃក្នុងដល់បុគ្គលដ៏ទៃទៀតណាមួយ ឬនីតិបុគ្គលប្រតិស្រុតណាមួយក្នុងគោលបំណងធ្វើឱ្យបុគ្គលនោះឬ នីតិប្រតិស្រុតនោះ រកចំណេញ ឬបញ្ចៀសការខាតបង់។
- អគ្គនាយក នាយក គណៈគ្រប់គ្រង និងបុគ្គលិករបស់ក្រុមហ៊ុន ឬរបស់នីតិបុគ្គលប្រតិស្រុត និងភាគហ៊ុននៅក្នុងក្រុមហ៊ុន ឬនីតិបុគ្គលប្រតិស្រុតដែលកាន់កាប់យ៉ាងតិច៥% នៃក្រុមហ៊ុនមានសិទ្ធិបោះឆ្នោតនិងបុគ្គលដ៏ទៃទៀត ដែលមានទំនាក់ទំនងរវាងបុគ្គលនេះជាមួយ នឹងក្រុមហ៊ុនឬនីតិបុគ្គលប្រតិស្រុតបានផ្តល់ឱ្យខ្លួនមាន ឬទទួលបានព័ត៌មានសម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុនឬនីតិប្រតិស្រុត។
- ប្រធានសមាជិក អគ្គនាយក នាយក និងបុគ្គលិករបស់ គមក ទាំងអស់ និងមន្ត្រីពាក់ព័ន្ធដ៏ទៃទៀតរបស់រាជរដ្ឋាភិបាល ឬបុគ្គលិករបស់នីតិបុគ្គលដែលទទួលបានការអនុញ្ញាត ឬទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក** ឱ្យធ្វើជាអន្តរការីនៅក្នុងទីផ្សារមូលបត្រ ដែលមាន ឬទទួលបានអាជ្ញាបណ្ណ សម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុន ឬនីតិបុគ្គលប្រតិស្រុតិ ដោយសារតែតួនាទីរបស់ខ្លួន។ ទោះជាយ៉ាងណាមិញ តាមរយៈសាររបស់អគ្គនាយក ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បាន

[41] មាត្រា ៤០ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[42] មាត្រា ៤០ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ផ្ញើសារសាធារណៈជន អំពីបេសកម្មដ៏ចម្បងមួយរបស់ក្រុមហ៊ុននេះ ដែលបង្កើតឡើងនូវបរិយាកាសជួញដូរត្រូវប្រកបដោយ ភាពយុតិធម៌ តម្លាភាព និងភាពមានអំណោយផលដល់វិនិយោគិន ទាំងក្នុងនិងក្រៅប្រទេស។

**ព័ត៌មានផ្ទៃក្នុង** និយមន័យនៃព័ត៌មានផ្ទៃក្នុង គឺជាបញ្ហាចោទចំពោះអ្នកនីតិបញ្ញត្តិនៅក្នុងបណ្តាច្បាប់នានា ក្នុងគោលបំណងកំណត់ឱ្យបានច្បាស់លាស់នូវដែនកំណត់នៃបទល្មើសជួញដូរផ្ទៃក្នុង។ នៅក្នុងច្បាប់កម្ពុជា ព័ត៌មានផ្ទៃក្នុង សំដៅដល់ព័ត៌មានទាំងឡាយណាទាក់ទិននឹងមូលបត្រ ដែលត្រូវបានបោះផ្សាយ និងបានការបោះផ្សាយដោយក្រុមហ៊ុនមហាជនដែលទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ហើយព័ត៌មានទាំងនោះមិនទាន់ផ្សព្វផ្សាយជាទូទៅ ប៉ុន្តែព័ត៌មានទាំងនោះដឹងដល់សាធារណជន អាចធ្វើអោយមានផលប៉ះពាល់ខ្លាំងដល់តម្លៃ ឬទិដ្ឋភាពជួញដូរដទៃទៀតរបស់មូលបត្រទាំងនោះ។ ហេតុដូចនេះ ព័ត៌មានផ្ទៃក្នុងជាព័ត៌មានទាំងឡាយណាដែលមានឥទ្ធិពលទៅលើតម្លៃនៃមូលបត្រដែលជួញដូរនៅលើទីផ្សារហើយជាព័ត៌មានដែលមិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈស្របតាមនីតិវិធី ដែលកំណត់ដោយបទប្បញ្ញត្តិជាធរមាន។ មាត្រា៣៦ កថាខណ្ឌទី៣ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់មូលបត្រមហាជនបានបញ្ជាក់បន្ថែមយ៉ាងច្បាស់ថា ព័ត៌មានណាមួយត្រូវបានចាត់ទុកជាព័ត៌មានដែលបានផ្សព្វផ្សាយជាសាធារណៈ ប្រសិនបើព័ត៌មាននោះអាចពិនិត្យមើលបានគ្រប់ពេលដោយសាធារណជន ឬសេចក្តីសន្និដ្ឋានដែលអាចឱ្យសាធារណៈជនទាញយកមកប្រើប្រាស់បាន។ ដោយឡែកព័ត៌មានណាមួយ ដែលអាចប៉ះពាល់ដល់ថ្លៃនៃមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ប្រសិនបើព័ត៌មាននោះអាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គលក្នុងការជួញដូរផ្ទៃក្នុងមូលបត្រ។

**អាកប្បកិរិយាដែលត្រូវបានហាមឃាត់ចំពោះអ្នកផ្ទៃក្នុង** អ្នកផ្ទៃក្នុងទាំងឡាយដែលទទួលបានព័ត៌មានផ្ទៃក្នុង មិនត្រូវឆ្លៀតប្រើប្រាស់ព័ត៌មានផ្ទៃក្នុងនោះ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដើម្បីធ្វើការជួញដូរលើមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ក្នុងគោលបំណងរកចំណេញឬបញ្ចៀសការខាតបង់ផ្ទាល់ខ្លួន ឬមិនត្រូវផ្តល់ព័ត៌មានផ្ទៃក្នុងនេះទៅឱ្យបុគ្គលណាម្នាក់ក្នុងគោលបំណងឱ្យបុគ្គលនោះអាចរកចំណេញ ឬបញ្ចៀសការខាតបង់ពីការជួញដូរមូលបត្រដែលពាក់ព័ន្ធ។

ច្បាប់បានបញ្ញត្តិយ៉ាងទូលំទូលាយនូវបញ្ជីរាយនាមអ្នកផ្ទៃក្នុង។ ពាក្យ (បុគ្គលដ៏ទៃទៀត) អាចអនុញ្ញាតអោយមានការបកស្រាយយ៉ាងទូលំទូលាយ ហើយនឹងធ្វើការផ្តន្ទាទោសចំពោះរាល់បុគ្គលទាំងអស់ដែលមានលទ្ធភាពទទួលបានព័ត៌មានផ្ទៃក្នុង ដោយសារតែទំនាក់ទំនងរបស់ខ្លួនជាមួយនឹងក្រុមហ៊ុនបោះផ្សាយមូលបត្រ ( ដូចជាមេធាវី សវនការគណនី ឬធនាគារជាដើមដែលពាក់ព័ន្ធទៅនឹងដំណើរការបោះផ្សាយលក់មូលបត្រសាធារណៈនៅលើទីផ្សារ ឬក៏តតិយជនផ្សេងទៀតដែល

មានទំនាក់ទំនងអាជីវកម្មជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ) ឬដោយសារតែតួនាទីរបស់ខ្លួននៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ។

### ២. ទណ្ឌកម្មនៃបទល្មើសជួញដូរផ្ទៃក្នុង

បុគ្គលដែលប្រព្រឹត្តដោយចេតនានូវបទល្មើស ជួញដូរផ្ទៃក្នុងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់១០(ដប់)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល។

នីតិបុគ្គល ដែលប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០.០០០.០០០ (ហាសិបលាន) រៀល ដល់ ១.០០០.០០០.០០០ ( មួយពាន់លាន) រៀល។

### ខ. ការជួញដូរផ្ទៃក្នុងតាមច្បាប់បរទេស (**ករណីសហរដ្ឋអាមេរិក**)

ដោយយោងទៅតាម Securities Exchange Act1934បទល្មើសក្នុងវិស័យមូលបត្រត្រូវបានចែងចែកជា៣ធំៗ រួមមាន៖

- ការជួញដូរផ្ទៃក្នុង (Insider trading)
- ការរៀបចំឧបាយកលក្នុងទីផ្សារ (Market Manipulation)
- សេចក្តីថ្លែងការណ៍ក្លែងបន្លំ និងនាំអោយយល់ខុស ( False and Misleading Statement )

### ១. លក្ខខណ្ឌនៃការជួញដូរផ្ទៃក្នុង[43] ( Insider Trading )

បទល្មើសការជួញដូរផ្ទៃក្នុង នៅក្នុងសហរដ្ឋអាមេរិក គឺសំដៅដល់ការទិញ ឬលក់មូលបត្រដែលបានចុះបញ្ជី ដោយមានការទាញផលប្រយោជន៍ពីអ្នកដទៃដោយការប្រើប្រាស់ព័ត៌មានអំពីតម្លៃមូលបត្រដែលមិនទាន់ចេញផ្សព្វផ្សាយជាសារធារណៈ។ ការជួញដូរផ្ទៃក្នុងក៏អាចរាប់បញ្ចូលផងដែរ ក្នុងការផ្តល់ព័ត៌មានផ្ទៃក្នុងដល់បុគ្គលដទៃណាមួយ ឬនីតិបុគ្គលប្រតិស្រុតណាមួយ ក្នុងគោលបំណងធ្វើអោយបុគ្គលនោះ ឬនីតិប្រតិស្រុតនោះ រកចំណេញ ឬបញ្ចៀសការខាតបង់ ដោយការផ្តល់ព័ត៌មានផ្ទៃក្នុង។

ច្បាប់របស់សហរដ្ឋអាមេរិកបានកំណត់បុគ្គល ដែលត្រូវចាត់ទុកថាជាអ្នកផ្ទៃក្នុងប្រហាក់ប្រហែលនឹងច្បាប់កម្ពុជាដែរប៉ុន្តែមានលក្ខណៈទូលំទូលាយជាងដែលមានដូចជា៖

១. នាយក នាយកគ្រប់គ្រង និងអ្នកដែលត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការណ៍ ឬសវនកររបស់ក្រុមហ៊ុនដែលបានយល់ដឹងអំពីការការជួញដូរមូលបត្រ។

[43] Securities Exchange Act 1934

២. មិត្តភ័ក្តិ, ក្រុមហ៊ុនរកស៊ី, សមាជិកគ្រួសារ និងផ្សេងទៀត ដែលបានជួញដូរមូលបត្រនៅពេលដែលទទួលបានព័ត៌មានពីនាយក ឬបុគ្គលិក។

៣. មន្ត្រីសាជីវកម្ម, ធនាគារ និងក្រុមហ៊ុនសាជីវកម្ម ដែលបានជួញដូរមូលបត្រដោយផ្អែកលើព័ត៌មានដែលទទួលបានក្នុងការតភ្ជាប់ជាមួយការផ្តល់សេវាកម្មសាជីវកម្ម ដែលមានមូលបត្រដែលបានជួញដូរ។

៤. មន្ត្រីរដ្ឋាភិបាល ដែលបានជួញដូរដោយផ្អែកលើព័ត៌មានសម្ងាត់ដែលពួកគេបានរៀនដោយសារការងារជាមួយរដ្ឋាភិបាល។

៥. អ្នកប្រឹក្សាយោបល់ផ្នែកនយោបាយដែលផ្តល់ជំនួយ ឬពាណិជ្ជកម្មផ្អែកលើព័ត៌មានសម្ភារៈ និងព័ត៌មានដែលមិនទាន់ផ្សព្វផ្សាយជាសារធារណៈ ដែលទទួលបានពីមន្ត្រីរដ្ឋាភិបាល និងអ្នកកាន់កាប់មូលបត្ររបស់ក្រុមហ៊ុន ដែលមូលបត្រត្រូវបានចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រឬត្រូវបានជួញដូរ ឬត្រូវបានជួញដូរ តម្លស្មើនឹងច្រើនជាង ១០% នៃដើមទុនដែលបានចុះបញ្ជី។

៦. មនុស្សមួយចំនួនផ្សេងទៀតដែលការលួចបន្លំ និងទាញយកអត្ថប្រយោជន៍អំពីព័ត៌មានសម្ងាត់ពីបុគ្គលិក ក្រុមគ្រួសារ មិត្តភក្តិ និងអ្នកដ៏ទៃ។

ដោយសារ តែការជួញដូរផ្ទៃក្នុងបានធ្វើអោយប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកវិនិយោគ និងយុត្តិធម៌ និងភាពសុចរិតនៃទីផ្សារមូលបត្រ ទើប SEC បានចាត់វិធានការ និងដាក់ទោសចំពោះការរំលោភបំពានក្នុងវិស័យមូលបត្រ។

### ២. ទណ្ឌកម្ម[44]

ក្នុងករណីដែលមានការរំលោភបំពានលើការហាមឃាត់លើការជួញដូរផ្ទៃក្នុង មានទោសពីរគឺទោសព្រហ្មទណ្ឌនិងទោសរដ្ឋប្បវេណីសម្រាប់បុគ្គលនិងនីតិបុគ្គលដែលប្រព្រឹត្តបទល្មើស។

សម្រាប់រូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសជួញដូរផ្ទៃក្នុង ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារអតិបរមា ២០ឆ្នាំ និងពិន័យជាប្រាក់អតិបរមា ៥.០០០.០០០$ (ប្រាំលានដុល្លារ) និងពិន័យជាប្រាក់អតិបរមា ២៥.០០០.០០០$ (ម្ភៃប្រាំលានដុល្លារ) សម្រាប់នីតិបុគ្គល។

**ករណីសិក្សា**[45]

**របាយការណ៍ស្តីពីការពង្រីកការស៊ើបអង្កេតលើករណីការជួញដូរផ្ទៃក្នុងរបស់សហរដ្ឋអាមេរិក ដែលបានចុះផ្សាយក្នុងគេហទំព័រព័ត៌មាន Bloomberg ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២**

[44] Hazen Federal Securities Law

[45] https://www.sec.gov/litigation/complaints/2019/comp-pr2019-10.pdf

រដ្ឋាភិបាលសហរដ្ឋអាមេរិកបានបញ្ជាក់ថាបានធ្វើការស៊ើបអង្កេតរយៈពេល ៥ឆ្នាំ លើករណីនៃការជួញដូរផ្ទៃក្នុងនៅ Wall Street ដែលចោទប្រកាន់ចំពោះអ្នកជួញដូរលើ Hedge-fund តាមរយៈការប្រើប្រាស់ព័ត៌មានខុសច្បាប់ដើម្បីទទួលបានប្រាក់រាប់លានដុល្លារ។

មានការចោទប្រកាន់កាលពីពេលថ្មីៗនេះ ដែលពាក់ព័ន្ធនឹងមិត្តភ័ក្តិមួយក្រុមដែលបានបង្កើតក្រុមឧក្រិដ្ឋកម្មមួយក្នុងគោលបំណងរកប្រាក់ចំណេញ ហើយដែលសមាជិកក្រុមនេះតែងតែផ្លាស់ប្តូរនូវព័ត៌មានផ្ទៃក្នុង។ ក្រុមមិត្តភ័ក្តិទាំងនេះសុទ្ធតែធ្លាប់ធ្វើការ និងរស់នៅក្នុងទីក្រុង San Francisco ក្នុងឆ្នាំ២០០៦ នេះបើយោងតាមពាក្យបណ្តឹងរបស់គណៈកម្មការមូលបត្រសហរដ្ឋអាមេរិក។

Sandeep Goyal ដែលជាអ្នកធ្លាប់ធ្វើការឱ្យក្រុមហ៊ុន DELL បានចែករំលែកទិន្នន័យជាមួយលោក Jesse Tortora ដែលជាអ្នកវិភាគឱ្យក្រុមហ៊ុន Diamondback Capital Management។ Goyal ក៏បានបញ្ជូនទិន្នន័យនោះទៅប្រធានរបស់ខ្លួនឈ្មោះ Todd Newman និងទៅមិត្តភ័ក្តិរបស់គាត់ម្នាក់ឈ្មោះ Danny Kuo ដែលក្រោយមកធ្វើការនៅ South Pasadena ក្នុងការិយាល័យ Hedge fund មួយ។ ក្រុមហ៊ុន Diamondback បានបង្កើតទឹកប្រាក់ប្រមាណ ៣,៨ លានដុល្លារអាមេរិក លើការជួញដូរព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន DELL។

Jesse Tortora ដែលមានទទួលព័ត៌មានពី Goyal នោះ បានបញ្ជូនព័ត៌មានទៅឱ្យប្រធានរបស់ខ្លួនឈ្មោះ Jon Horvath ហើយបន្ទាប់មកមានអ្នកគ្រប់គ្រងទុនវិនិយោគនៅក្នុងក្រុមហ៊ុន SAC ម្នាក់ដែលមិនត្រូវបានកំណត់អត្តសញ្ញាណ បានជួញដូរលើព័ត៌មាននោះ និងបានបង្កើតទឹងប្រាក់ប្រមាណជា ១លានដុល្លារអាមេរិក។ ចំណែក Spyridon Adondakis ធ្វើការឱ្យក្រុមហ៊ុន Level Global ដែលជាមិត្តភ័ក្តិរបស់ Goyal និងបានទទួលនូវព័ត៌មាននោះផងដែរ បានបញ្ជូនព័ត៌មាននោះទៅប្រធានរបស់ខ្លួនគឺលោក Anthony Chiasson និងអ្នកជាប់ពាក់ព័ន្ធផ្សេងទៀតនៅក្នុងក្រុមហ៊ុន New York-based Level Global ដែលបានបង្កើតទឹកប្រាក់ប្រមាណ ៥៧លានដុល្លារអាមេរិក។

លោក Anthony Chiasson ដែលជាសហស្ថាបនិក Level Global Investors LP ជាមួយនឹង David Ganek នៅក្នុងឆ្នាំ២០០៣ ត្រូវបានដាក់ឱ្យនៅជាប់ឃុំ។ គាត់បានជួយបង្កើត New York-based Level Global ទៅក្នុងក្រុមហ៊ុនមួយដែលមានទឹកប្រាក់ ៤ពាន់លានដុល្លារ មុនការធ្វើការបិទក្រុមហ៊ុននេះក្នុងខែកុម្ភៈឆ្នាំមុនដោយសារតែមានការអង្កេត (Probe)។ យោងតាមពាក្យបណ្តឹងលោក Chiasson និងអ្នកផ្សេងទៀតដែលបានបង្កើតមូលនិធិប្រមាណ ៥៧ លានដុល្លារ លើការជួញដូរខុសច្បាប់លើក្រុមហ៊ុន Dell Inc. (DELL) និងបានអះអាងថាក្នុងគម្រោងមានរហូតដល់ ៦១,៨ លានដុល្លារឯនោះ។

រដ្ឋាភិបាលក៏បានចាប់ខ្លួនលោក Jon Horvath ដែលជាអ្នកវិភាគបច្ចេកទេសនៅក្រុមហ៊ុន SAC Capital's Sigma Capital Management Unit. លោក Horvath មានអាយុ ៤២ឆ្នាំ ត្រូវបានចោទប្រកាន់ពីបទជួញដូរលើព័ត៌មានផ្ទៃក្នុង ដែលត្រូវបានផ្តល់ដោយនិយោជិតរបស់ក្រុមហ៊ុន DELL ខណៈដែលកំពុងធ្វើការនៅក្រុមហ៊ុន SAC។ មេធាវីរបស់លោក Horvath បាននិយាយថា Horvath បានចំណាយពេលជាង១០ឆ្នាំក្នុងការងារជាអ្នកវិភាគវិនិយោគដែលគាត់បានរៀបចំខ្លួនគាត់ ប្រកបដោយភាពស្មោះត្រង់ និងសុចរិតភាព។ មេធាវីរូបនោះបានគូសបញ្ជាក់ថា លោក Horvath មិនបានប្រព្រឹត្តអ្វីខុសឡើយហើយការចោទប្រកាន់លើរូបគាត់នឹងស្តែងឱ្យឃើញពីស្ថានភាពមួយគួរឱ្យសោកស្តាយ។

Robert Khuzami ប្រធានការិយាល័យ ធ្វើការពង្រឹងការអនុវត្តច្បាប់នៃគណៈកម្មការមូលបត្រសហរដ្ឋអាមេរិក បានគូសបញ្ជាក់ថា ការប្រព្រឹត្តខុសច្បាប់ដែលបានចោទប្រកាន់ក្នុងពាក្យបណ្តឹងនៅពេលនេះ គឺមិនមែនត្រឹមតែប្រព្រឹត្តដោយបុគ្គលតូចតាចនៅក្នុងវិស័យប្រឹក្សាវិនិយោគ ប៉ុន្តែគឺជាអ្នកវិនិយោគលើ Hedge-fund ធំបំផុត និងមានភាពវ័យឆ្លាតបំផុតនៅក្នុងសហរដ្ឋអាមេរិក។

## កថាខណ្ឌទី២៖ ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ

### ក. ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារតាមច្បាប់កម្ពុជា

### ១. លក្ខខណ្ឌនៃបទល្មើស[46]

ដោយសារការជួញដូរមូលបត្រនៅលើទីផ្សារ ងាយទទួលរងពីការប្រើប្រាស់ឧបាយកលនៅលើទីផ្សារ និងការបោកបញ្ឆោតនានា ដែលការណ៍នេះតម្រូវឱ្យនិយតករមូលបត្រនៃប្រទេសកម្ពុជាក៏ដូចជាប្រទេសដ៏ទៃទៀត គឺយកចិត្តទុកដាក់និងបង្កើតបទបញ្ញត្តិផ្សេងៗ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងអំពើក្លែងបន្លំនានានៅលើទីផ្សារមូលបត្រ។

ការជួញដូរក្លែងក្លាយ និងការប្រើប្រាស់ឧបាយកលក្នុងទីផ្សារ (False Trading and Market Manipulation) ទោះបីជាដោយចេតនា ឬដោយធ្វេសប្រហែសក្តី បុគ្គលមិនត្រូវ៖

១. ធ្វើសកម្មភាពណាមួយដែលបណ្តាលឱ្យ ឬគេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឱ្យឬអាចបណ្តាលឱ្យមានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុសចំពោះការជួញដូរមូលបត្រ ដែលគេកំពុងជួញដូរនៅលើផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២. ធ្វើប្រតិបត្តិការ ឬផែនការជួញដូរមូលបត្រដែលមានលក្ខណៈសិប្បនិម្មិតទាក់ទងនឹងមូលបត្រហើយប្រសិនបើប្រតិបត្តិនោះបណ្តាលឱ្យ៖

[46] មាត្រា ៤២ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- តម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជានៅថេរកើនឡើង ឬស្រុតចុះ។
- ចលនាដែលមានការឡើងចុះតម្លៃនៃការជួញដូរមូលបត្រ ដែលមាននៅលើទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**២. ទណ្ឌកម្ម**[47]

បុគ្គលដែលប្រព្រឹត្តដោយចេតនាល្មើស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ (ហាសិបលាន) រៀល ដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល។

**ខ. ការរៀបចំឧបាយកលក្នុងទីផ្សារតាមច្បាប់បរទេស** [48] (Market Manipulation) (**ករណីសហរដ្ឋអាមេរិច**)

ការរៀបចំឧបាកលក្នុងទីផ្សារ ជាទូទៅសំដៅទៅលើការប៉ុនប៉ុងដោយចេតនាក្នុងការជ្រៀតជ្រៀនៅក្នុងទីផ្សារមូលបត្រ។ ការរៀបចំឧបាយលក្នុងទីផ្សារជាមធ្យោបាយមួយដោយលួយបន្លំប្រាក់ចំណេញពីអ្នកវិនិយោគដោយការបោកបញ្ឆោត និង ជាអំពីមួយដែលធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់សាធារណៈក្នុងជួញដូរទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

**១. លក្ខខណ្ឌនៃបទល្មើស**[49]

ច្បាប់របស់សហរដ្ឋអាមេរិកបានកំណត់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលត្រូវចាត់ទុកថាអ្នករៀបចំឧបាយកលក្នុងទីផ្សារ ដែលមានលក្ខណៈខុសពីច្បាប់ប្រទេសកម្ពុជា គឺបានកំណត់តែចំពោះរូបវន្តបុគ្គលតែប៉ុណ្ណោះ តែច្បាប់សហរដ្ឋអាមេរិកវិញបានកំណត់ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលហើយ និងសកម្មភាពក្នុងការរៀបចំឧបាយកលក្នុងទីផ្សារមានលក្ខណៈខុសគ្នាដាច់ ដែលមានដូចជា៖

ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារកើតមានឡើងនៅពេលដែលបុគ្គល ឬក្រុមហ៊ុន៖

[47] មាត្រា៥៩ នៃច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

[48] Securities Exchange Act 1934

[49] https://study.com/academy/lesson/what-is-market-manipulation.html#/partialRegFormModal

១. ប៉ុនប៉ងដាក់ទិញលក់មូលបត្រ ក្នុងការបញ្ជាទិញក្នុងតម្លៃដូចគ្នា ក្នុងគោលបំណងដើម្បីជំរុញទំហំជួញដូរ ធ្វើឱ្យភាគហ៊ុនមើលទៅគួរឱ្យចាប់អារម្មណ៍បន្ថែមទៀតដល់វិនិយោគិនដ៏ទៃទៀតបង្កើនតម្លៃ

២. បង្កើតសកម្មភាព ឬពាក្យចចាមអារាម ដើម្បីជំរុញតម្លៃនៃភាគហ៊ុនមួយ (ហៅកាត់ថា Runs or Ramping)

៣. លាងសម្អាតការជួញដូរ ការលក់ និងការទិញមូលបត្រឡើងវិញនៅតម្លៃដូចគ្នា

៤. ប៉ុនប៉ងបញ្ចុះតម្លៃភាគហ៊ុនក្នុងការជួញដូរមូលបត្រក្នុងរយៈពេលខ្លី

៥.ការទិញភាគហ៊ុនពិសេសៗ ឬទ្រព្យសម្បត្តិផ្សេងទៀតដើម្បីទទួលបានការគ្រប់គ្រងនៃការផ្គត់ផ្គង់ និងអាចកំណត់តម្លៃភាគហ៊ុននៅលើទីផ្សារមូលបត្រ

៦. ការជួញដូរផ្ទៃក្នុងនៅពេលដែលមានអ្នកទទួលព័ត៌មានសម្ងាត់អំពីក្រុមហ៊ុនដោយទាញយកព័ត៌មាននេះ ដើម្បីរកប្រាក់ចំណេញឬចៀសវាងការខាតបង់ពីការទិញ ឬលក់ភាគហ៊ុនរបស់ពួកគេ។

## ២. ទណ្ឌកម្ម[50]

ការពិន័យនៅក្នុងច្បាប់សហរដ្ឋអាមេរិកមានលក្ខណៈខុសៗគ្នា ដូចជាការដាក់ទណ្ឌកម្មផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ ត្រូវបានប្រើប្រាស់ដើម្បីប្រយុទ្ធ ប្រឆាំងនឹងការប្រើឧបាយកលក្នុងទីផ្សារ។ ទោសព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ត្រូវបានកំណត់ដូចខាងក្រោម៖

១. ចំពោះជនណាដែលប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ៥ឆ្នាំ និងពិន័យជាប្រាក់ ១០០.០០០ ដុល្លារ

២. ចំពោះជនណាធ្វើពាណិជ្ជកម្ម និងការជួញដូរមូលបត្រដែលត្រូវបានហាមឃាត់ ត្រូវជាប់ពន្ធនាគារមិនលើសពី ៥ ឆ្នាំ និងពិន័យជាប្រាក់ ១០០.០០០ ដុល្លារ ឬក៏ទាំងពីរ

៣. ចំពោះនីតិបុគ្គលដែលប្រព្រឹត្តបទល្មើសត្រូវជាប់ពន្ធនាគាររយៈពេល ២០ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២៥០ ០០០ដុល្លារ។

**ករណីសិក្សា**[51]

**ករណីក្រុមហ៊ុន Montgomery Street Research**

នៅចុងឆ្នាំ២០១៤ សកម្មភាពប្រព្រឹត្តរបស់ក្រុមហ៊ុន Montgomery Street Researchម្ចាស់ក្រុមហ៊ុនបានរៀបរាប់អំពីការរៀបចំឧបាយកលក្នុងទីផ្សារ ពេលដាក់លក់អោយវិនិយោគិន។

[50] Hazen Federal Securities Law
[51] https://www.classlawgroup.com/securities-fraud/stock/market-manipulation/examples/

បន្ទាប់មកមានក្រុមហ៊ុនមួយបានជួលក្រុមហ៊ុន Montgomery ជាលក្ខណៈឯកជនសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្រោយមកម្ចាស់ក្រុមហ៊ុន Montgomery ត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងការលាងសម្អាតប្រាក់ ដែលពាក់ព័ន្ធក្នុងការទិញលក់មូលបត្រភ្លាមៗ ដែលមិនបានផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។

គណៈកម្មការមូលបត្រ (SEC) បានធ្វើការចោទប្រកាន់ក្រុមហ៊ុន Montgomery បានធ្វើប្រតិបត្តការលាងសម្អាតប្រហែល១០០កន្លែងដែលបញ្ជាទិញ-លក់មូលបត្រចេញក្នុងរយៈពេល៩០នាទី។ គណៈកម្មការមូលបត្រត្រូវបានបញ្ជាក់ថា តម្លៃនៃការដាក់ទិញ-លក់ស្មើតែមានតម្លៃដូចគ្នាទាំងអស់។

## កថាខណ្ឌទី៣៖ សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស

### ក. សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុសតាមច្បាប់កម្ពុជា[52] ( False and Misleading Statement )

ទីផ្សារមូលបត្រ គឺជាទីផ្សារដែលពឹងផ្អែកទៅលើការប្រមើលទុកជាមុននូវហេតុការណ៍ដែលនឹងកើតឡើងនាពេលអនាគត។ ដើម្បីធ្វើការប្រមើលទុកជាមុនបាន លុះត្រាតែអ្នកចូលរួមទាំងអស់មានព័ត៌មានច្បាស់លាស់ទាក់ទងនឹងក្រុមហ៊ុន និងព័ត៌មានផ្សេងទៀត។ ហេតុដូចនេះ ព័ត៌មានគឺជាធាតុដែលសំខាន់បំផុតនៅលើទីផ្សារមូលបត្រ។ ការវិភាគនៅលើព័ត៌មានទាំងឡាយអាចធ្វើឱ្យប៉ះពាល់ដល់តម្លៃរបស់មូលបត្រ។ ដូចនេះ ព័ត៌មានដែលផ្សព្វផ្សាយត្រូវតែជាព័ត៌មានច្បាស់លាស់ត្រឹមត្រូវ។ ការផ្សព្វផ្សាយនូវព័ត៌មានមិនពិត ក្លែងបន្លំ ឬនាំឱ្យយល់ខុស ត្រូវបានផ្តន្ទាទោសដោយច្បាប់។ នឹងត្រូវផ្តន្ទាទោសដូចគ្នា បើទោះបីជាទង្វើនេះត្រូវធ្វើឡើងដោយចេតនា ឬដោយអចេតនាក្តី ហើយទោះបីជាធ្វើឡើងដោយប្រើប្រាស់នូវមធ្យោបាយណាក៏ដោយ។

#### ១. លក្ខខណ្ឌនៃបទល្មើស

ច្បាប់បានបញ្ញត្តិថារាល់បុគ្គលទាំងអស់មិនត្រូវធ្វើសេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំប្រសិនបើ៖

១. សេចក្តីថ្លែង ឬការផ្សព្វផ្សាយនោះបើមានលក្ខណៈក្លែងបន្លំ ឬមានលក្ខណៈនាំឱ្យយល់ខុសធ្ងន់ធ្ងរ។

[52] ៨២នៃច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

២. សេចក្តីថ្លែង ឬការផ្សព្វផ្សាយ ព័ត៌មានទាំងនោះអាចៈ

- បណ្តាលឱ្យសាធារណជននៅក្នុងប្រទេសកម្ពុជា ទិញឬលក់ មូលបត្រ ឬ
- បណ្តាលឱ្យមានការកើនឡើង ការថយចុះ ឬការនៅថេរចំពោះតម្លៃនៃការជួញដូរមូលបត្រ ដែលជួញដូរនៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា។

៣. នៅពេលដែលបុគ្គលនោះធ្វើសេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានៈ

- បុគ្គលនោះមិនគិតថា សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មាននោះពិត ឬក្លែងបន្លំ ឬ
- បុគ្គលនោះដឹង ឬ គួរដឹងថា សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មាននោះ គឺក្លែងបន្លំ និងមានលក្ខណៈធ្វើឱ្យយល់ខុស។

### ២. ទណ្ឌកម្ម[53]

បុគ្គលដែលបានប្រព្រឹត្តដោយចេតនាល្មើសនឹងប្បញ្ញត្តិ នៃមាត្រា៤០ នៃ កថាខណ្ឌទី៣ មាត្រា ៤២ នៃច្បាប់ស្តីពីការបោះផ្សាយ និង ការជួញដូរមូលបត្រមហាជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូច មានចែងក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល។

## ខ.សេក្តីថ្លែងការណ៍ក្លែងបន្លំ និងនាំអោយយល់ខុស ( False and Misleading Statement )[54] (**ករណីសហរដ្ឋអាមេរិច**)

### ១. លក្ខខណ្ឌនៃបទល្មើស[55]

ព័ត៌មានដែលផ្សព្វផ្សាយត្រូវតែជាព័ត៌មានច្បាស់លាស់ត្រឹមត្រូវ។ ការផ្សព្វផ្សាយនូវព័ត៌មានមិនពិត ក្លែងបន្លំ ឬនាំឱ្យយល់ខុស ត្រូវបានផ្តន្ទាទោសដោយច្បាប់។ នឹងត្រូវផ្តន្ទាទោសដូចគ្នាបើទោះបីជាទង្វើនេះត្រូវធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោលក្តីហើយទោះបីជាធ្វើឡើងដោយប្រើ

[53] មាត្រា ៥៣នៃច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន

[54] Securities Exchange Act 1934

[55] https://www.classlawgroup.com/securities-fraud/stock/misleading-statements/

ប្រាស់នូវមធ្យោបាយណាក៏ដោយ។ សេក្តីថ្លែងការណ៍អំពីមូលបត្រនាំឱ្យមានការយល់ខុសកើតឡើងក្រោមរូបភាពដូចជា៖

- ការក្លែងបន្លំ លាក់បាំងដោយប្រើឧបាយកល, រៀបចំគម្រោងទុកមុននៅព័ត៌មានមិនពិតក្នុងការជួញដូរមូលបត្រ
- ធ្វើសេចក្តីថ្លែងការណ៍ក្លែងបន្លំដែលមិនសុចរិត
- ធ្វើការក្លែងបន្លំដោយការសរសេរក្លែងក្លាយ ឬផ្តល់ឯកសារក្លែងក្លាយ

### ២.ទណ្ឌកម្ម[56]

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើស ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ៥ ឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ២៥០.០០០ ដុល្លារ។ ចំពោះនីតិបុគ្គលដែលប្រព្រឹត្តបទល្មើសត្រូវជាប់ពន្ធធនាគារ៨ឆ្នាំ និងពិន័យជាប្រាក់៥០០.០០០ ដុល្លារ។

**ករណីសិក្សា** [57]

**បណ្តឹងរបស់គណៈកម្មការមូលបត្រសហរដ្ឋអាមេរិក**

ករណីនេះពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ក្លែងបន្លំ ឬនាំឱ្យយល់ខុសដែលប្រពឹត្តិដោយលោក Elon Musk ដែលជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុនTesla,Inc. នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៨ ទាក់ទងនឹងការចង់ដកក្រុមហ៊ុនTesla ពីទីផ្សារលក់ភាគហ៊ុនដើម្បីឱ្យក្រុមហ៊ុនផលិតរថយន្តក្លាយជាក្រុមហ៊ុនឯកជនវិញ។ សេចក្តីថ្លែងការណ៍ដែលមានរបស់លោក Musk ដែលត្រូវបានធ្វើការផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម Twitter ចំពោះព័ត៌មានដែលមិនពិតដោយលោកអាចដាក់ក្រុមហ៊ុនTesla ជាលក្ខណៈឯកជន ក្នុងតម្លៃដែលបង្ហាញពីការធានារ៉ាប់រងលើតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុននៅពេលនោះថាមានមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ ដែលមានទឹកប្រាក់រាប់ពាន់លានដុល្លារនេះត្រូវបានធានាហើយមានសមភាពចំពោះតែការបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុន។តាមការពិតលោក Musk មិនបានពិភាក្សាសូម្បីតែបន្តិចពីកិច្ចព្រមព្រៀងសំខាន់ៗរួមទាំងតម្លៃជាមួយនឹងប្រភពណាមួយដែលមានសក្តានុពលផ្តល់ថវិកានោះ។

នៅប្រហែលម៉ោង ១២:៤៨ រសៀល ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៨ ក្នុងអំឡុងពេលនោះ Musk បានបង្ហោះសារ Twitter ទៅអ្នកតាមដានរបស់គាត់ដែលមានចំនួនជាង ២២ លាននាក់ថា "ខ្ញុំកំពុងពិចារណាយកTesla ជាឯកជនក្នុងតម្លៃ៤២០ដុល្លារ។

[56]Securities Exchange Act 1933

[57] https://www.sec.gov/litigation/complaints/2019/comp-pr2019-10.pdf

ដោយមានការផ្តល់មូលនិធិមានសុវត្ថិភាព ។ សេចក្តីថ្លែងការណ៍នេះគឺមិនពិត និងបោកប្រាស់។

ពីរម៉ោងបន្ទាប់ លោកក៏បានបន្ថែមទៀតថា ៖

- ក្តីសង្ឃឹមរបស់ខ្ញុំគឺបណ្តាអ្នកវិនិយោគទាំងអស់ដែលបាននៅជាមួយ Tesla ទោះបីជា ក្រុមហ៊ុនមានលក្ខណៈឯកជនមែនតែពួកយើង នឹងបង្កើតមូលនិធិពិសេសក្នុងគោលបំណងអនុញ្ញាតឱ្យអ្នកគ្រប់គ្នានៅជាមួយTesla។
- ម្ចាស់ភាគហ៊ុនអាចលក់នៅក្នុងតម្លៃ ៤២០ ដុល្លារក្នុងមួយភាគហ៊ុន ឬកាន់ភាគហ៊ុននិងប្តូរទៅជាឯកជន។
- ការគាំទ្រអ្នកវិនិយោគត្រូវបានបញ្ជាក់។ ហេតុផលតែម្យ៉ាងគឺ ហេតុអ្វីបានជាមិនប្រាកដថាវាជាការរំពឹងទុកលើការបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុន។

លោក Musk មិនបានប្រុងប្រយ័ត្នដោយមិនដឹងថាមួយក្នុងចំណោមសេចក្តីថ្លែង ការណ៍របស់គាត់ជាព័ត៌មានមិនពិត និង/ ឬ ជាការបោកបញ្ឆោតដោយហេតុតែគាត់មិនមាន មូលដ្ឋានគ្រប់គ្រាន់សម្រាប់ការពិតចំពោះអំណះអំណាងរបស់លោក។ នៅពេលដែលគាត់ធ្វើ សេចក្តីថ្លែងការណ៍ទាំងនោះ លោកបានដឹងថាខ្លួនមិនបានធ្វើការពិភាក្សា នូវប្រតិបត្តិការប្តូរទៅជា ឯកជនក្នុងតម្លៃ ៤២០ ដុល្លារ ក្នុងមួយហ៊ុនជាមួយនឹងប្រភពដែលបានផ្តល់មូលនិធិណាមួយទេ។ ហើយលោកមិនបានធ្វើអ្វីមួយដើម្បីស៊ើបអង្កេតថាតើអ្នកវិនិយោគអាចនៅជាមួយនឹងក្រុមហ៊ុនឯកជនមួយតាមរយៈ "ការផ្តល់ជូនមូលនិធិពិសេស" និងមិនបានបញ្ជាក់ពីការគាំទ្ររបស់អ្នកវិនិយោគ Tesla សម្រាប់ការធ្វើប្រតិបត្តិការនេះផងដែរ។ ជាងនេះ គាត់បានដឹងថាគាត់មិនបានបំពេញនូវ សមភាពជាច្រើនដែលជាដំណោះស្រាយមិនពិតច្បាស់លាស់ ក៏ប៉ុន្តែគាត់បានប្រកាសយ៉ាងច្បាស់ ហើយថា "មូលហេតុនេះគឺមិនប្រាកដថាវាអាស្រ័យលើការបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុនទេ" ។ សេចក្តីថ្លែងការណ៍នេះនឹងត្រូវលុបចោលជាសាធារណៈ ចំពោះការផ្តល់ព័ត៌មានមិនពិតថាការ ទទួលយកក្រុមហ៊ុនឯកជនTesla គឺជាប្រធានបទតែមួយគត់ដែលអនុញ្ញាតឱ្យលោកធ្វើដើម្បីការបោះឆ្នោតរបស់ម្ចាស់ហ៊ុន។ វិនិយោគិនបានឆ្លើយតបទៅនឹងបណ្តាញសង្គមរបស់លោក Musk ចាប់តាំងពីថ្ងៃ ដែលលោកបិទការជួញដូរ ។ នាពេលនោះតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវបានកើនឡើងច្រើនជាង ៦% បើធៀបទៅនឹងបរិមាណការកើនឡើងគួរឱ្យកត់សម្គាល់ដែលបានឈានទៅដល់១០,៩៨%គិតពីថ្ងៃមុន។ សេចក្តីថ្លែងការណ៍ជាសាធារណៈក្លែងបន្លំរបស់លោកMusk បណ្តាលឱ្យមានការកត់សម្គាល់ការយល់ច្រឡំនិងការរំខាននៅលើទីផ្សារសម្រាប់ភាគហ៊ុនរបស់ក្រុមហ៊ុនTesla និងបង្កគ្រោះថ្នាក់ដល់វិនិយោគិន។ ដោយការចូលរួមក្នុងការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់នៅក្នុងពាក្យបណ្តឹងនេះលោក Musk បានរំលោភ

ហើយដែលអនុវត្តតាមបញ្ញត្តិផ្នែកទី១០(b) នៃ Securities Exchange Act 1933។ គណៈកម្មការមូលបត្របានដាក់ទោសលោក Musk ដោយយោងទៅតាមច្បាប់ Exchange Act ជំពូកទី២១(b) ដើម្បីធ្វើការវិនិច្ឆ័យទៅលើសំណង់រដ្ឋប្បវេណី និងការអនុវត្តទោសព្រហ្មទណ្ឌ តាមការវិនិច្ឆ័យរបស់តុលាការ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ ពីការធ្វើការស្រាវជ្រាវទៅលើប្រធានបទតាមរយៈការដកស្រង់ព័ត៌មានពាក់ព័ន្ធពីប្រព័ន្ធអ៊ីនធើណេតបណ្ណាល័យ និងឯកសារយោងពីសាស្ត្រាចារ្យកន្លងមក យើងអាចស្វែងយល់ពីសារតាដំណើរការនៃការជួញដូរមូបត្រនៅក្នុងប្រទេសកម្ពុជា ដែលជាស្ថានប័ន្តត្រូវបង្កើតឡើង ដើម្បីជួយបំពេញបន្ថែម ដល់វិស័យធានាគារដែលមានស្រាប់ក្នុងការគៀគរមូលធនព្រមទាំងពង្រីកមធ្យោបានគ្រប់គ្រងហានិភ័យនៃវិស័យហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយផ្តល់នូវជម្រើសថ្មីមួយទៀត ក្នុងហិរញ្ញប្បទានផ្ទាល់ដល់គម្រោងវិនិយោគនានាដែលជាកម្លាំងចលករនៃកំណើតសេដ្ឋកិច្ច។

ដំណើការនៃការជួញដូរមូលបត្រនៅក្នុងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិច ពិតជាមានសារៈសំខាន់ណាស់ ពីព្រោះបើសិនជាវិនិយោគពុំមានការយល់ដឹង អំពីការប្រព្រឹត្តទៅនៃការទិញលក់មូលបត្រនោះទេវិនិយោគនឹងមិនមានទឹកចិត្តក្នុងការវិនិយោគឡើយ ពីព្រោះពួកគេមិនមានការទុកចិត្តក្នុងការបណ្តាក់ទុកក្នុងវិស័យនេះទេ។ យើងឃើញថាទីផ្សារមូលបត្រមានបញ្ហាចោទជាច្រើនទាក់ទងនឹងការប្រព្រឹត្តិបទល្មើសក្នុងទីផ្សារមូលបត្រដែលបទល្មើសមានការជួញដូរផ្ទៃក្នុងការជួញដូរក្លែងក្លាយ និងឧបាយកលក្នុងទីផ្សារ និងសេចក្តីថ្លែង ឬការផ្សព្វផ្សាយព័តត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស ដែលជាបទល្មើសកើតឡើងញឹកញាប់នៅក្នុងវិស័យមូលបត្រតែបទល្មើសទាំងនោះនៅកម្ពុជាមិនទាន់បទល្មើសនៅឡើងទេ គឺមានតែក្នុងសហរដ្ឋអាមេរិក។

ដើម្បីចូលរួមផ្តល់ជាដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ គណៈកម្មការមូលបត្រកម្ពុជា និងសហរដ្ឋអាមេរិក បានដាក់ឱ្យអនុវត្តនូវច្បាប់ និងបទបញ្ញត្តិផ្សេងៗដែលទាក់ទងនិងវិស័យនេះ ក្នុងគោលបំណងធានាដល់ការប្រព្រឹត្តទៅដ៏ត្រឹមត្រូវរបស់ទីផ្សារមូលបត្រ។ ស្របពេលជាមួយគ្នានេះដែរនៅក្នុងប្រទេសកម្ពុជាយើងឃើញមានការដាក់បង្ហាញនូវព័ត៌មានទាក់ទងនិងមូលបត្រ អ្នកចូលរួមក្នុងទីផ្សារ និងទិន្នន័យទីផ្សារតាមរយៈគេហទំព័រ **គ.ម.ក** ដែលជាហេតុងាយស្រួលដល់មហាជនក្នុងការទទួលយកព័ត៌មានបន្ថែម។ ក្រៅពីនេះមានការរៀបចំឡើងនូវសិក្ខាសាលាអប់រំ និងវគ្គបំប៉នខ្លីៗ ដើម្បីបណ្តុះបណ្តាល់វិជ្ជាជីវៈទាក់ទងនិងមូលបត្រក្នុងគោលបំណងបញ្ជ្រាបព័ត៌មានឱ្យកាន់តែទូលំទូលាយ។

សរុបសេចក្តីមក ទីផ្សារមូលបត្រកម្ពុជាអាចចាត់ទុកបានជាកាតាលីករដ៏សំខាន់ក្នុងការជំរុញការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុឱ្យបានទូលំទូលាយជាងមុន និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

# អនុសាសន៍

ដោយសារ តែប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ការយល់ដឹងរបស់ប្រជាជន នៅមានកម្រិតនៅឡើយ នៅពិសេសចំណេះដឹងខាងផ្នែក នៃការជួញដូរមូលបត្រនៅមានកម្រិតទាបនៅឡើយ ទើបកម្ពុជាសម្រេចបង្កើតគណៈកម្មការមូលបត្រកម្ពុជានេះឡើង ដើម្បីសម្រាប់រៀបចំប្រព័ន្ធហិរញ្ញវត្ថុទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ទើបកម្ពុជាបង្កើតនូវគម្រោងទីផ្សារមូលបត្រនេះឡើង។ ទន្ទឹងនឹងនេះ ទីផ្សារមូលបត្រកម្ពុជា ត្រូវទទួលបានគ្រប់គ្រងដោយស្ថាប័នមួយដែលមានឈ្មោះថា គណៈកម្មការមូលបត្រកម្ពុជាក្រោមការគ្រប់គ្រងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ដូច្នេះយើងខ្ញុំ សូមចូលរួមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

- គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលដៅគ្រប់គ្រងលើវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាការចូលរួមចំណែក ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនិងសង្គមជាតិ តាមរយៈការកៀរគរមូលធន ពីសាធារណៈជនឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់ការវិនិយោគនៅកម្ពុជា។
- គណៈកម្មការមូលបត្រកម្ពុជាត្រូវបង្កើនចំនួននៃសិក្ខាសាលាជាសាធារណៈឬការតាំងពិព័រណ៍ផ្សេងៗស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រ ជូនដល់សិស្ស និស្សិត ឬសាធារណៈជន អោយបានជ្រាបពីបញ្ហាមូលបត្រ ដោយមានការចូលរួមពីអ្នកជំនាញពាក់ព័ន្ធ ក៏ដូចជាស្ថាប័នពាក់ព័ន្ធ និងការជួញដូរមូលបត្រលើទីផ្សារមូលបត្រកម្ពុជា។
- ក្រុមហ៊ុនមូលបត្រកម្ពុជា គួរតែស្វែងយល់បន្ថែម ពីយុទ្ធសាស្ត្រនានា មុននឹងសម្រេចចិត្តឱ្យមានការអនុវត្ត ក្នុងវិស័យនៃការជួញដូរមូលបត្រឬការបោះផ្សាយមូលបត្រ។
- ក្រុមហ៊ុនមូលបត្រកម្ពុជា គួរតែស្វែងយល់បន្ថែម ពីវិស័យជួញដូរមូលបត្រពីប្រទេសជិតខាងដើម្បីអោយវិស័យហិរញ្ញនេះកាន់តែមានការរីកចម្រើននិងមានសន្ទុស្សន៍កើនឡើង ដែលអាចចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចផងដែរ។
- ក្រុមហ៊ុនមូលបត្រកម្ពុជា គួរតែជំរុញបន្ថែមដល់គ្រឹះស្ថានសាធារណៈនិងឯកជនឱ្យធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឱ្យបានច្រើន ដើម្បីអោយវិនិយោគិនទាំងក្នុង និងក្រៅស្រុក អាចកៀរគរប្រមូលដើមទុន មកធ្វើអាជីវកម្មរបស់គេ ហើយការបង្កើនបោះផ្សាយមូលបត្រជាការផ្តល់ជម្រើស ដល់វិនិយោគិនណាដែលមានបំណងក្នុងការវិនិយោគលើវិស័យមូលបត្រនេះ។

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត

- ព្រះរាជក្រម នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រ
- អនុក្រឹត្យ លេខ **៥៤.អនក្រ.បក** ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- ប្រកាស លេខ០០៦/១១**គ.ម.កប្រ.ក**, ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ
- ប្រកាសលេខ០០៣/១៨ **គ.ម.ក/ប្រក** ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម
- គោលការណ៍ណែនាំ លេខ០០១ **គ.ម.ក/គ.ណ.ន** ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីយន្តការនៃការបោះផ្សាយក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- ព្រឹត្តបត្រមូលបត្ររបស់គណៈកម្មការមូលបត្រកម្ពុជាចេញផ្សាយលេខ២ ខែមករា ឆ្នាំ២០១៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ស្តីអំពីអត្ថប្រយោជន៍សម្រាប់វិនិយោគិនភាគហ៊ុន
- ព្រឹត្តបត្រមូលបត្ររបស់គណៈកម្មការមូលបត្រកម្ពុជាប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៨
- Securities Exchange Act 1934 Enacted March 23, 2018

  G:\COMP\SEC\SECURITIESEXCHANGE

## សៀវភៅ

- សៀវភៅហិរញ្ញប្បទានរបស់ក្រុមហ៊ុនពាណិជ្ជកម្មតាមរយៈទីផ្សារមូលបត្រ បោះផ្សាយលើកទី១ ឆ្នាំ២០០៩ ដោយសាស្ត្រាចារ្យ **ញាន វណ្ណៈ**
- សៀវភៅមូលបត្រកម្មសិទ្ធិ និងតម្លៃបោះផ្សាយលើកទី១ ឆ្នាំ២០១២ ដោយសាស្ត្រាចារ្យ **បៀន សាំង**
- សៀវភៅនីតិព្រហ្មទណ្ឌធុរកិច្ចបោះពុម្ពផ្សាយឆ្នាំ២០១២ ដោយសាស្ត្រាចារ្យ **ញាន វណ្ណៈ**
- មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្របោះផ្សាយលើកទី១ ឆ្នាំ២០១១ដោយសាស្ត្រាចារ្យ **បៀន សាំង**

## គេហទំព័រ

- www.secc.gov.kh

- info@secc.gov.com
- www.facebook.com/secc.gov.kh
- http://csx.com.kh
- https://www.sec.gov/
- https://criminal.findlaw.com/criminal-charges/false-statements.html
- https://www.investor.gov
- https://www.classlawgroup.com
- https://www.bdo.de/en-gb/services/our-focus/capital-markets/market-manipulation-and-insider-trading

# ឧបសម្ព័ន្ធ

# ច្បាប់

# ស្តីពី

# ការបោះផ្សាយ និងការ

# ជួញដូរមូលបត្រ

# មហាជន

# ២០០៧

# ព្រះរាជក្រម

នស/រកម/១០០៧/០២៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភានីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការបោះផ្សាយ

# និង

# ការជួញដូរមូលបត្រមហាជន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

ច្បាប់នេះមានគោលដៅគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រដែលធ្វើការជួញដូរ ឬ ផ្តល់សេវាកម្មហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រ ។ ច្បាប់នេះរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណជន ឬ អ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់ការវិនិយោគ ។

**មាត្រា ២.- គោលបំណង**

ច្បាប់នេះមានគោលបំណង :

១-បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ ។

២-លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។

៣-ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ។

៤-ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥-ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

**មាត្រា ៣.- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការមូលបត្រមហាជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២

## គណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ៥.- អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ដែលមានប្រធាន ១(មួយ)រូប និងសមាជិកចំនួន ៨(ប្រាំបី)រូប ដែលតែងតាំងដោយអនុក្រឹត្យ ។ សមាជិករបស់ គ.ម.ក. មានអាណត្តិ ៥(ប្រាំ)ឆ្នាំ ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬ ផ្លាស់ប្តូរភារកិច្ច ។ សមាជិក គ.ម.ក. អាចត្រូវបានតែងតាំងសារជាថ្មីទៀតបាន តាមសំណើរបស់ប្រធាន គ.ម.ក. នៅពេលផុតអាណត្តិ ។

**មាត្រា ៦.- សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា**

ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សមាសភាពរបស់ គ.ម.ក. មាន :

១- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ (មួយ)រូប

២- តំណាងធនាគារជាតិនៃកម្ពុជា ០១ (មួយ)រូប

៣- តំណាងក្រសួងពាណិជ្ជកម្ម ០១ (មួយ)រូប

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

41.

៤- តំណាងក្រសួងយុត្តិធម៌ ០១ (មួយ)រូប

៥- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១ (មួយ)រូប

៦- អគ្គនាយក គ.ម.គ. ០១ (មួយ)រូប

៧- អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២ (ពីរ)រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល ។ សមាជិកនៃ គ.ម.គ. ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណៈ-សម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬ ច្រើនផ្នែក ដូចជាពាណិជ្ជកម្ម គ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណនេយ្យ និងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង ។

**មាត្រា ៧.- មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ ។

២-ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ ។

៣-កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ។

៤-កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ។

៥-លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ ។

៦-ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ ។

៧-ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៨-បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ ។

**មាត្រា ៨.- មុខងាររបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា**

អគ្គនាយកនៃ គ.ម.ក. មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រងបុគ្គលិក និងមន្ត្រីជំនាញដែលទទួលបន្ទុកសម្របសម្រួលកិច្ចការរដ្ឋបាលរបស់គ.ម.ក. ក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-រាយការណ៍ និងផ្តល់អនុសាសន៍ជូនប្រធាន និងសមាជិកទាំងអស់នៃ គ.ម.ក. នូវរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍ និង ការត្រួតពិនិត្យទីផ្សារមូល-បត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ និងបទ-ប្បញ្ញត្តិផ្សេងៗ ។

៣-ពិនិត្យសំណុំឯកសារ ដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈនិងផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយគ.ម.ក.។

៤-ពិនិត្យឯកសារផ្តល់ព័ត៌មាន ដែលទាក់ទងនឹងសំណើដាក់លក់មូលបត្រមហាជនដែលដាក់មកគ.ម.ក. ដើម្បីធានានូវការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ និងបញ្ញត្តិនានានៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដោយផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារដែលបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ ។

៥-ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានជាប្រចាំ ដែលផ្តល់ជូនទីផ្សារមូលបត្រនូវ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

ព័ត៌មានហិរញ្ញវត្ថុ ព័ត៌មានមិនមែនហិរញ្ញវត្ថុ និងព័ត៌មានផ្សេងទៀតរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ ។

៦-ត្រួតពិនិត្យការអនុវត្តច្បាប់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនិងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយ ចំពោះអំពើល្មើសនឹងច្បាប់នេះ ។

៧-ទាក់ទងនឹងទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ អគ្គនាយកគ.ម.ក. ត្រូវ:

ក-ពិនិត្យ និងពិនិត្យឡើងវិញលើពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់ការអនុញ្ញាត នៅពេលដែលអ្នកស្នើសុំបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល គ.ម.ក. បានកំណត់ ។

ខ-ពិនិត្យ និងពិនិត្យឡើងវិញ និងផ្តល់ការអនុញ្ញាតឱ្យធ្វើការកែប្រែលើវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ ដែលទទួលបានការអនុញ្ញាត ។

គ-ត្រួតពិនិត្យសកម្មភាពរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីធានាការគោរពតាមលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត និងលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែលគ.ម.ក. បានកំណត់ ។

ឃ-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសរបស់បុគ្គលដែលទទួលបានការអនុញ្ញាតទៅនឹងលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត ឬ លក្ខខណ្ឌដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយរួមមានការព្យួរ ឬ ការដកហូតការអនុញ្ញាត ។

ង-មុនផ្តល់ការអនុញ្ញាត ឬ ដកហូតការអនុញ្ញាត អគ្គនាយកត្រូវសុំការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

ពិគ្រោះយោបល់ពីការប្រជុំពេញអង្គរបស់ គ.ម.ក. ។

៨-ទាក់ទងនឹងក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ អគ្គនាយក នៃ គ.ម.ក. ត្រូវ :

ក-ពិនិត្យពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់អាជ្ញាប័ណ្ណ ប្រសិនបើអ្នកស្នើសុំបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល គ.ម.ក. បានកំណត់ ។

ខ-ត្រួតពិនិត្យសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្នុងការគោរពតាមលក្ខ-ខណ្ឌនៃអាជ្ញាប័ណ្ណរួមទាំងលក្ខខណ្ឌហិរញ្ញវត្ថុ ។

គ-ត្រួតពិនិត្យការគោរពតាមលក្ខខណ្ឌនៃអាជីវកម្មដែលកំណត់ក្នុងច្បាប់នេះ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

ឃ-ពិនិត្យដើម្បីផ្តល់ការអនុញ្ញាតចំពោះការស្នើសុំឱ្យក្លាយទៅជាស្វ័យ-និយ័តករចំពោះពាណិជ្ជករមូលបត្រ ឬទីប្រឹក្សាវិនិយោគ ប្រសិនបើអ្នកស្នើសុំនោះបានគោរពតាមលក្ខខណ្ឌដែលបានកំណត់ ។

ង-ត្រួតពិនិត្យការអនុវត្តតាមលក្ខខណ្ឌនៃច្បាប់របស់ស្វ័យនិយ័តករដែលបានការអនុញ្ញាត ។

ច-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសនឹងលក្ខខណ្ឌនៃអាជ្ញា-ប័ណ្ណ ឬ នៃការអនុញ្ញាត ឬ អំពើល្មើសនឹងលក្ខខណ្ឌនៃច្បាប់នេះរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងចាត់វិធានការអនុវត្តសមស្របណាមួយដូចជាព្យួរ ឬ ដកហូតអាជ្ញាប័ណ្ណ ឬ ការអនុញ្ញាត ។

៩-ចាត់រាល់វិធានការសមស្របដែលច្បាប់នេះអនុញ្ញាតដើម្បីអង្កេតស្វែងរក និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ និងអំពើមិនសមស្របដែលពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ ។

**មាត្រា ៩.- សិទ្ធិអំណាចរបស់អគ្គនាយកក្នុងការគ្រប់គ្រង គ.ម.ក**

ក្នុងគោលបំណងអនុវត្តតាមមុខងារ ដែលមានចែងក្នុងច្បាប់នេះ អគ្គនាយកនៃ គ.ម.ក. មានសិទ្ធិអំណាចដូចខាងក្រោម :

១-ផ្តល់សិទ្ធអំណាចទៅបុគ្គលិករបស់គ.ម.ក. ឬ ផ្តល់សិទ្ធអំណាចទៅបុគ្គលផ្សេងទៀត ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន ។

២-ក្នុងករណីអគ្គនាយកនៃ គ.ម.ក. មានមូលហេតុត្រឹមត្រូវ ហើយជឿជាក់ថាបទល្មើសត្រូវបានប្រព្រឹត្តនៅក្រោមច្បាប់នេះ អគ្គនាយកនៃ គ.ម.ក. អាចសម្រេចឱ្យបុគ្គលិករបស់ខ្លួនធ្វើការស៊ើបអង្កេតលើ :

ក-បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ឬ ទទួលបានការអនុញ្ញាត ។

ខ-បុគ្គលដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ ។

គ-ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលមានមូលបត្រដាក់លក់ ឬ ដាក់តម្លៃនៅក្នុងទីផ្សារមូលបត្រ ។

ឃ-បុគ្គលផ្សេងទៀតតាមការជាក់ស្តែង ។

៣-ប្រមូលភស្តុតាងពីបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត ។

៤-រាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការស៊ើបអង្កេតជូនប្រធាន និងសមាជិកទាំងអស់នៃ គ.ម.ក. ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ដើម្បីចាត់វិធានការអនុវត្តបន្ត ។

៥-បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ពីបទល្មើស ។

៦-ធ្វើការអង្កេតលើរាល់សកម្មភាពទីផ្សារមូលបត្រប្រតិស្រុត ។

៧-ផ្សព្វផ្សាយឈ្មោះ និងសកម្មភាពរបស់បុគ្គលដែលមានពិរុទ្ធភាពពីបទល្មើសដែលមានចែងក្នុងច្បាប់នេះ ឬ ដែលទទួលទណ្ឌកម្មខាងវិន័យពី គ.ម.ក. ។

៨-ដកហូត ឬ ព្យួរអាជ្ញាប័ណ្ណ ការអនុញ្ញាត ឬការចុះបញ្ជីដែលបានផ្តល់ឱ្យ ។

៩-សិទ្ធិមួយចំនួនទៀតស្របតាមមាត្រា ៤៥ នៃច្បាប់នេះ ។

**មាត្រា ១០.- សិទ្ធិពិសេសរបស់ គ.ម.ក.**

មន្ត្រីរបស់គ.ម.ក. ទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានមុខងារដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីមុខងាររបស់នគរបាលយុត្តិធម៌ ។

AUME DU CAMBODGE
ISTRE DU PALAIS ROYAL

**មាត្រា ១១.- ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក.**

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ ។ គ.ម.ក. ត្រូវមានថវិកាសម្រាប់ចំណាយផ្ទាល់ខ្លួនដាច់ដោយឡែក ។

## ជំពូកទី ៣

## សំណើលក់មូលបត្រ និង ការបោះផ្សាយមូលបត្រ

**មាត្រា ១២.- ការបោះផ្សាយ និងលក់មូលបត្រ**

គ្មានបុគ្គលណាមួយបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពី គ.ម.ក. ដោយអនុលោមតាមច្បាប់និងលក្ខខណ្ឌផ្សេងៗ ដែលកំណត់ដោយ គ.ម.ក. ។ បុគ្គលនោះត្រូវបង់ថ្លៃសេវានៃការដាក់ពាក្យស្នើសុំដែលកំណត់ឡើងស្របតាមច្បាប់នេះ ។

**មាត្រា ១៣.- ការពិនិត្យលើពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ**

អគ្គនាយកនៃ គ.ម.ក. ត្រូវពិនិត្យរាល់ពាក្យស្នើសុំ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ និងជូនដំណឹងដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំនោះ អំពីភាពសមស្រប ឬ មិនសមស្រប នៃសំណើនោះជាមួយនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលយ៉ាងយូរ ៣(បី) ខែ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ ។

**មាត្រា ១៤.- លក្ខខណ្ឌនៃពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ**

ដើម្បីសម្រេចថា ពាក្យស្នើសុំមួយមានភាពសមស្រប ឬមិនសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា អគ្គនាយកនៃ គ.ម.ក. ត្រូវតែពិចារណាលើ :

១-គុណភាពនៃអភិបាលកិច្ច និងប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ។

២-តម្រូវការរបស់ទីផ្សារមូលបត្ររួមទាំងតម្រូវការដើម្បីអភិវឌ្ឍទីផ្សារមូលបត្រ ។

៣-កត្តាជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈរួមទាំង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

អត្ថិភាពនៃកិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញដែលនឹងធានាថា រាល់មូល-បត្រទាំងអស់ដែលប្រកាសលក់ក្នុងក្របខ័ណ្ឌនៃសំណើលក់ជាសាធារណៈនោះ អាចបោះផ្សាយបាន ឬ អាចលក់អស់ ។

៤-លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីដើម្បីលក់នៅទីផ្សារមូលបត្រ ។

៥-លក្ខខណ្ឌផ្សេងៗ តម្រូវក្នុងការផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានឱ្យស្របតាមជំពូកនេះ ។

៦-បញ្ហាផ្សេងៗទៀត ដែលអគ្គនាយកនៃ គ.ម.ក. ពិនិត្យឃើញថាមានលក្ខណៈសមស្របក្នុងការការពារផលប្រយោជន៍សាធារណៈ ។

**មាត្រា ១៥.- ការយល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ**

ប្រសិនបើ គ.ម.ក. យល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ ដែលដាក់ជូនតាមមាត្រា ១២ នៃច្បាប់នេះ បុគ្គលដែលធ្វើសំណើនោះអាចចាប់ផ្តើមធ្វើសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់នេះ ។

**មាត្រា ១៦.- ការដាក់លក់មូលបត្រជាសាធារណៈ**

គ្មានបុគ្គលណាមួយធ្វើសំណើលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ លើកលែងតែសំណើលក់នោះ ធ្វើឡើងដោយគោរពតាមលក្ខខណ្ឌខាងក្រោម :

១-មូលបត្រដែលធ្វើសំណើលក់នោះ ត្រូវបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដោយនីតិបុគ្គលប្រតិស្រុត ដែលត្រូវបានកំណត់ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

២-រាល់លក្ខខណ្ឌនៃការស្នើសុំលក់ និងឯកសារផ្តល់ព័ត៌មានដែលត្រូវបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌដទៃទៀតដែលត្រូវបានកំណត់ស្របតាមច្បាប់នេះ ត្រូវតែទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក. លើកលែងតែការដាក់លក់នោះ គឺជាការដាក់លក់មូលបត្រអញ្ញត្រកម្មដូចមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់

ROYAUME DU CAMBODGE * LE MINISTRE du PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

នេះ ។ ចំពោះឯកសារផ្តល់ព័ត៌មានត្រូវតែចុះបញ្ជីនៅគ.ម.ក. ។

**មាត្រា ១៧.- បែបបទនៃការដាក់លក់មូលបត្រ និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន**

បុគ្គលណាដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈ ត្រូវដាក់ពាក្យសុំការអនុញ្ញាតធ្វើសំណើលក់នោះ និងសុំការអនុញ្ញាតចុះបញ្ជីឯកសារផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងសំណើលក់ទៅគ.ម.ក. ។ បុគ្គលស្នើសុំត្រូវ :

១-ដាក់ពាក្យសុំមួយច្បាប់តាមទម្រង់កំណត់ដែលរួមមានលក្ខខណ្ឌនៃសំណើលក់ជាសាធារណៈនៃមូលបត្រ និងឯកសារផ្តល់ព័ត៌មានមួយច្បាប់ ដែលបំពេញតាមលក្ខខណ្ឌរបស់ច្បាប់នេះព្រមទាំងលក្ខខណ្ឌទាំងឡាយណា ដែលត្រូវបានកំណត់ដោយអនុលោមតាមច្បាប់នេះ ។

២-បង់ថ្លៃសេវាតាមការកំណត់សម្រាប់ការដាក់ពាក្យស្នើសុំ ។

**មាត្រា ១៨.- ការចុះបញ្ជី និងការយល់ព្រមលើឯកសារផ្តល់ព័ត៌មាន**

អគ្គនាយកនៃ គ.ម.ក. អាចផ្តល់ការអនុញ្ញាត ចំពោះឯកសារផ្តល់ព័ត៌មាន និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានដែលបានដាក់ជូនគ.ម.ក. ប្រសិនបើអគ្គនាយកនៃ គ.ម.ក. ពិនិត្យឃើញថាឯកសារនោះបំពេញតាមលក្ខខណ្ឌរបស់ច្បាប់ និងលក្ខខណ្ឌផ្សេងៗដែលត្រូវបានកំណត់អនុលោមតាមច្បាប់នេះ ។

**មាត្រា ១៩.- ការបដិសេធលើឯកសារផ្តល់ព័ត៌មាន**

ការសម្រេចបដិសេធចំពោះការផ្តល់ការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានត្រូវធ្វើឡើងដូចខាងក្រោម :

១-ប្រសិនបើអគ្គនាយកនៃ គ.ម.ក. ពិនិត្យឃើញថា ឯកសារផ្តល់ព័ត៌មានដែលបានដាក់សុំការអនុញ្ញាតនោះ ពុំបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងៗដទៃទៀតដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ គ.ម.ក. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យស្នើសុំដោយផ្តល់នូវ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ក-មូលហេតុ ។

ខ-ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំ ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដើម្បីធ្វើការពន្យល់បន្ថែមលើគុណសម្បត្តិនៃសំណើដាក់លក់មូលបត្រជាសាធារណៈនោះ ។

គ-ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំ ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រដើម្បីធ្វើការកែប្រែឯកសារផ្តល់ព័ត៌មាន ។

២-ប្រសិនបើអគ្គនាយកនៃ គ.ម.ក. នៅតែពិនិត្យឃើញថាឯកសារផ្តល់ព័ត៌មានដែលតម្រូវឱ្យកែប្រែនោះ នៅតែមិនបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងលក្ខខណ្ឌផ្សេងៗដទៃទៀតដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ គ.ម.ក. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យស្នើសុំយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបានថាឯកសារផ្តល់ព័ត៌មានត្រូវបានបដិសេធមិនឱ្យចុះបញ្ជី ។

**មាត្រា ២០.- ឯកសារផ្តល់ព័ត៌មានបន្ថែម**

ក្នុងរយៈពេលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវដាក់ឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសជូនទៅ គ.ម.ក. ដើម្បីសុំការអនុញ្ញាត និងចុះបញ្ជី ប្រសិនបើឯកសារផ្តល់ព័ត៌មានមាន :

១-ការកែប្រែ ឬ ផ្លាស់ប្តូរព័ត៌មាន ដែលប៉ះពាល់ដល់ខ្លឹមសារឯកសារផ្តល់ព័ត៌មានដែលបានផ្តល់ ។

២-បញ្ហាសំខាន់ថ្មីបានកើតឡើងដោយសារតែច្បាប់ ឬ លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយអនុលោមតាមច្បាប់នេះ បានតម្រូវឱ្យបង្ហាញបញ្ហាសំខាន់ថ្មីនោះ ទោះបីជាឯកសារផ្តល់ព័ត៌មានត្រូវបានរៀបចំហើយក៏ដោយ ។

៣-ឯកសារផ្តល់ព័ត៌មាន ដែលបានផ្តល់មានបង្កប់នូវព័ត៌មានសំខាន់ណាមួយដែលមានលក្ខណៈមិនច្បាស់លាស់ ឬ វែងបន្ទំ ឬ ដែលនាំឱ្យយល់ខុស ឬ មានការខកខានមិនបានបញ្ចូលនូវព័ត៌មានសំខាន់ដែលត្រូវដាក់ក្នុងឯកសារផ្តល់ព័ត៌មាន ។

បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ មិនត្រូវផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសជាសាធារណៈ លើកលែងតែឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសនោះ ទទួលបានការអនុញ្ញាត និងចុះបញ្ជីពី គ.ម.ក. ។

**មាត្រា ២១.- ការព្យួរ ឬ ការលុបចោលឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួច**

អគ្គនាយកនៃ គ.ម.ក. មានសិទ្ធិព្យួរការចុះបញ្ជីនៃឯកសារផ្តល់ព័ត៌មាន ដើម្បីការពារផលប្រយោជន៍សាធារណៈ ក្នុងករណីអគ្គនាយកនៃ គ.ម.ក. ពិនិត្យឃើញថា ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចហើយ ដោយរួមទាំងឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសនោះ :

១-មានព័ត៌មានដែលមានលក្ខណៈក្លែងបន្លំ ឬ ដែលនាំឱ្យយល់ខុស ឬ ខកខានពុំបានផ្តល់ព័ត៌មានសំខាន់ណាមួយ ។

២-ពុំបានអនុវត្តតាមច្បាប់ ឬ លក្ខខណ្ឌផ្សេងទៀត ដែលបានកំណត់អនុលោមតាមច្បាប់នេះ ។

ការព្យួរការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ត្រូវធ្វើឡើងក្នុងរយៈពេលជាក់លាក់ណាមួយ មិនឱ្យលើសពី ០១ (មួយ) ខែ ហើយបន្ទាប់ពីផុតរយៈពេលនៃការព្យួរនេះ បើអគ្គនាយកនៃ គ.ម.ក. ពិនិត្យឃើញថា បញ្ហាដែលបណ្តាលឱ្យមានការព្យួរមិនត្រូវបានដោះស្រាយឱ្យបានសមស្រប អគ្គនាយកនៃ គ.ម.ក. មានសិទ្ធិលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននោះ ។

**មាត្រា ២២.- លក្ខខណ្ឌបន្ថែមទាក់ទងនឹងសំណើលក់ និងការបោះផ្សាយមូលបត្រ**

លក្ខខណ្ឌបន្ថែមទៀតដែលទាក់ទងនឹងការគ្រប់គ្រង និងត្រួតពិនិត្យសំណើលក់ជាសាធារណៈ និងការបោះផ្សាយមូលបត្រ ត្រូវកំណត់ដោយ គ.ម.ក. ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

## ជំពូកទី ៤
## ដំណើរការរបស់ទីផ្សារមូលបត្រ

**មាត្រា ២៣.- ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ**

គ្មានបុគ្គលណាមួយ អាចធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រឡើយ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. ដោយអនុលោមតាមច្បាប់នេះ ឬ ច្បាប់ផ្សេងៗទៀតជាធរមាន ។ មាត្រានេះមិនត្រូវបានអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាទេ ដែលអាចធ្វើប្រតិបត្តិការប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ។

**មាត្រា ២៤.- ការដាក់ពាក្យស្នើសុំធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ**

ការដាក់ពាក្យស្នើសុំ ដើម្បីធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ត្រូវធ្វើឡើងដូចខាងក្រោម :

១-បុគ្គល ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីគ.ម.ក. ដើម្បីធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ តាមទម្រង់ដែលបានកំណត់ និងបង់ថ្លៃសេវាតាមការកំណត់របស់គ.ម.ក. ។

២-ក្រោយពីទទួលបានពាក្យស្នើសុំតាមកថាខណ្ឌ (១) អគ្គនាយកនៃ គ.ម.ក. ត្រូវបញ្ជូនពាក្យស្នើសុំមួយច្បាប់ជូនប្រធាន គ.ម.ក. និងសមាជិកនៃ គ.ម.ក. ទាំងអស់ ដើម្បីផ្តល់អនុសាសន៍លើពាក្យស្នើសុំនោះឱ្យបានយ៉ាងឆាប់តាមការជាក់ស្តែង ។

៣-អគ្គនាយកនៃ គ.ម.ក. អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ ។ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំមិនបានផ្តល់ព័ត៌មានបន្ថែម អគ្គនាយកនៃ គ.ម.ក. អាចបដិសេធមិនពិនិត្យពាក្យស្នើសុំនោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២៥.– ការអនុញ្ញាតលើពាក្យស្នើសុំ**

ការសម្រេចផ្តល់ការអនុញ្ញាតលើការស្នើសុំធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រមានដូចតទៅ :

១-ក្រោយពីទទួលបានការសម្រេចពីការប្រជុំពេញអង្គរបស់គ.ម.ក.មក អគ្គនាយកនៃ គ.ម.ក. ត្រូវផ្តល់ការអនុញ្ញាតដល់បុគ្គល ដើម្បីដាក់ឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ប្រសិនបើអគ្គនាយកនៃ គ.ម.ក. ពិនិត្យឃើញថា ពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ ។

២-អគ្គនាយកនៃ គ.ម.ក. មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការពន្យល់ ។

៣-ប្រសិនបើអគ្គនាយកនៃ គ.ម.ក. ផ្តល់ការអនុញ្ញាតតាមកថាខណ្ឌ (១) :

-ការអនុញ្ញាតត្រូវធ្វើឡើង ដោយគោរពតាមលក្ខខណ្ឌកំណត់ អនុលោមតាមច្បាប់នេះ

-ក្នុងរយៈពេលដែលការអនុញ្ញាតនៅមានសុពលភាព អគ្គនាយកនៃ គ.ម.ក. អាចកំណត់នូវលក្ខខណ្ឌបន្ថែម ឬ កែប្រែ ឬ ដកហូតលក្ខខណ្ឌបន្ថែមណាមួយមកវិញបាន ក្រោយពីបានទទួលការសម្រេចរបស់គ.ម.ក ។

**មាត្រា ២៦.– លក្ខខណ្ឌតម្រូវឱ្យមានប្រព័ន្ធផាត់ទាត់ និងទូទាត់**

មុនពេលដែលអគ្គនាយកនៃ គ.ម.ក. ផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដើម្បីដាក់ឱ្យដំណើរការប្រតិបត្តិការទីផ្សារមូលបត្រ អ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់ជូន គ.ម.ក. អំពីលទ្ធភាពរបស់ខ្លួនក្នុងការរៀបចំឱ្យមានការប្រើប្រាស់ប្រព័ន្ធផាត់ទាត់និងទូទាត់មួយសមស្របសម្រាប់អ្នកចូលរួមការជួញដូរនៅក្នុងទីផ្សារមូលបត្រនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២៧.– ការព្យួរ និងការដកហូត ការអនុញ្ញាត**

សិទ្ធិអំណាចរបស់អគ្គនាយកនៃ គ.ម.ក. ក្នុងការគ្រប់គ្រងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ មានដូចតទៅ ៖

១-ក្រោយពេលផ្តល់ការអនុញ្ញាតស្របតាមជំពូកនេះ ប្រសិនបើអគ្គនាយកនៃ គ.ម.ក. ពិនិត្យឃើញថា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់និង ប្រតិបត្តិកររក្សាទុកមូលបត្របានបំពានលើលក្ខខណ្ឌនៃការអនុញ្ញាត ឬ លក្ខខណ្ឌរបស់ច្បាប់ និងលក្ខខណ្ឌផ្សេងទៀតដែលបានកំណត់តាមច្បាប់នេះ អគ្គនាយកនៃ គ.ម.ក. មានសិទ្ធិចាត់វិធានការដូចខាងក្រោម ៖

ក-ដឹកនាំកែតម្រង់បុគ្គលដែលទទួលបានការអនុញ្ញាតឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវ ។

ខ-ដាក់លក្ខខណ្ឌ ឬ កំហិតបន្ថែមលើការអនុញ្ញាត ។

គ-ព្យួរការអនុញ្ញាត រហូតដល់អ្នកដែលទទួលបានការអនុញ្ញាតនោះអនុវត្តតាមលក្ខខណ្ឌតម្រូវឱ្យបានពេញលេញ ។

ឃ-ដកហូតការអនុញ្ញាតនោះមកវិញ ។

២-អគ្គនាយកនៃ គ.ម.ក. មិនត្រូវចាត់វិធានការស្របតាមកថាខណ្ឌ(១) ដោយមិនបានសុំយោបល់ គ.ម.ក. ដោយបើកធ្វើការប្រជុំពេញអង្គជាមុន និង ដោយមិនបានផ្តល់ដល់អ្នកទទួលបានការអនុញ្ញាតនូវមូលហេតុជាលាយលក្ខណ៍អក្សរ និងមិនផ្តល់ឱកាសឱ្យអ្នកទទួលបានការអនុញ្ញាតធ្វើការពន្យល់ ។

**មាត្រា ២៨.– វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រដែលមានការអនុញ្ញាត**

គ្មានបុគ្គលណា អាចដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬ សេវារក្សាទុកមូលបត្រ លើកលែងតែទទួលបានការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

អនុញ្ញាតពី គ.ម.ក. ។ វិធានប្រតិបត្តិការ និងនីតិវិធីនោះ ត្រូវចែងអំពីបញ្ញត្តិនានា ដែលទាក់ទងនឹងការគ្រប់គ្រងឱ្យបានច្បាស់លាស់ហើយឱ្យស្របតាមច្បាប់នេះ ។

**មាត្រា ២៩.- លក្ខខណ្ឌបន្ថែមដែលមានទាក់ទងនឹងការប្រព្រឹត្តទៅរបស់ផ្សារបន្ទាប់**

ការលក់ ឬ ការទិញមូលបត្រដែលបោះផ្សាយលក់ អនុលោមតាមច្បាប់នេះ ត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌបន្ថែមដែលកំណត់ដោយ គ.ម.ក. ។

**មាត្រា ៣០.- ការគោរពលក្ខខណ្ឌ និងលក្ខខណ្ឌបន្ថែមនៃការអនុញ្ញាត**

បុគ្គលដែលបានទទួលការណែនាំពីអគ្គនាយកនៃ គ.ម.ក. តាមមាត្រា ២៧(១) នៃច្បាប់នេះ ឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនៃការអនុញ្ញាត ត្រូវតែគោរពតាមការណែនាំក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក. ។

## ជំពូកទី ៥

## អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ

**មាត្រា ៣១.- ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ**

គ្មានបុគ្គលណាមួយអាចធ្វើអាជីវកម្មមូលបត្រ ឬ តាំងខ្លួនជាអ្នកធ្វើអាជីវកម្មមូលបត្រក្នុងទម្រង់ជាក្រុមហ៊ុនមូលបត្របានទេ លើកលែងតែបុគ្គលនោះទទួលអាជ្ញាប័ណ្ណពីអគ្គនាយកនៃ គ.ម.ក. ឬពាណិជ្ជករមូលបត្រអញ្ញត្រកម្ម ឬ ពាណិជ្ជករពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រអញ្ញត្រកម្មដែលកំណត់ដោយអនុក្រឹត្យ ។

គ្មានជនណាមួយអាចធ្វើជាភ្នាក់ងារ ឬ តាំងខ្លួនជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រប្រតិស្រុតដើម្បីធ្វើអាជីវកម្មមូលបត្របានទេ លុះត្រាតែជននោះត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយអគ្គនាយកនៃ គ.ម.ក. ឱ្យធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រអនុលោមតាមច្បាប់នេះ ។

**មាត្រា ៣២.- ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ**

ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវធ្វើដូចតទៅ :

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

១-បុគ្គលម្នាក់អាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬ ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រទៅអគ្គនាយកនៃ គ.ម.ក. តាមទម្រង់បែបបទដែលបានកំណត់ និងដោយបង់ថ្លៃសេវាតាមការកំណត់របស់ គ.ម.ក. ។

២-អគ្គនាយកនៃ គ.ម.ក. អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធមិនពិនិត្យពាក្យស្នើសុំនោះ រហូតដល់អ្នកដាក់ពាក្យស្នើសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់ ។

**មាត្រា ៣៣.- ការពិនិត្យ និងសម្រេចលើពាក្យស្នើសុំអាជ្ញាប័ណ្ណ**

ការសម្រេចផ្តល់អាជ្ញាប័ណ្ណ និងលក្ខខណ្ឌអាជ្ញាប័ណ្ណ ត្រូវអនុវត្តដូចខាងក្រោម :

១-អគ្គនាយកនៃ គ.ម.ក. អាចផ្តល់អាជ្ញាប័ណ្ណដល់អ្នកដាក់ពាក្យស្នើសុំ ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬ ធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌ ដែលបានកំណត់ដោយ គ.ម.ក. ។ នៅក្នុងរយៈពេលដែលអាជ្ញា-ប័ណ្ណនៅមានសុពលភាព ប្រសិនបើលក្ខខណ្ឌដែលបានកំណត់ដោយ គ.ម.ក. មានការប្រែប្រួល អ្នកដាក់ពាក្យស្នើសុំដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវបន្តបំពេញតាមលក្ខខណ្ឌប្រែប្រួលនោះ ។

២-អគ្គនាយកនៃ គ.ម.ក. មិនត្រូវបដិសេធក្នុងការផ្តល់អាជ្ញាប័ណ្ណជូនអ្នកដាក់ពាក្យស្នើសុំ ដោយមិនបញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងដោយមិនបានផ្តល់ឱកាសដល់អ្នកដាក់ពាក្យស្នើសុំឱ្យធ្វើការពន្យល់ឡើយ ។

៣-ប្រសិនបើអគ្គនាយកនៃ គ.ម.ក. ផ្តល់អាជ្ញាប័ណ្ណតាមកថាខណ្ឌ (១) :

-អាជ្ញាប័ណ្ណដែលផ្តល់នោះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ និងលក្ខខណ្ឌដែលកំណត់ដោយ គ.ម.ក

-អាជ្ញាប័ណ្ណដែលផ្តល់នោះ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ ឬ ការដាក់កំហិតណាមួយតាមការចាំបាច់ រួមទាំងលក្ខខណ្ឌដែលដាក់កំហិតលើប្រភេទអាជីវកម្មណាមួយដែលស្ថិតក្នុងអាជ្ញាប័ណ្ណ និង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

-ក្នុងរយៈពេលដែលអាជ្ញាប័ណ្ណនៅមានសុពលភាព អគ្គនាយកនៃ គ.ម.ក. អាចកំណត់នូវលក្ខខណ្ឌបន្ថែមលើអាជ្ញាប័ណ្ណ កែប្រែ ឬ ដកលក្ខខណ្ឌណាមួយមកវិញ ក្រោយទទួលបានការសម្រេចរបស់គ.ម.ក. ។

**មាត្រា ៣៤.- ការព្យួរ និងការដកហូតអាជ្ញាប័ណ្ណ**

វិធានការចំពោះអ្នកកាន់អាជ្ញាប័ណ្ណមានដូចតទៅ ៖

១-ក្រោយពេលផ្តល់អាជ្ញាប័ណ្ណក្រោមជំពូកនេះ ប្រសិនបើអគ្គនាយកនៃគ.ម.ក. ពិនិត្យឃើញថា អ្នកកាន់អាជ្ញាប័ណ្ណបានបំពានលើលក្ខខណ្ឌណាមួយនៃអាជ្ញាប័ណ្ណ ឬ លក្ខខណ្ឌណាមួយដែលកំណត់ដោយគ.ម.ក. ឬ បទប្បញ្ញត្តិណាមួយដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ គ.ម.ក. អាចចាត់វិធានការដូចខាងក្រោម ៖

-ដឹកនាំកែតម្រង់អ្នកកាន់អាជ្ញាប័ណ្ណឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនោះ

-ដាក់កំហិតលើអាជ្ញាប័ណ្ណ

-ព្យួរអាជ្ញាប័ណ្ណនោះ រហូតដល់អ្នកកាន់អាជ្ញាប័ណ្ណបានគោរពតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមពេញលេញ

-ដកហូតអាជ្ញាប័ណ្ណមកវិញ ។

២-អគ្គនាយកនៃ គ.ម.ក. មិនត្រូវចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌ (១) ដោយមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ដល់អ្នកកាន់អាជ្ញាប័ណ្ណអំពីមូលហេតុនៃការចាត់វិធានការនេះ និងដោយមិនផ្តល់ឱកាសឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើការពន្យល់ឡើយ ។

**មាត្រា ៣៥.- លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ និងការផ្តល់អាជ្ញាប័ណ្ណដល់ទីប្រឹក្សាវិនិយោគ ពាណិជ្ជករ មូលបត្រ និងអ្នកចូលរួមដទៃទៀត**

លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ និងការផ្តល់អាជ្ញាប័ណ្ណដល់ទីប្រឹក្សាវិនិយោគ ពាណិជ្ជករ មូលបត្រនិងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ ឬ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុក

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មូលបត្រត្រូវកំណត់ដោយគ.ម.ក. ។

**មាត្រា ៣៦.— ការបង្កើត និងការរក្សាបញ្ជីអាជ្ញាប័ណ្ណ**

អគ្គនាយកនៃ គ.ម.ក. ត្រូវបង្កើត និងរក្សាបញ្ជីអាជ្ញាប័ណ្ណទាំងអស់ដែលខ្លួនបានផ្តល់ តាមទម្រង់បែបបទត្រឹមត្រូវ ដោយចុះបញ្ជាក់នូវព័ត៌មានជាក់លាក់មួយចំនួន ។

**មាត្រា ៣៧.— ការគោរពលក្ខខណ្ឌ និងលក្ខខណ្ឌបន្ថែមនៃអាជ្ញាប័ណ្ណ**

បុគ្គលណាដែលបានទទួលការណែនាំពីអគ្គនាយកនៃ គ.ម.ក. តាមមាត្រា ៣៤(១) នៃ ច្បាប់នេះឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនៃអាជ្ញាប័ណ្ណ ត្រូវតែគោរពតាមការណែនាំក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក. ។

## ជំពូកទី ៦

## អភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

**មាត្រា ៣៨.— លក្ខខណ្ឌនៃអភិបាលកិច្ច ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទប្បញ្ញត្តិទាំងឡាយជាធរមាន និងរាល់លក្ខខណ្ឌទាំងឡាយស្តីពីអភិបាលកិច្ច ដែលកំណត់ដោយគ.ម.ក. ដើម្បីការពារផលប្រយោជន៍ដល់ការប្រព្រឹត្តទៅនៃទីផ្សារមូលបត្រនិងដើម្បីការពារផលប្រយោជន៍អ្នកវិនិយោគសាធារណៈ ។

**មាត្រា ៣៩.— លក្ខខណ្ឌគ្រប់គ្រងសាជីវកម្ម**

លក្ខខណ្ឌគ្រប់គ្រងសាជីវកម្មអាចត្រូវកំណត់ដោយគ.ម.ក. ដើម្បីគ្រប់គ្រងលើ :

- បែបបទក្នុងការទទួលបានសិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត ដែលបោះផ្សាយលក់ជាសាធារណៈនូវភាគហ៊ុនមានសិទ្ធិបោះឆ្នោត ។ លក្ខខណ្ឌដែលត្រូវបានកំណត់នោះមានគោលបំណងដើម្បីធានាថាការទទួលបានសិទ្ធិគ្រប់គ្រងលើភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលនោះ ធ្វើឡើងប្រកបដោយយុត្តិធម៌ និងតម្លាភាព ។

-ការផ្តល់ព័ត៌មានអំពីកម្មសិទ្ធិនៃការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់ជាសាធារណៈនូវភាគហ៊ុនមានសិទ្ធិបោះឆ្នោត ។ លក្ខខណ្ឌដែលត្រូវបានកំណត់នោះមានគោលបំណងដើម្បីធានាថា អ្នកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត អាចដឹងពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ភាគហ៊ុនចំនួនច្រើននៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលនោះ ។

## ជំពូកទី ៧

## អាកប្បកិរិយាដែលត្រូវបានហាមឃាត់ទាក់ទិននៅនឹងមូលបត្រ

### មាត្រា ៥០.- ការជួញដូរផ្ទៃក្នុង

អ្នកផ្ទៃក្នុងត្រូវបានកំណត់ដូចខាងក្រោម:

-អគ្គនាយក នាយក គណៈគ្រប់គ្រង និងបុគ្គលិករបស់ក្រុមហ៊ុន ឬ របស់នីតិ-បុគ្គលប្រតិស្រុត និងភាគហ៊ុនិកនៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតដែលកាន់កាប់យ៉ាងតិច ៥ (ប្រាំ) ភាគរយនៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត និងបុគ្គលដទៃទៀត ដែលទំនាក់ទំនងរបស់បុគ្គលនោះជាមួយនឹងក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតផ្តល់ឱ្យខ្លួនមាន ឬ ទទួលបាននូវព័ត៌មានសម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុត

-ប្រធាន សមាជិក អគ្គនាយក នាយក និងបុគ្គលិករបស់គ.ម.ក. ទាំងអស់ និងមន្ត្រីពាក់ព័ន្ធដទៃទៀតរបស់រាជរដ្ឋាភិបាល ឬ បុគ្គលិករបស់នីតិបុគ្គលដែលទទួលបានការអនុញ្ញាតឬទទួលបានអាជ្ញាប័ណ្ណពីអគ្គនាយកនៃ គ.ម.ក. ឱ្យធ្វើជាអន្តរការីនៅក្នុងទីផ្សារ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

មូលបត្រដែលមាន ឬ ទទួលបាននូវព័ត៌មានសម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតដោយសារតែតួនាទីរបស់ខ្លួន ។

ព័ត៌មានផ្ទៃក្នុងសំដៅដល់ព័ត៌មានទាំងឡាយណាទាក់ទិននឹងមូលបត្រដែលត្រូវបោះផ្សាយ និងបានបោះផ្សាយ ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ហើយព័ត៌មានទាំងនោះមិនទាន់ផ្សព្វផ្សាយជាទូទៅ ប៉ុន្តែប្រសិនបើព័ត៌មានទាំងនោះនឹងដល់សាធារណជន អាចមានផលប៉ះពាល់ខ្លាំងដល់តម្លៃ ឬ ទិដ្ឋភាពជួញដូរដទៃទៀតរបស់មូលបត្រទាំងនោះ ។

អ្នកផ្ទៃក្នុងដូចមានចែងក្នុងកថាខណ្ឌទី ១ មិនត្រូវ :

-ធៀតប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដែលចែងក្នុងកថាខណ្ឌទី ២ ខាងលើ ដោយផ្ទាល់ ឬ មិនផ្ទាល់ ដើម្បីជួញដូរមូលបត្ររបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតក្នុងគោលបំណងរកចំណេញ ឬ បញ្ចៀសការខាតបង់ផ្ទាល់ខ្លួន

-ផ្តល់ព័ត៌មានផ្ទៃក្នុងដល់បុគ្គលដទៃណាមួយ ឬ នីតិបុគ្គលប្រតិស្រុតណាមួយក្នុងគោលបំណងធ្វើឱ្យបុគ្គលនោះ ឬ នីតិបុគ្គលប្រតិស្រុតនោះរកចំណេញ ឬ បញ្ចៀសការខាតបង់ ។

**មាត្រា ៥១.- ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ**

ទោះបីជាដោយចេតនា ឬ ដោយធ្វេសប្រហែសក្តី បុគ្គលមិនត្រូវ :

១-ធ្វើសកម្មភាពណាមួយ ឬ គេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឱ្យ ឬ អាចបណ្តាលឱ្យមានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុសចំពោះការជួញដូរមូលបត្រដែលគេកំពុងជួញដូរនៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា ។ ឬ

២-ធ្វើប្រតិបត្តិការ ឬ ធ្វើផែនការជួញដូរ ដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រ ហើយប្រសិនបើប្រតិបត្តិការនោះបណ្តាលឱ្យ :

-តម្លៃនៃការជួញដូរមូលបត្រ នៅលើទីផ្សារមូលបត្រ នៅក្នុងប្រទេសកម្ពុជានៅថេរ កើនឡើង ឬ ស្រុតចុះ និង

-មានចលនាឡើង ចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ក្នុងប្រទេសកម្ពុជា ។

**មាត្រា ៤២.- សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស**

បុគ្គលមិនត្រូវធ្វើសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានប្រសិនបើ :

១-សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះមានលក្ខណៈក្លែងបន្លំ ឬ មានលក្ខណៈនាំឱ្យយល់ខុសធ្ងន់ធ្ងរ ។

២-សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានទាំងនោះអាច :

-បណ្តាលឱ្យសាធារណជននៅក្នុងប្រទេសកម្ពុជា ទិញ ឬ លក់មូលបត្រ ឬ

-បណ្តាលឱ្យមានការកើនឡើង ការថយចុះ ឬ ការនៅថេរចំពោះតម្លៃនៃការផ្តល់ជូនមូលបត្រដែលផ្តល់ជូននៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា ។

៣-នៅពេលដែលបុគ្គលនោះធ្វើសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាន :

-បុគ្គលនោះមិនគិតថា សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះពិត ឬ ក្លែងបន្លំ ឬ

-បុគ្គលនោះដឹង ឬ គួរដឹងថាសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះគឺក្លែងបន្លំ និងមានលក្ខណៈធ្វើឱ្យយល់ខុស ។

## ជំពូកទី ៨

## ការដោះស្រាយវិវាទ និង វិធានការទណ្ឌកម្ម

**មាត្រា ៤៣.- ការផ្សះផ្សាវិវាទ**

គ្រប់វិវាទដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មមូលបត្រ ភាគីជម្លោះអាចនាំយកវិវាទនោះជូនទៅ គ.ម.ក. ដើម្បីធ្វើការផ្សះផ្សាមុននឹងប្តឹងទៅតុលាការ លើកលែងតែរឿងព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ៨៤.- នីតិវិធីនៃការផ្សះផ្សាវិវាទ និងដោះស្រាយវិវាទ**

គ.ម.ក. ក្រោយពីបានទទួលពាក្យប្តឹងហើយ ត្រូវសាកសួរភាគីទាំងសងខាងឱ្យដឹងពីកម្មវត្ថុនៃវិវាទ រួចសាកល្បងផ្សះផ្សាភាគីដោយយកច្បាប់វិធាន និងបទប្បញ្ញត្តិផ្សេងៗជាមូលដ្ឋាន ។

លទ្ធផលផ្សះផ្សា ត្រូវមានចុះក្នុងកំណត់ហេតុធ្វើដោយគ.ម.ក. បញ្ជាក់ការយល់ព្រម ឬមិនយល់ព្រមផ្សះផ្សានៃភាគី ។ កំណត់ហេតុត្រូវមានចុះហត្ថលេខាដោយគ.ម.ក. និងភាគីទាំងអស់ និងត្រូវចម្លងជូនគ្រប់ភាគី ។

ការព្រមព្រៀងដែលបានធ្វើឡើង នៅចំពោះមុខគ.ម.ក. គឺជាការព្រមព្រៀងដែលមានអានុភាពអនុវត្ត ។

ក្នុងករណីដែលគ្មានការសះជានឹងគ្នា សាមីភាគីអាចស្នើសុំឱ្យបញ្ជូនកំណត់ហេតុមិនសះជាទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬ ប្តឹងទៅតុលាការមានសមត្ថកិច្ច ។ អាជ្ញាយុកាលនៃបណ្តឹងទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬ ប្តឹងទៅតុលាការមានសមត្ថកិច្ច មានរយៈពេល ៩០(កៅសិប) ថ្ងៃ ពុំនោះទេ សិទ្ធិប្តឹងនេះនឹងត្រូវបាត់បង់ ។

**មាត្រា ៨៥.- វិធានការបន្ថែមរបស់ គ.ម.ក.**

ដើម្បីបន្ថែមទៅលើវិធានការដែលគ.ម.ក. ដាក់ឱ្យអនុវត្តនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ គ.ម.ក. អាចចាត់វិធានការដូចខាងក្រោម :

១- ក្នុងករណីដែលមានការប្រព្រឹត្តល្មើសនឹងច្បាប់ ឬ បទប្បញ្ញត្តិ ដែលធ្វើឡើងអនុលោមតាមច្បាប់នេះ ឬ រំលោភលើច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត អគ្គនាយកនៃគ.ម.ក. អាច :

-ចេញលិខិតព្រមានទៅបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់នេះ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត

-ចេញបទបញ្ជាឱ្យបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់

នេះ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត ធ្វើការជួសជុលសំណងព្យសនកម្ម ស្របតាមច្បាប់នេះ និងច្បាប់ដទៃទៀត ទៅតាមអំពើល្មើសដែលបុគ្គលនោះ បានប្រព្រឹត្តនៅកាលបរិច្ឆេទជាក់លាក់មួយ

-ស្នើសុំទៅតុលាការមានសមត្ថកិច្ច ដើម្បីចេញដីកាតម្រូវឱ្យបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀតឱ្យអនុវត្តតាមច្បាប់ និងឱ្យជួសជុលសំណងព្យសនកម្មតាមការកំណត់របស់តុលាការដែលមានអំណាចឆន្ទានុសិទ្ធិសម្រេច

-ចាត់វិធានការដាក់ពិន័យអន្តរការណ៍ ឬ ដាក់ទណ្ឌកម្មរដ្ឋបាលលើបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌនៃច្បាប់ ។ ការដាក់ទណ្ឌកម្មរដ្ឋបាលត្រូវកំណត់ដោយគ.ម.ក.

-ព្យួរជាបណ្តោះអាសន្ន ឬ បញ្ឈប់ការងាររបស់អគ្គនាយក នាយក សមាជិកគណៈគ្រប់គ្រង ឬ បុគ្គលិកជាន់ខ្ពស់របស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត

-ជ្រើសរើស និងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬ សកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត ។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ទៅឱ្យអគ្គនាយកគ.ម.ក. តាមលក្ខខណ្ឌដែលមានក្នុងកិច្ចសន្យាជាមួយអគ្គនាយកនៃគ.ម.ក. និង

-ដាក់កំហិត ឬ បញ្ឈប់សកម្មភាពជាក់លាក់ ឬ ទូទៅដែលធ្វើឡើងដោយនីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត ទោះបីជាសកម្មភាពទាំងនោះ ត្រូវបានធ្វើឡើងស្រប ឬ មិនស្របតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬ នៃការអនុញ្ញាតដែលអគ្គនាយកនៃគ.ម.ក. ផ្តល់ឱ្យក៏ដោយ ។

២-ក្នុងករណីដែលគ.ម.ក. ពិនិត្យឃើញថា នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត អាចជាអសាធនីយ ឬ មានបញ្ហាផ្នែកហិរញ្ញវត្ថុ អគ្គនាយកនៃគ.ម.ក. អាចប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីតែងតាំង ឬ ស្នើសុំទៅតុលាការ ដើម្បីតែងតាំងបុគ្គលដែល

ROYAUME DU CAMBODGE
LE MINISTRE ... ROYAL

43

មានសមត្ថភាពសមស្របឱ្យធ្វើជាអភិបាលបណ្ដោះអាសន្ន ដើម្បីគ្រប់គ្រង និងរៀបចំឡើងវិញ ឬ ជម្រះបញ្ជីនីតិបុគ្គលនោះ ស្របតាមច្បាប់ស្ដីពីក្ស័យធននៃព្រះរាជាណាចក្រកម្ពុជា ឬ បទប្បញ្ញត្តិផ្សេងៗទៀតដែលមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់នេះ ។ ក្នុងករណីដែលមានទំនាស់រវាងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ក្ស័យធន ត្រូវយកបទប្បញ្ញត្តិនៃច្បាប់នេះមកអនុវត្ត ។

**មាត្រា ៤៦.- សិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់ គ.ម.ក.**

បុគ្គលដែលទទួលរងការខូចខាតដោយវិធានការ ឬ សេចក្ដីសម្រេចណាមួយរបស់ **គ.ម.ក.** អាចប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ដើម្បីសុំឱ្យពិនិត្យឡើងវិញនូវវិធានការ ឬ សេចក្ដីសម្រេចនោះ ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៤៧.- ការបោះផ្សាយ និងលក់មូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលបោះផ្សាយ និងលក់មូលបត្រជាសាធារណៈដោយគ្មានការអនុញ្ញាតពី **គ.ម.ក.** ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន)រៀល ដល់ ៥០០.០០០.០០០(ប្រាំរយលាន)រៀល ។

**មាត្រា ៤៨.- សំណើលក់មូលបត្រជាសាធារណៈដោយខុសច្បាប់**

បុគ្គលណាដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៤៩.- អំពីផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានខុស**

បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមិនបំពេញកាតព្វកិច្ចតាមកថាខណ្ឌទី ១ នៃមាត្រា ២០ នៃច្បាប់នេះ ឬ ដែលផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានពុំខុសជាសាធារណៈ ដោយគ្មានការអនុញ្ញាតពី និងចុះបញ្ជីនៅគ.ម.ក. ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៥០.- ការធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ដោយគ្មានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. ដោយអនុលោមតាមច្បាប់នេះ ឬច្បាប់ផ្សេងៗទៀតជាធរមាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៥១.- វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ និង សេវារក្សាទុកមូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬ សេវារក្សាទុកមូលបត្រ ដោយគ្មានការអនុញ្ញាតពី **គ.ម.ក.** ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ២០០.០០០.០០០(ពីររយលាន) រៀល ។

**មាត្រា ៥២.- ការធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាប័ណ្ណ**

លើកលែងតែពាណិជ្ជករមូលបត្រអញ្ញត្រកម្ម ឬ ពាណិជ្ជករពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម បុគ្គលណាដែលធ្វើអាជីវកម្មមូលបត្រ ឬ តាំងខ្លួនជាអ្នកធ្វើអាជីវកម្មមូលបត្រក្នុងទម្រង់ជាក្រុមហ៊ុនមូលបត្រ ឬ ជនណាដែលធ្វើជា ឬ តាំងខ្លួនជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដើម្បីធ្វើអាជីវកម្មមូលបត្រ ដោយគ្មានអាជ្ញាប័ណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។

- នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៥៣.- ការមិនគោរពតាមការណែនាំរបស់ គ.ម.ក.**

បុគ្គលដែលមិនគោរពតាមបញ្ញត្តិនៃមាត្រា ៣០ និងមាត្រា ៣៧ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ :

ROYAUME DU CAMBODGE - LE MINISTRE DU PALAIS ROYAL

ក-ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល ។

ខ-ពី ២០.០០០.០០០(ម្ភៃលាន) រៀល ទៅ ២០០.០០០.០០០ (ពីររយលាន)រៀល ចំពោះនីតិបុគ្គល ។

**មាត្រា ៥៤.- បទល្មើសជួញដូរផ្ទៃក្នុង ជួញដូរក្លែងក្លាយ និងប្រើឧបាយកលក្នុងទីផ្សារ សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬ នាំឱ្យយល់ខុស**

បុគ្គលដែលប្រព្រឹត្តដោយចេតនាល្មើសនឹងបញ្ញត្តិនៃមាត្រា ៤០ កថាខណ្ឌទី ៣ មាត្រា ៤១ និងមាត្រា ៤២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ដល់ ១០(ដប់)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០(ហាសិបលាន) រៀល ដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ។

**មាត្រា ៥៥.- ទោសបន្ថែមអនុវត្តចំពោះរូបវន្តបុគ្គល**

ចំពោះបទល្មើសដូចមានចែងនៅក្នុងច្បាប់នេះ ទោសបន្ថែមមួយ ឬ ច្រើន ដូចខាងក្រោម អាចត្រូវបានប្រកាស ៖

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះ បានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ។

២-ការហាមឃាត់ ការបើកបរយានយន្តគ្រប់ប្រភេទ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ) ឆ្នាំ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេលមិនលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទល្មើសឧក្រិដ្ឋ និងសម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ចំពោះបទល្មើសមជ្ឈិម ។

៤-ការហាមឃាត់ទណ្ឌិតបរទេសនូវការចូលមក និងស្នាក់អាស្រ័យនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៧-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសនូវឧបភោគភណ្ឌ សម្ភារៈ និងគ្រឿងសង្ហារឹមតែងលម្អទីតាំងដែលក្នុងទីតាំងនោះបទល្មើសត្រូវបានប្រព្រឹត្ត ។

៩-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១០-ការបិទគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបទល្មើស ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១១-ការហាមឃាត់ ការធ្វើអាជីវកម្មបើគ្រឹះស្ថាន ដែលបើកជាសាធារណៈ ឬ ដែលប្រើប្រាស់ដោយសាធារណជនជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១២-ការបណ្ដេញចេញពីទីផ្សារមូលបត្រ ។

១៣-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេលមិនលើសពី ២ (ពីរ) ខែ ។

១៤-ការចេញផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ។

១៥-ការចាក់ផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេលមិនលើសពី ៨ (ប្រាំបី) ថ្ងៃ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ៥៦.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

ចំពោះបទល្មើសដូចមានចែងក្នុងច្បាប់នេះ នីតិបុគ្គលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាង ដើម្បីជាប្រយោជន៍នៃនីតិបុគ្គលនោះ ។

ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ ។

**មាត្រា ៥៧.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលទោសបន្ថែមមួយ ឬ ច្រើន ដូចខាងក្រោម៖

-ការរំលាយចោល

-ការដាក់ឱ្យនៅក្រោមការតាមដានរបស់តុលាការ

-ការហាមចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន

-ការបណ្តេញចេញពីទីផ្សារមូលបត្រ

-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ

-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាគោលដៅនៃបទល្មើស

-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស

-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស

-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយគមនាគមន៍ សោតទស្សន៍ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៥៨.-- បទប្បញ្ញត្តិដែលផ្ទុយនឹងច្បាប់នេះ**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៧១០.៥៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ៥០២ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ១១ ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
# សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ

- **ការកាន់កាប់ភាគហ៊ុនចំនួនច្រើន** (Substantial Share Holding) សំដៅដល់ការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់បុគ្គលម្នាក់ ឬ ភាគីពាក់ព័ន្ធ ឬ សមាការីរបស់បុគ្គលនោះដែលមានចំនួនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ។

- **កិច្ចសន្យាធានាទិញ** (Underwriting Agreement) សំដៅដល់កិច្ចព្រមព្រៀងដែលធ្វើឡើងដើម្បីធានាទិញមូលបត្រទាំងអស់ ឬ មួយផ្នែកដែលលក់មិនអស់ តាមនីតិវិធីនៅកាលបរិច្ឆេទផុតកំណត់នៃសំណើលក់ជាសាធារណៈ ។ កិច្ចសន្យាធានាទិញនោះគឺរាប់បញ្ចូលទាំងកិច្ចសន្យាធានាទិញបន្តដែលធ្វើឡើងដោយបុគ្គលដែលមានការអនុញ្ញាតតាមច្បាប់នេះ ។

ផុតរយៈពេលនោះឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៍ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ ។

- **ក្រុមហ៊ុនមូលបត្រ** (Securities Firm) សំដៅដល់ក្រុមហ៊ុន ឬក្រុមហ៊ុនសហកម្មសិទ្ធិដែលទទួលបានអាជ្ញាប័ណ្ណដើម្បីធ្វើអាជីវកម្មមូលបត្រដោយស្របទៅតាមច្បាប់នេះ ។

- **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** (Public Limited Company) សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

- **ក្រុមហ៊ុនសហកម្មសិទ្ធិ** (Partnertship) សំដៅដល់សមាគមជំនួញ ដែលធ្វើអាជីវកម្មទទួលខុសត្រូវទូទៅ ឬ ទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងដោយរួបរវន្តបុគ្គលរួមគ្នា និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

- **ក្រុមហ៊ុន** (Company) សំដៅដល់ក្រុមហ៊ុនឯកជន ឬ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានបង្កើត ឬ ចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

- **គណៈកម្មការមូលបត្រកម្ពុជា** (Securities and Exchange Commission of Cambodia) សំដៅដល់នីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់នេះ ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការមូលបត្រ ។

- **តុលាការ** (Court) សំដៅដល់តុលាការមានសមត្ថកិច្ចដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីបើកសវនាការនិងសម្រេចសេចក្ដីដែលបណ្ដឹងតាមច្បាប់នេះ ។

- **ភ្នាក់ងារក្រុមហ៊ុនមូលបត្រ** (Securities representative) សំដៅដល់បុគ្គលដែលបំពេញនូវមុខងារ ឬ សកម្មភាពតាមការឯកភាពរបស់ក្រុមហ៊ុនមូលបត្រដែលតម្រូវឱ្យមាន និងត្រូវមានអាជ្ញាប័ណ្ណដោយអនុលោមតាមច្បាប់នេះ ។ ភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវរាប់បញ្ចូលទាំងអគ្គនាយក នាយក បុគ្គលិក ឬ នយោជិតរបស់ក្រុមហ៊ុន ឬ សហកម្មសិទ្ធិករដែលបំពេញមុខងារទាំងនេះក្នុងនាមក្រុមហ៊ុនមូលបត្រ ។

- **ទីផ្សារមូលបត្រ** (Securities Market) សំដៅដល់ទីផ្សារ ឬ ទីកន្លែងជួញដូរមូលបត្រ ឬ ប្រព័ន្ធដែលផ្ដល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬ ស្នើការទិញ-លក់មូលបត្រ ។

- **ទម្រង់អរូបីនៃមូលបត្រ** (Dematerialized Form) សំដៅដល់ទម្រង់កត់ត្រាកម្មសិទ្ធិស្របច្បាប់នៃមូលបត្រដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ឌីជីថល ឬ កុំព្យូទ័រ ដែលអាចបើកមើលបាននិងបោះពុម្ពជាទម្រង់ដែលអាចអានបាន ។

- **ទិញ** សំដៅដល់ការទិញតាមគ្រប់រូបភាព ដូចជាទិញដោយផ្ទាល់ ឬ ទិញតាមប្រព័ន្ធអេឡិចត្រូនិច ឬ ចុះឈ្មោះសុំទិញ (ធ្វើបរិវិសកម្ម) ។

- **នីតិបុគ្គលប្រតិស្រុត** (Permitted Entity) សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយនិងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងៗ ។ នីតិបុគ្គលនេះមិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា ។

- **បុគ្គល** (Person) សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលរួមទាំងក្រុមហ៊ុននិងក្រុមហ៊ុន

- **បុគ្គលពាក់ព័ន្ធ** (Related Entity) ទាក់ទិននឹងក្រុមហ៊ុនដែលធ្វើសំណើលក់មូលបត្រជាសាធារណៈសំដៅដល់បុគ្គលណាមួយដូចខាងក្រោម :

ក-ភាគទុនិកដែលជាស្ថាបនិកក្រុមហ៊ុន ។

ខ-សាច់ញាតិផ្ទាល់របស់ភាគទុនិកជាស្ថាបនិកក្រុមហ៊ុន ។

គ-នាយកក្រុមហ៊ុន ឬ សាខាក្រុមហ៊ុន ឬ ក្រុមហ៊ុនហ្វូលឌីង ។

ឃ-សាច់ញាតិផ្ទាល់របស់នាយកក្រុមហ៊ុនទាំងនោះ ។

ង-សាខាក្រុមហ៊ុន ឬ ក្រុមហ៊ុនហ្វូលឌីង ឬ សាខាក្រុមហ៊ុនហ្វូលឌីង ។

ច-រូបវន្តបុគ្គលឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានចែងក្នុងបទប្បញ្ញត្តិ ឬ អនុក្រឹត្យ ។

- **ប្រតិបត្តិការរក្សាទុកមូលបត្រ** (Securities Depository) សំដៅដល់បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្មដូចខាងក្រោមនេះ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬ ធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ :

ក- កាន់កាប់ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង ។

ខ-ទទួលរក្សាទុកនូវមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬ ជាទម្រង់អរូបីក្តីដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រក្នុងនាមអតិថិជនឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង ។

គ-ផ្តល់សេវាកម្មនិងលក្ខណៈងាយស្រួលផ្សេងៗទៀតដែលទាក់ទិននឹងការផ្តល់សេវាកម្មដូចមានចែងក្នុងកថាខណ្ឌ(ក) និង(ខ) ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL •

- **ប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម** (Exempt Securities Transaction) សំដៅដល់ប្រតិបត្តិការមូលបត្រដែលធ្វើដោយបុគ្គលជាក់លាក់ណាមួយ ឬ ដោយបុគ្គលផ្សេងទៀត ដើម្បីចុះឈ្មោះស៊ុំទិញ ទិញ បោះផ្សាយ លក់ ឬ ផ្ទេរមូលបត្រ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។

- **ប្រព័ន្ធផាត់ទាត់ និងទូទាត់** (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្របំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបានដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ ។

- **ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម** (Interest in a Managed Investment Scheme) សំដៅដល់ផលប្រយោជន៍ស្របច្បាប់ទោះបីដោយផ្ទាល់ ឬ ដោយប្រយោល នៅក្នុងគម្រោងវិនិយោគដែលមានលក្ខណៈដូចតទៅ :

១-បុគ្គលផ្តល់វិភាគទានសាច់ប្រាក់ ឬ ផ្តល់វត្ថុមានតម្លៃ ដើម្បីមានសិទ្ធិទទួលផលកម្រៃដែលបានមកពីគម្រោងវិនិយោគ ។

២-រាល់វិភាគទានដែលប្រមូលបានហើយត្រូវបានយកទៅប្រើប្រាស់នៅក្នុងគម្រោងវិនិយោគ ដើម្បីបង្កើតផលកម្រៃហិរញ្ញវត្ថុ ឬ ផលកម្រៃដែលបានមកជាសិទ្ធិ ឬ ជាផលប្រយោជន៍លើទ្រព្យសម្បត្តិ សម្រាប់សមាជិកដែលមានផលប្រយោជន៍ក្នុងគម្រោងវិនិ-យោគនោះ ទោះបីសមាជិកនោះមិនគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃនៃគម្រោងវិនិយោគនោះក៏ដោយ ។

- **ពាណិជ្ជករមូលបត្រ** (Securities Dealer) សំដៅដល់ពាណិជ្ជករដែលធ្វើអាជីវកម្មមូលបត្រ ។

- **ពាណិជ្ជករមូលបត្រអញ្ញត្រកម្ម** (Exempt Securities Dealer) សំដៅដល់បុគ្គលដែលធ្វើអា-ជីវកម្មមូលបត្រ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។ ពាណិជ្ជករមូលបត្រអញ្ញត្រកម្មនេះនឹងមានចែងដោយអនុក្រឹត្យ ឬ ប្រកាស ។

- **ភាគហ៊ុនមានសិទ្ធិបោះឆ្នោត** (Voting Share) សំដៅដល់ភាគហ៊ុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលផ្តល់សិទ្ធិបោះឆ្នោតទៅឱ្យអ្នកកាន់កាប់ភាគហ៊ុនដែលបានចុះបញ្ជី ។

- **មូលបត្រមហាជន** (Non-government Securities) សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអនុលោមតាមច្បាប់ ។ មូលបត្រទាំងនោះមាន :

ក-មូលបត្រកម្មសិទ្ធិរាប់បញ្ចូលទាំងភាគហ៊ុន ។

ខ-មូលបត្របំណុល រាប់បញ្ចូលទាំងសញ្ញាប័ណ្ណ ។

គ-ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម ។

ឃ-ឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរីវេទីវ ដែលទាក់ទងនឹងមូលបត្រមួយគឺយោងទៅលើចំណុច(ក) (ខ) ឬ (គ) ខាងលើ ។

ង-ឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលកំណត់ថាជាមូលបត្រ ។

- **មូលបត្រកម្មសិទ្ធិ** (Equity Securities) សំដៅដល់ផលប្រយោជន៍ ឬ សិទ្ធស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោតភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា ។

- **មូលបត្រគាហក** (Bearer Securities) សំដៅដល់មូលបត្រដែលកម្មសិទ្ធិនៃមូលបត្រនោះត្រូវបានកំណត់ដោយការកាន់កាប់ជារូបវន្ត មិនមែនតាមរយៈការចុះបញ្ជីនៃកម្មសិទ្ធិករនៅក្នុងបញ្ជីមូលបត្រ ដែលរក្សាទុកដោយ ឬ រក្សាទុកសំរាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ។

- **មូលបត្រថ្មី** (New Securities) សំដៅដល់មូលបត្រដែលមិនធ្លាប់បានបោះផ្សាយ ឬ ធ្វើសំណើលក់ជាសាធារណៈពីមុនមកដោយក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមានចែងក្នុង

- **មូលបត្របំណុល** (Debt Securities) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយ ដោយបញ្ជាក់ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឱ្យប្រាក់ខ្ចី ឬ ដាក់ជាប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬ បុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះ ហើយទោះបីជាមាន ឬ គ្មានទ្រព្យដាក់ធានាក្តី ។

- **រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- **វិធានប្រតិបត្តិការនៃទីផ្សារមូលបត្រ ឬ នៃប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ នៃសេវារក្សាទុកមូលបត្រ** (Operating Rules of a securities market, clearance and settlement facility, or Securities Depository) សំដៅដល់វិធាន និងនីតិវិធី ដែលគ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សារ ឬ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ដែលរួមទាំង :

(១) លក្ខន្តិកៈរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ឬ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ ។

(២) វិធាននៃការចុះបញ្ជីនៅទីផ្សារមូលបត្រ ។

- **សមាគមី** (Associate) សំដៅដល់បុគ្គលដែលកំពុងមានទំនាក់ទំនងអាជីវកម្មជាមួយបុគ្គលមួយផ្សេងទៀត ។

- **សមាជិកគ្រួសារផ្ទាល់** (Close relative) សំដៅដល់ទំនាក់ទំនងជាប្តី ប្រពន្ធ កូន ឪពុក ម្តាយ បងប្អូនប្រុស ឬ បងប្អូនស្រីរបស់បុគ្គលណាម្នាក់ ។

- **ស្វ័យនិយ័តករ** (Self Regulatory Organization) សំដៅដល់ស្ថាប័នដែលគ្រប់គ្រងសមាជិករបស់ខ្លួនតាមរបៀបដែលសមាជិកនោះធ្វើអាជីវកម្ម ។

- **សំណងព្យសនកម្ម** (Damage) សំដៅដល់ការទូទាត់សងការខូចខាត ។

- **សំណើលក់មូលបត្រជាសាធារណៈ** (Public Offer) សំដៅដល់ការអញ្ជើញសាធារណជនឱ្យដាក់ស្នើសុំទិញ ឬ ទិញមូលបត្រ ។ សំណើលក់នេះរួមមាន :

(១) សំណើដាក់លក់ ឬ ទិញមូលបត្រដែលធ្វើឡើងចំពោះមជ្ឈដ្ឋានសាធារណជន ជាក់លាក់ណាមួយដែលត្រូវបានជ្រើសរើសឡើងតាមរបៀបណាក៏ដោយ

(២) សំណើដាក់លក់ឬ ទិញមូលបត្រដែលធ្វើឡើង តាមរបៀបចៃដន្យចំពោះសមាជិកនៃមជ្ឈដ្ឋានសាធារណៈដែលបានជ្រើសរើស

(៣) សំណើដាក់លក់ ឬ ទិញមូលបត្រដែលធ្វើឡើង ចំពោះបុគ្គលដែលស្គាល់ពីមុនតាមរយៈការផ្សាយពាណិជ្ជកម្មសំណើដាក់លក់ ឬ ទិញ ឬ តាមរយៈការអញ្ជើញបុគ្គលនោះឱ្យមកសាកសួរព័ត៌មាន ឬ សុំការពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ *

(៤)ការចែកអត្ថបទផ្សាយពាណិជ្ជកម្ម ឯកសារផ្តល់ព័ត៌មាន ឬពាក្យស្នើសុំដែលទាក់ទងនឹងការដាក់ពាក្យសុំទិញ ការទិញ ឬ ការលក់មូលបត្រ ។

ប៉ុន្តែសំណើលក់ជាសាធារណៈមិនរាប់បញ្ចូលនូវ ៖

-សំណើលក់ជាឯកជនដែលធ្វើឡើងចំពោះបុគ្គលដែលមានទំនាក់ទំនងជាមួយនឹងបុគ្គលធ្វើសំណើលក់ ឬ សហការី ។

-សំណើលក់ជាឯកជនដែលធ្វើឡើង ចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប)រូប ។

-ការអញ្ជើញបុគ្គលណាមួយឱ្យធ្វើកិច្ចព្រមព្រៀងធានាទិញ ឬ កិច្ចព្រមព្រៀងធានាបន្តដែលទាក់ទិននឹងការបោះផ្សាយមូលបត្រ ។

- **សំណើលក់មូលបត្រជាឯកជន** (Private or personal Offer) សំដៅដល់សំណើលក់ដែល ៖

១-ត្រូវបានធ្វើស្នើការដោយបុគ្គលដែលជាអ្នកទទួលសំណើ ។

២-ត្រូវបានធ្វើឡើងចំពោះបុគ្គល ដែលមានការចាប់អារម្មណ៍ចំពោះសំណើលក់ដោយផ្អែកណាលើ

(ក)ទំនាក់ទំនងពីមុនរវាងបុគ្គលដែលធ្វើសំណើ និងអ្នកដែលទទួលសំណើ

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL *

(ខ)ទំនាក់ទំនងវិជ្ជាជីវៈឬទំនាក់ទំនងដទៃទៀតរវាងបុគ្គលដែលធ្វើសំណើ និងអ្នកទទួលសំណើនោះ

(គ)សេចក្តីប្រកាស ឬ អំពើរបស់បុគ្គលណាមួយដែលបង្ហាញថាខ្លួនចាប់អារម្មណ៍នឹងសំណើនោះ ។

- **សំណើលក់អញ្ញត្រកម្ម** (Exempt Offer) សំដៅដល់សំណើលក់មូលបត្រជាសាធារណៈដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់ ។ សំណើលក់អញ្ញត្រកម្មនេះមានចែងដោយអនុក្រឹត្យឬប្រកាស ។

- **អសាធនីយ** (Insolvent) សំដៅដល់ការមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់សងបំណុលដែលជំពាក់គេ ។

- **អ្នកវិនិយោគសាធារណៈ** (Public Investor) សំដៅដល់សាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិទិញឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសមាការី ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ នីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតនោះ ។

- **អាជីវកម្មមូលបត្ររបស់បុគ្គលមួយ** (Securities Business of Person) ត្រូវគិតទាំងសកម្មភាពដូចខាងក្រោម:

ក-ការទិញ ឬលក់មូលបត្រក្នុងនាមជាភ្នាក់ងាររបស់បុគ្គលផ្សេងទៀត ។

ខ-ការទិញ ឬ លក់មូលបត្រដោយប្រើប្រាស់មូលនិធិរបស់ខ្លួន និងក្នុងនាមខ្លួនឯង ។

គ-ការផ្តល់ប្រឹក្សាអំពីវិនិយោគមូលបត្រ ឬ ការបោះផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនអ្នកវិនិយោគសាធារណៈ ។

ឃ-ចុះកិច្ចព្រមព្រៀងធានា ជាមួយក្រុមហ៊ុនដែលធ្វើសំណើលក់ ឬ ទិញមូលបត្រ ឬ ចុះកិច្ចព្រមព្រៀងធានាទិញ ឬ លក់បន្ត ។

- **ឯកសារផ្តល់ព័ត៌មានជាប្រចាំ** (Continuous Disclosure Document) សំដៅដល់ឯកសារផ្តល់ព័ត៌មានដែលពិពណ៌នាអំពីព្រឹត្តិការណ៍ ដែលកើតឡើងនៅពេលណាមួយក្នុងអាយុកាលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ។

- **ឯកសារផ្តល់ព័ត៌មាន** (Disclosure Document) សំដៅដល់លិខិតជូនដំណឹង ឬ សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយអំពីប្រវត្តិក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុ ឬជាការអញ្ជើញឱ្យទិញ ឬ សំណើឱ្យគេដាក់ពាក្យសុំទិញ ឬ ទិញមូលបត្រ ឬប្រកាសអំពីការដាក់លក់ ឬ ការលក់មូលបត្រ និងរាប់បញ្ចូលទាំងឯកសារផ្តល់ព័ត៌មានជាប្រចាំ ឬ ឯកសារផ្តល់ព័ត៌មានជំនួសផងដែរ ។

- **ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ** (Derivative Instrument) សំដៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬ កាតព្វកិច្ចនៃមូលបត្រដើមទៅឱ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬ កាតព្វកិច្ចទិញលក់ ឬ ដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគតដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬ មិនប្រើប្រាស់សិទ្ធិនេះក៏ដោយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

rector, officer or employee of or volunteer for such plan, company, account, person, or entity, acting within the scope of that person's employment or activities with respect to such plan, shall be deemed to be a "broker", "dealer", "municipal securities broker", "municipal securities dealer", "government securities broker", "government securities dealer", "clearing agency", or "transfer agent" for purposes of this title—

(1) solely because such plan, company, person, or entity buys, holds, sells, trades in, or transfers securities or acts as an intermediary in making payments in connection with transactions in securities for its own account in its capacity as trustee or administrator of, or otherwise on behalf of, or for the account of, any church plan, company, or account that is excluded from the definition of an investment company under section 3(c)(14) of the Investment Company Act of 1940; and

(2) if no such person or entity receives a commission or other transaction-related sales compensation in connection with any activities conducted in reliance on the exemption provided by this subsection.

(h) LIMITED EXEMPTION FOR FUNDING PORTALS.—

(1) IN GENERAL.—The Commission shall, by rule, exempt, conditionally or unconditionally, a registered funding portal from the requirement to register as a broker or dealer under section 15(a)(1), provided that such funding portal—

(A) remains subject to the examination, enforcement, and other rulemaking authority of the Commission;

(B) is a member of a national securities association registered under section 15A; and

(C) is subject to such other requirements under this title as the Commission determines appropriate under such rule.

(2) NATIONAL SECURITIES ASSOCIATION MEMBERSHIP.—For purposes of sections 15(b)(8) and 15A, the term "broker or dealer" includes a funding portal and the term "registered broker or dealer" includes a registered funding portal, except to the extent that the Commission, by rule, determines otherwise, provided that a national securities association shall only examine for and enforce against a registered funding portal rules of such national securities association written specifically for registered funding portals.

**SEC. 3A. [78c–1] SWAP AGREEMENTS.**

(a) [Section 762(d)(1)(A) of Public Law 111–203 repeals subsection (a) and states "...and reserving that subsection".]

(b) SECURITY-BASED SWAP AGREEMENTS.—

(1) The definition of "security" in section 3(a)(10) of this title does not include any security-based swap agreement.

(2) The Commission is prohibited from registering, or requiring, recommending, or suggesting, the registration under this title of any security-based swap agreement. If the Commission becomes aware that a registrant has filed a registration application with respect to such a swap agreement, the Commission shall promptly so notify the registrant. Any such reg-

istration with respect to such a swap agreement shall be void and of no force or effect.

(3) Except as provided in section 16(a) with respect to reporting requirements, the Commission is prohibited from—

(A) promulgating, interpreting, or enforcing rules; or

(B) issuing orders of general applicability;

under this title in a manner that imposes or specifies reporting or recordkeeping requirements, procedures, or standards as prophylactic measures against fraud, manipulation, or insider trading with respect to any security-based swap agreement.

(4) References in this title to the "purchase" or "sale" of a security-based swap agreement shall be deemed to mean the execution, termination (prior to its scheduled maturity date), assignment, exchange, or similar transfer or conveyance of, or extinguishing of rights or obligations under, a security-based swap agreement, as the context may require.

**SEC. 3B. [78c–2] SECURITIES-RELATED DERIVATIVES.**

(a) Any agreement, contract, or transaction (or class thereof) that is exempted by the Commodity Futures Trading Commission pursuant to section 4(c)(1) of the Commodity Exchange Act (7 U.S.C. 6(c)(1)) with the condition that the Commission exercise concurrent jurisdiction over such agreement, contract, or transaction (or class thereof) shall be deemed a security for purposes of the securities laws.

(b) With respect to any agreement, contract, or transaction (or class thereof) that is exempted by the Commodity Futures Trading Commission pursuant to section 4(c)(1) of the Commodity Exchange Act (7 U.S.C. 6(c)(1)) with the condition that the Commission exercise concurrent jurisdiction over such agreement, contract, or transaction (or class thereof), references in the securities laws to the "purchase" or "sale" of a security shall be deemed to include the execution, termination (prior to its scheduled maturity date), assignment, exchange, or similar transfer or conveyance of, or extinguishing of rights or obligations under such agreement, contract, or transaction, as the context may require.

**SEC. 3C. [78c–3] CLEARING FOR SECURITY-BASED SWAPS.**

(a) IN GENERAL.—

(1) STANDARD FOR CLEARING.—It shall be unlawful for any person to engage in a security-based swap unless that person submits such security-based swap for clearing to a clearing agency that is registered under this Act or a clearing agency that is exempt from registration under this Act if the security-based swap is required to be cleared.

(2) OPEN ACCESS.—The rules of a clearing agency described in paragraph (1) shall—

(A) prescribe that all security-based swaps submitted to the clearing agency with the same terms and conditions are economically equivalent within the clearing agency and may be offset with each other within the clearing agency; and

(B) provide for non-discriminatory clearing of a security-based swap executed bilaterally or on or through the

(C) The term "foreign person controlled by a United States person" includes any noncorporate entity in which United States persons directly or indirectly have more than a 50 per centum beneficial interest, and any corporation in which one or more United States persons, directly or indirectly, own stock possessing more than 50 per centum of the total combined voting power of all classes of stock entitled to vote, or more than 50 per centum of the total value of shares of all classes of stock.

(3) The Board of Governors of the Federal Reserve System may, in its discretion and with due regard for the purposes of this section, by rule or regulation exempt any class of United States persons or foreign persons controlled by a United States person from the application of this subsection.

(g) Subject to such rules and regulations as the Board of Governors of the Federal Reserve System may adopt in the public interest and for the protection of investors, no member of a national securities exchange or broker or dealer shall be deemed to have extended or maintained credit or arranged for the extension or maintenance of credit for the purpose of purchasing a security, within the meaning of this section, by reason of a bona fide agreement for delayed delivery of a mortgage related security or a small business related security against full payment of the purchase price thereof upon such delivery within one hundred and eighty days after the purchase, or within such shorter period as the Board of Governors of the Federal Reserve System may prescribe by rule or regulation.

RESTRICTIONS ON BORROWING BY MEMBERS, BROKERS, AND DEALERS

SEC. 8. [78h] It shall be unlawful for any registered broker or dealer, member of a national securities exchange, or broker or dealer who transacts a business in securities through the medium of any member of a national securities exchange, directly or indirectly—

(a) In contravention of such rules and regulations as the Commission shall prescribe for the protection of investors to hypothecate or arrange for the hypothecation of any securities carried for the account of any customer under circumstances (1) that will permit the commingling of his securities without his written consent with the securities of any other customer, (2) that will permit such securities to be commingled with the securities of any person other than a bona fide customer, or (3) that will permit such securities to be hypothecated, or subjected to any lien or claim of the pledgee, for a sum in excess of the aggregate indebtedness of such customers in respect of such securities.

